អង្គការសមាគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO



# បញ្ហាបរិស្ថាន

## និងសហគមន៍ក្រីក្រក្នុងទីក្រុង៖

### កាសិក្សាប្រៀបធៀប

## ការយល់ដឹង
## កាយល់ឃើញ
## ដំណោះស្រាយ









# សេចក្តីសង្ខេប

នេះ គឺជាបណ្តុំនៃការស្រាវជ្រាវ ដែលធ្វើការសិក្សា និងពិភាក្សាអំពីទិដ្ឋភាពផ្សេងៗ ដែលជាមូលហេតុនៃផលប៉ះពាល់ដល់សហគមន៍ក្រីក្រក្នុងទីក្រុងនៅកម្ពុជា។

ការសិក្សាទីមួយ ធ្វើការសិក្សាស្វែងយល់អំពីការយល់ដឹងរបស់សហគមន៍ក្រីក្រចំនួនបី នៅក្នុងទីក្រុងភ្នំពេញ ទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេនៅក្នុងដំណើរការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន (EIA)។ ការរកឃើញបានបង្ហាញពីការយល់ដឹងនៅមានកម្រិតរបស់ប្រជាសហគមន៍ទាំងនោះ ដោយលើកឡើងពីឧបសគ្គដែលមានដូចជាគម្លាតនៃទំនាក់ទំនង និងព័ត៌មានមិនគ្រប់គ្រាន់រវាងអាជ្ញាធរ និងពលរដ្ឋ។ ការសិក្សានេះផ្តល់អនុសាសន៍មួយចំនួនដូចជា ការធ្វើឱ្យប្រសើរឡើងនូវការចូលរួមរបស់សាធារណៈជនតាមរយៈការបង្កើនការយល់ដឹង ការពង្រឹងការអនុវត្តច្បាប់ និងការពង្រឹងតម្លាភាពជាដើម។

ការសិក្សាទីពីរ ធ្វើការសិក្សាស្វែងយល់អំពីស្ថានភាពរស់នៅនៅក្នុងសហគមន៍ក្រីក្រមួយនៅទីក្រុងភ្នំពេញដែលបាន និងកំពុងប្រឈមនឹងបញ្ហាសំរាម និងទឹកកខ្វក់។ ការសិក្សានេះធ្វើឡើងដើម្បីកំណត់ពីប្រភពពិតប្រាកដនៃសម្រាមដែលមាននៅក្នុងសហគមន៍ ហើយធ្វើការស្វែងរក និងផ្តល់ដំណោះស្រាយដែលឆ្លើយតបទៅនឹងបញ្ហាប្រឈមរបស់សហគមន៍មួយនេះ និងសហគមន៍ ឬតំបន់ស្រដៀងគ្នាផ្សេងទៀតនៅទីក្រុងភ្នំពេញ។

គម្រោងស្រាវជ្រាវទីបី ធ្វើការសិក្សាពីបញ្ហាប្រឈមនិងផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើសហគមន៍ក្រីក្រចំនួនពីរ នៅទីក្រុងភ្នំពេញ។

ការសិក្សានេះ មានគោលបំណងស្វែងយល់ពីការសម្របខ្លួនរបស់ប្រជាសហគមន៍ និងផ្តល់នូវអនុសាសន៍សម្រាប់ដំណោះស្រាយដែល

អាចធ្វើទៅបាន។ ការសម្ភាសន៍បង្ហាញពីលក្ខខណ្ឌអាកាសធាតុខុសប្រក្រតី ប្រព័ន្ធលូបង្ហូរទឹកមិនគ្រប់គ្រាន់ បញ្ហាប្រឈមក្នុងអាជីវកម្ម និងការកើនឡើងថ្លៃទឹក និងអគ្គិសនី។

ហើយគម្រោងស្រាវជ្រាវទីបួន ធ្វើការសិក្សាពីបញ្ហាប្រឈមនិងផលប៉ះពាល់នៃការបំពុលដោយសំឡេងនៅក្នុងសហគមន៍ក្រីក្រចំនួនពីរនៅទីក្រុងភ្នំពេញ។ ការសិក្សានេះផ្តោតលើការយល់ដឹងអំពីស្ថានភាពបច្ចុប្បន្ន ប្រភព និងប្រភេទនៃការបំពុលដោយសំឡេង រួមជាមួយនឹងការពិនិត្យមើលលើផលវិបាក និងការស្នើសុំដំណោះស្រាយ។

គម្រោងស្រាវជ្រាវទាំងនេះបានបង្ហាញពីបញ្ហាប្រឈមផ្សេងៗដែលមាននៅក្នុងសហគមន៍ក្រីក្រនៅទីក្រុង ហើយបញ្ហា និងការប្រឈមទាំងនោះរួមមានការយល់ដឹងមានកម្រិតអំពីសិទ្ធិ និងការចូលរួមរបស់ពួកគេនៅក្នុងដំណើរការនៃការវាយតម្លៃផលប៉ះពាល់បរិស្ថាន EIA បញ្ហាជាមួយនឹងការគ្រប់គ្រងកាកសំណល់ ផលប៉ះពាល់នៃការប្រែប្រួលអាកាសធាតុលើជីវិតប្រចាំថ្ងៃរបស់ពួកគេ និងផលប៉ះពាល់នៃសំលេងរំខាន និងការបំពុល។ តាមរយៈការសិក្សាទាំងនេះ អនុសាសន៍ត្រូវបានផ្តល់ជូនដើម្បីសម្រួលដល់ជីវភាពរស់នៅ និងសុខុមាលភាពរបស់ប្រជាសហគមន៍ទាំងនេះ។

អង្គការសហគមធាងត្នោត

Sahmakum Teang Tnaut Organization · a Cambodian Urban NGO

របាយការណ៍ស្រាវជ្រាវ ឆ្នាំ២០២៣

# ការពិនិត្យមើលកម្រិតនៃការយល់ដឹង

## និងទស្សនៈអំពីការចូលរួមក្នុងដំណើរការ
## វាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់សហគមន៍ក្រីក្រក្នុងទីក្រុង

# តារាងមាតិកា


សេចក្ដីសង្ខេប.....១

០១

សេចក្ដីផ្ដើម.....២

០២

សហគមន៍គោលដៅ.....៦

២.១. សហគមន៍ព្រៃកតាគង់៦០ម៉ែត្រ.....៦

២.២. សហគមន៍ព្រៃកតាគង់៣.....៧

២.៣. សហគមន៍បឹងត្របែកភូម៤.....៨

០៣

ការពិនិត្យខ្លឹមសារអត្ថបទ.....៩

៣.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន.....៩

៣.២. ក្របខណ្ឌច្បាប់ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា.....១០

៣.៣. ការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា.....១៣

៣.៤. បញ្ហាប្រឈមសំខាន់នៃការចូលរួមជាសាធារណៈនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា.....១៤

៣.៥. ការចូលរួមជាសាធារណៈនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងវារីអគ្គិសនីនៅកម្ពុជា.....១៥

៣.៦. សិទ្ធិទទួលបានព័ត៌មាន ជាសិទ្ធិទទួលបានសុខុមាលភាពនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិសថាន.....១៦

៣.៧. ក្របខណ្ឌការពារ គោរព និងដោះស្រាយ.....១៧

០៤

វិធីសាស្ត្រស្រាវជ្រាវ.....១៩

៤.១. ការជ្រើសរើសសំណាក.....១៩

៤.២. វិធីសាស្ត្រប្រមូលទិន្នន័យ.....២០

៤.៣. វិធីសាស្ត្រវិភាគទិន្នន័យ.....២០

៤.៤. លទ្ធផលរកឃើញផ្អែកតាមពិសោធន៍.....២០

# តារាងមាតិកា

៤.៥. ការពិចារណាលើក្រមសីលធម៌........................................................២០

០៥ លទ្ធផលស្រាវជ្រាវសំខាន់ៗ និងការវិភាគទិន្នន័យ ........................................២៣

៥.១. ចម្លើយឆ្លើយតបទៅនឹងសំណួរ "អ្វីទៅជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងជាសិទ្ធិរបស់ពួកគេ ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន?". ....................................................................................................២៣

៥.២. គម្រោងសំណង់ខុនដូ ដែលស្ថិតនៅជិតសហគមន៍ព្រែកតាគង់៦០ ម៉ែត្រ...................................................................................................២៤

៥.៣. គម្រោងអភិវឌ្ឍន៍នៅជិតសហគមន៍ព្រែកតាគង់៣...............................២៥

៥.៤. អាងស្តុកទឹកបឹងត្របែក ដែលស្ថិតនៅជិតសហគមន៍បឹងត្របែកភូមិ៤.......២៦

៥.៥. ការវិភាគប្រៀបធៀបការយល់ដឹង ទស្សនៈ និងឧបសគ្គក្នុងដំណើការចូលរួមវាយតម្លៃហេតុប៉ះពាល់បរិស្ថាន........................................................២៨

៥.៥.១. ការយល់ដឹង និងទស្សនៈ...................................................២៨

៥.៥.២. ឧបសគ្គចំពោះការចូលរួម.................................................២៩

៥.៦. កម្រិតយល់ដឹង និងទស្សនៈរបស់សហគមន៍ក្រីក្រក្នុងទីក្រុងលើការចូលរួមដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន......................................២៩

៥.៧. ឧបសគ្គរាំងសហគមន៍ក្រីក្រក្នុងទីក្រុងក្នុងការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន.....................................................៣០

៥.៧.១. កង្វះខាតនៃការយល់ដឹង និងចំណេះដឹង...............................៣០

៥.៧.២. កង្វះខាតនៃទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន................៣១

៥.៧.៣. កង្វះខាតព័ត៌មាន និងការអញ្ជើញចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន.........................................៣១

៥.៧.៤. កង្វះខាតធន្ទះអនុវត្តសិទ្ធិរបស់ពួកគេ...................................៣១

០៦ សេចក្តីសន្និដ្ឋាន..............................................................................៣២

០៧ អនុសាសន៍.....................................................................................៣៣

# សេចក្តីសង្ខេប



ការស្រាវជ្រាវនេះ សិក្សាលើការយល់ដឹង និងទស្សនៈរបស់សហគមន៍ក្រីក្រក្នុងទីក្រុងនៅកម្ពុជាស្តីពីសិទ្ធិចូលរួមរបស់ពួកគេនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ របាយការណ៍នេះ រំលេចសារៈសំខាន់នៃការចូលរួមជាសាធារណៈ ដើម្បីសម្រេចបានកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព និងបញ្ហាប្រឈម ដែលរារាំងដល់កាចូលរួមរបស់សាធារណជន ជាពិសេសសហគមន៍ក្រីក្រក្នុងទីក្រុង។ ការសិក្សានេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណភាព ដោយរួមបញ្ចូលទាំងការសម្ភាស និងការពិភាក្សាក្រុម ដើម្បីប្រមូលទិន្នន័យពីសហគមន៍ក្រីក្រក្នុងទីក្រុង។ លទ្ធផលរកឃើញសំខាន់ៗបង្ហាញថាការយល់ដឹងរបស់ប្រជាសហគមន៍អំពីសិទ្ធិចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅមានកម្រិត និងបញ្ហានានា ដែលជាឧបសគ្គក្នុងការយល់ដឹង ដូចជាកង្វះខាតនៃទំនាក់ទំនង ការផ្សព្វផ្សាយព័ត៌មាន និងឆន្ទៈក្នុងការចូលរួមរបស់ប្រជាសហគមន៍។ របាយការណ៍នេះ បានផ្តល់អនុសាសន៍នានា ដើម្បីលើកកម្ពស់ការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរួមបញ្ចូលទាំងការផ្សព្វផ្សាយឱ្យមាន ការយល់ដឹង ការពង្រឹងក្របខណ្ឌច្បាប់ និងការលើកកម្ពស់តម្លាភាព។

*គោលបំណងនៃអនុសាសន៍នេះ ដើម្បីធានាថា សំឡេង និងកង្វល់របស់សហគមន៍ក្រីក្រក្នុងទីក្រុងត្រូវបានដឹងឮ និងដាក់បញ្ចូល នៅក្នុងដំណើរការនៃការសម្រេចចិត្តទាក់ទងនឹងគម្រោងអភិវឌ្ឍន៍។*



# ១. សេចក្ដីផ្ដើម



ការវាយតម្លៃ ហេតុប៉ះពាល់បរិស្ថាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការសម្រេចបានកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាព ដោយវាយតម្លៃ និងគ្រប់គ្រងផលប៉ះពាល់បរិស្ថាន នៅទីតាំងដែលមានសក្ដានុពលសម្រាប់គម្រោងអភិវឌ្ឍន៍។ កម្ពុជា ជាប្រទេសមួយផ្ដល់តម្លៃដល់ធនធានធម្មជាតិដ៏សម្បូរបែបរបស់ខ្លួន និងធានាតុល្យភាពនៃកំណើនសេដ្ឋកិច្ចក្នុងកិច្ចការពារបរិស្ថាន។ ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានគ្រប់គ្រងដោយការបង្កើតបទដ្ឋានគតិយុត្តិជាបន្តបន្ទាប់ ដោយរួមបញ្ចូលទាំងច្បាប់ស្ដីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ អនុក្រឹត្យលេខ៧២ ស្ដីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រកាសលេខ០២១ ស្ដីពីចំណាត់ថ្នាក់វាយតម្លៃហេតុ ប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍។ ក្របខណ្ឌច្បាប់ទាំងអស់នេះ ផ្ដល់មូលដ្ឋានសម្រាប់គម្រោងអភិវឌ្ឍន៍អនុវត្តឱ្យត្រឹមត្រូវ កាត់បន្ថយ និងគ្រប់គ្រងផលវិបាកផ្សេងៗលើបរិស្ថាន ប្រកបដោយប្រសិទ្ធភាព។[១] ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសារៈសំខាន់សម្រាប់ការការពារសិទ្ធិ និងសុខុមាលភាពរបស់សហគមន៍ក្រីក្រក្នុងទីក្រុង។ ជាដំបូង ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដើរតួនាទីយ៉ាងសំខាន់នៅក្នុងការកំណត់ និងកាត់បន្ថយផលប៉ះពាល់បរិស្ថានដ៏មានសក្ដានុពល ដែលកើតឡើងពីគម្រោងអភិវឌ្ឍន៍។ ជាក់ស្ដែង សហគមន៍ក្រីក្រក្នុងទីក្រុងតែងតែប្រឈមមុខទៅនឹងការអភិវឌ្ឍមិនស្មើភាពគ្នា។ ទស្សនៈវិស័យនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននេះ មានសារៈសំខាន់ណាស់ដែលចាំបាច់ត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជាឧទាហរណ៍ នៅពេលមានគម្រោងឧស្សាហកម្មថ្មី ដែលបំពុលបរិយាកាសដ៏ធ្ងន់ធ្ងរ អាចនឹងប៉ះពាល់ដល់សហគមន៍ក្រីក្រក្នុងទីក្រុងដែលមានទីតាំងនៅក្បែរនោះ។ តាមរយៈការរៀបរាប់ខាងលើ វិធានការកាត់បន្ថយសមស្រប អាចត្រូវបានបង្កើតឡើង ដូចជាការដំឡើងឧបករណ៍ត្រួតពិនិត្យការបំពុល ឬការអនុវត្តគម្រោងគំនិតផ្ដួចផ្ដើមបៃតង មានការដាំដើមឈើ ដើម្បីបន្សុទ្ធខ្យល់ជាដើម។ តាមរយៈការដោះស្រាយយ៉ាងសកម្មនូវកង្វល់ទាំងអស់នេះ សុខភាព និងគុណភាពជីវិតរបស់សហគមន៍ក្រីក្រក្នុងទីក្រុង

[១] ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក, "គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន", ២៤ កុម្ភៈ ២០២៣ ទាញយកពី៖ https://www.usaid.gov/environmental-procedures/environmental-compliance-esdm-program-cycle/principles-eia

អាចត្រូវបានការពារបានកាន់តែប្រសើរថែមទៀត។

*ទីពីរ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ធានាថាគម្រោងអភិវឌ្ឍន៍ ត្រូវស្របតាមតម្រូវការជាក់លាក់ និងផលប្រយោជន៍សហគមន៍ក្រីក្រក្នុងទីក្រុង ហេតុនេះត្រូវមានការទប់ស្កាត់លើគម្រោងដែលអាចនាំឱ្យមានការផ្លាស់ប្តូរទីតាំងលំនៅឋាន ឬគ្រោះថ្នាក់នៅក្នុងសហគមន៍ទាំងនោះ។*

ជាឧទាហរណ៍៖ នៅពេលមានគម្រោងសាងសង់ផ្លូវថ្មី ផលប៉ះពាល់ដែលអាចកើតមានដូចជា ជីវភាពរបស់ប្រជាពលរដ្ឋដែលរស់នៅ និងអ្នកធ្វើការនៅតាមបណ្តោយផ្លូវនៃគម្រោងសាងសង់អាចត្រូវបានវាយតម្លៃផងដែរ។ ដូច្នេះ គម្រោងនេះ អាចត្រូវបានរៀបចំឱ្យមានការកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន តាមរយៈការផ្តល់សំណងសមរម្យ ការរួមបញ្ចូលសំណូមពរ និងការគិតគូដល់សុខុមាលភាពរបស់សហគមន៍ក្រីក្រក្នុងទីក្រុង ដើម្បីផ្តល់អត្ថប្រយោជន៍ពិតប្រាកដដល់ប្រជាពលរដ្ឋដែលងាយរងគ្រោះក្នុងការបង្កើតគម្រោងអភិវឌ្ឍន៍ប្រកបដោយចីរភាព។



លើសពីនេះទៀត ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ជំរុញឱ្យមានការជឿទុកចិត្ត និងកិច្ចសហប្រតិបត្តិការរវាងសហគមន៍ និងអ្នកអភិវឌ្ឍន៍គម្រោង ដោយធានាថាគំនិតផ្តួចផ្តើមអភិវឌ្ឍន៍ទាំងអស់ ត្រូវគោរពតាមតម្រូវការរបស់ភាគីពាក់ព័ន្ធទាំងអស់។ ការប្រជុំជាសាធារណៈ និងការពិគ្រោះយោបល់នឹងត្រូវរៀបចំឡើងនៅក្នុងអំឡុងពេលដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលមានការចូលរួមពីសមាជិកសហគមន៍ ដើម្បីផ្តល់ឱកាសបញ្ចេញមតិអំពីកង្វល់នានា ដែលជាធាតុចូលសម្រាប់គម្រោងមុនពេលអនុវត្តន៍។

ការចូលរួមនេះ មិនត្រឹមតែកសាងទំនុកចិត្ត និងការយល់ដឹងរវាងសហគមន៍ និងអ្នកអភិវឌ្ឍន៍ប៉ុណ្ណោះទេ ការចូលរួមនេះដើរតួនាទីយ៉ាងសំខាន់ក្នុងការធានាឱ្យមតិយោបល់របស់ប្រជាសហគមន៍មានតម្លៃហើយកង្វល់របស់ពួកគេត្រូវបានដោះស្រាយ។

ចំណុចចម្បងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ផ្តោតសំខាន់ទៅការការពារគុណភាពបរិស្ថាន សុខភាពប្រជាពលរដ្ឋ និងសុខុមាលភាពរបស់សហគមន៍ដោយផ្ទាល់។ ការចូលរួមជាសាធារណៈ នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានមើលឃើញថា ជាមធ្យោបាយនៃការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងបង្កើនប្រសិទ្ធភាពនៃគម្រោង។ ទោះជាយ៉ាងណាក៏ដោយ ការចូលរួមជាសាធារណៈ ជាពិសេសសម្រាប់សហគមន៍ក្រីក្រក្នុងទីក្រុងតែងតែជួបនូវឧបសគ្គនានា។ ការផ្តល់ព័ត៌មានពីអ្នកអភិវឌ្ឍន៍ និងការទទួលបានព័ត៌មានអំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសារៈសំខាន់ចំពោះសហគមន៍ក្រីក្រក្នុងទីក្រុង ដើម្បីបញ្ចេញមតិយោបល់អំពីបញ្ហានានាទាក់ទងនឹងការអភិវឌ្ឍ។ ដូច្នេះហើយសកម្មភាពទាំងនេះមានសារៈសំខាន់ដែលអាចផ្តល់ភាពត្រឹមត្រូវដល់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលធានាបាន

នូវការរួមចំណែករបស់សហគមន៍ក្រីក្រក្នុងកិច្ចការអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ប្រសិទ្ធភាពនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជាត្រូវពឹងផ្អែកលើកត្តាជាច្រើន ដោយរួមបញ្ចូលទាំងការយល់ដឹងរបស់ប្រជាពលរដ្ឋមូលដ្ឋាន និងការចូលរួមរបស់ពួកគេ។ ជាទូទៅ ការចូលរួមជាសាធារណៈ ដើរតួនាទីយ៉ាងសំខាន់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយកង្វល់ និងមតិយោបល់របស់សហគមន៍ក្រីក្រក្នុងទីក្រុងដែលរងផលប៉ះពាល់ត្រូវបានដាក់បញ្ចូលទៅក្នុងដំណើរការនៃសេចក្តីសម្រេចចិត្ត។ ទោះជាយ៉ាងណាក៏ដោយ វិសាលភាពនៃការយល់ដឹងរបស់សហគមន៍ និងទស្សនៈរបស់ពួកគេលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនទាន់ត្រូវបានពិនិត្យច្បាស់លាស់នៅឡើយ។

ការសិក្សានេះ មានបំណងពិនិត្យមើលការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា។ តាមរយៈការឈ្វេងយល់អំពីការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍បញ្ហាប្រឈម និងចំណុចខ្វះខាត ដែលអាចរារាំងដល់ការចូលរួមប្រកបដោយប្រសិទ្ធភាពរបស់សាធារណជននៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចត្រូវបានកំណត់។ ការដោះស្រាយបញ្ហាប្រឈមទាំងនេះ មានសារៈសំខាន់ ចំពោះការធានានូវតម្លាភាព គណនេយ្យភាព និងភាពស្របច្បាប់នៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជំរុញឱ្យការអភិវឌ្ឍនៅកម្ពុជាប្រកបដោយចីរភាព។

ដោយសារពេលវេលាមានកំណត់ និងធនធានមានកម្រិតការស្រាវជ្រាវនេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ដោយផ្អែកលើហេតុផលមួយចំនួន។ ការស្រាវជ្រាវបែបគុណភាពតម្រូវឱ្យមានការយល់ដឹងទូលំទូលាយដែលមានភាពស្មុគស្មាញ តាមរយៈវិធីសាស្ត្រនានាដូចជា ការធ្វើសម្ភាសនបុគ្គលសំខាន់ៗ ការពិភាក្សាជាក្រុម និងការអង្កេត។ ជាក់ស្តែង វិធីសាស្ត្រនេះផ្តល់នូវភាពបត់បែន ដោយសំណាកមានទំហំតូច។ លើសពីនេះទៀត វិធីសាស្ត្របែបគុណភាពនេះសង្កត់ធ្ងន់លើការយល់ដឹងតាមបរិបទនៃបញ្ហាស្រាវជ្រាវ ហើយមិនសូវប្រើប្រាស់ធនធានច្រើន។ បន្ថែមពីនេះទៀត វិធីសាស្ត្រនេះ ប្រើប្រាស់ពេលវេលាតិចទាក់ទងនឹងការប្រមូលទិន្នន័យ និងការវិភាគ។ ដោយពិចារណាលើកត្តាទាំងនេះ វិធីសាស្ត្របែបគុណភាព មានលក្ខណៈសមស្រប សម្រាប់ការស្រាវជ្រាវនេះ។

គោលបំណងនៃការស្រាវជ្រាវនេះ មានបីសំខាន់ៗ គឺ៖ ទីមួយ ឈ្វេងយល់ពីកម្រិតនៃការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ទីពីរ កំណត់ឧបសគ្គដែលរារាំងការចូលរួមរបស់សហគមន៍ក្រីក្រក្នុងទីក្រុងនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងទី៣ រៀបចំអនុសាសន៍នានាដើម្បីលើកកម្ពស់សិទ្ធិចូលរួមរបស់សហគមន៍ក្រីក្រក្នុងទីក្រុងនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

លទ្ធផលស្រាវជ្រាវនេះ នឹងលើកកម្ពស់ការយល់ដឹងដែលមានស្រាប់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា ដោយបំភ្លឺលើការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុង។ លទ្ធផលស្រាវជ្រាវសំខាន់ៗទាំងនេះនឹងផ្តល់ជូនដល់អ្នកបង្កើតគោលនយោបាយម្ចាស់គម្រោង និងភាគីពាក់ព័ន្ធទាំងអស់ អំពីប្រសិទ្ធភាពនៃការចូលរួមជាសាធារណៈ នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ លើសពីនេះទៀត

ការស្រាវជ្រាវនេះ នឹងផ្តល់ការយល់ដឹងសម្រាប់ការលើកកម្ពស់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសម្របសម្រួលឱ្យប្រជាសហគមន៍ក្រីក្រក្នុងទីក្រុងចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងគម្រោងអភិវឌ្ឍន៍។ ការរៀបរាប់ខាងលើ បង្ហាញទិដ្ឋភាពទូទៅនៃខ្លឹមសារវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ក្នុងការសម្រេចបានកិច្ចអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅកម្ពុជា និងសង្កត់ធ្ងន់លើតួនាទីនៃការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដើម្បីយល់ឱ្យកាន់តែស៊ីជម្រៅនូវចំណេះដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចាំបាច់ត្រូវពិនិត្យមើលឯកសារដែលមានស្រាប់។ លទ្ធផលស្រាវជ្រាវសំខាន់ៗត្រូវបានពិនិត្យមើល និងផ្ទៀងផ្ទាត់ជាមួយបទដ្ឋានគតិយុត្តិពាក់ព័ន្ធនានា និងគោលការណ៍អន្តរជាតិ។ ដោយការវិភាគអត្ថបទដែលមានស្រាប់ ការឈ្វេងយល់កាន់តែប្រសើរអំពីស្ថានភាពបច្ចុប្បន្ននៃការចូលរួមជាសាធារណៈ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចទទួលបាន និងកំណត់ភាពខ្វះខាត ឬចំណុចសំខាន់ៗសម្រាប់ការកែលម្អ។



# ២. សហគមន៍គោលដៅ



របាយការណ៍ស្រាវជ្រាវនេះ ផ្តោតលើសហគមន៍ដែលងាយរងគ្រោះចំនួន៣ នៅក្នុងរាជធានីភ្នំពេញ ដែលប្រឈមនឹងបញ្ហានានា និងការកាន់កាប់កម្មសិទ្ធិដីធ្លី ដោយផ្អែកលើប្រវត្តិសង្ខេបរបស់សហគមន៍គោលដៅនៃអង្គការសមាគមជាងត្នោតក្នុងឆ្នាំ២០២២។[២] សហគមន៍ព្រែកតាគង់៦០ម៉ែត្រកំពុងប្រឈមនឹងការបណ្តេញចេញ ដោយសារសកម្មភាពបន្តបូមខ្សាច់ចាក់នៅទីតាំងក្បែរសហគមន៍ និងប្រព័ន្ធលូបង្ហូរទឹកដំណើរការមិនបានល្អ។ សហគមន៍ព្រែកតាគង់៣ មានបញ្ហាប្រឈមទាក់ទងនឹងការកាន់កាប់កម្មសិទ្ធិដីធ្លី និងការអភិវឌ្ឍទីក្រុងរណប។ សហគមន៍បឹងត្របែកភូមិ៤បានខិតខំព្យាយាមធ្វើឱ្យជីវភាពរស់នៅប្រសើរឡើង និងការពារសិទ្ធិកាន់កាប់ដីធ្លីរបស់ពួកគេ ទោះបីជាពួកគេកំពុងប្រឈមនឹងការគំរាមកំហែងឱ្យផ្លាស់ប្តូរទីលំនៅដោយសារ មានគម្រោងសាងសង់មួយស្ថិតនៅជិតទីតាំងសហគមន៍ ហើយពួកគេ ត្រូវបានចោទប្រកាន់ពីបទកាន់កាប់ដីសាធារណៈរបស់រដ្ឋដោយខុសច្បាប់។

## ២.១. សហគមន៍ព្រែកតាគង់៦០ម៉ែត្រ

ព្រែកតាគង់៦០ម៉ែត្រ គឺជាសហគមន៍ក្រីក្រក្នុងទីក្រុងស្ថិតនៅបឹងទំពុន ដែលប្រឈមនឹងការគំរាមកំហែងបណ្តេញចេញ ដោយសារសកម្មភាពបូមខ្សាច់ចាក់បំពេញរបស់ក្រុមហ៊ុន អេហ្សិឌគ្រុប (AZ GROUP) ក្រុមហ៊ុន អាយអ៊ិនជី ហូលឌីង (ING Holdings) និងការសាងសង់មហាវិថី ហ៊ុន សែន។ សហគមន៍នេះ មានប្រជាពលរដ្ឋរស់នៅបច្ចុប្បន្នចំនួន ២៣៨នាក់ ដែលភាគច្រើនជាជនជាតិខ្មែរ ហើយមិនមានឯកសារស្របច្បាប់កាន់កាប់កម្មសិទ្ធិដីធ្លី និងប្រព័ន្ធលូបង្ហូរទឹកដំណើរការមិនទាន់បានល្អ ដែលបណ្តាលឱ្យផ្ទះសម្បែងរបស់ប្រជាសហគមន៍មួយចំនួនរស់នៅលើទឹកស្អុយ។

បញ្ហាអាទិភាពចម្បងនៃការបណ្តេញចេញរបស់សហគមន៍នេះគឺ បញ្ហាការប្រើប្រាស់គ្រឿងញៀន និងអគ្គីភ័យ។ ជាងនេះទៅទៀត សហគមន៍នេះកំពុងប្រឈមនឹងបញ្ហាហេដ្ឋារចនាសម្ព័ន្ធ រួមមានការទទួលបានទឹក និងភ្លើង ភ្លើងបំភ្លឺផ្លូវ ផ្លូវតូចចង្អៀត លំនៅឋានទ្រុឌទ្រោម និងប្រព័ន្ធលូបង្ហូរទឹកមិនមានដំណើរល្អ។ បច្ចុប្បន្ន ការភ័យ

២ ប្រវត្តិសង្ខេបនៃសហគមន៍គោលដៅរបស់អង្គការសមាគមជាងត្នោត ក្នុងខែមករា ឆ្នាំ២០២២

ខ្លាចនៃការបណ្តេញរបស់សហគមន៍មិនត្រឹមតែព្រួយបារម្ភពីសុវត្ថិភាពដែលអាចបណ្តាលមកពីបញ្ហាខាងលើនេះទេ គឺអាចមកពីគម្រោងអភិវឌ្ឍន៍ដែលមានទីតាំងនៅជិតសហគមន៍នោះផងដែរ ខណៈពេលដែលពួកគេទទួលបានសេវាកម្មនានារួមមានសាលារៀន មណ្ឌលសុខភាព និងកម្មវិធីថែទាំសុខភាពដោយឥតគិតថ្លៃ។

សហគមន៍ចង់ផ្លាស់ប្តូរទៅតាំងទីលំនៅឋានថ្មី ប៉ុន្តែមិនទាន់ទទួលបានការឆ្លើយតបពីអាជ្ញាធរមូលដ្ឋាននៅឡើយទេ។ ពួកគេមានផែនការយកបញ្ហាដែលជាកង្វល់របស់ខ្លួនទៅខុទ្ទកាល័យនាយករដ្ឋមន្ត្រីដើម្បីរកដំណោះស្រាយ និងសំណងសមរម្យសម្រាប់ការតាំងទីលំនៅថ្មី។

ចាប់តាំងពីអគារខុនបានសាងសង់មុនឆ្នាំ ២០១៩ មក សហគមន៍ព្រែកតាគង់៦០ម៉ែត្របាននឹងកំពុងប្រឈមនឹងបញ្ហាជាច្រើន។

ជាក់ស្តែង ប្រជាពលរដ្ឋបានរស់នៅក្នុងស្ថានភាពដ៏លំបាកជារៀងរាល់ថ្ងៃ ដូចជាការបំពុលសំឡេង កកស្ទះសំរាម ធូលី កម្ទេចកម្ទីដែក ដែលធ្លាក់មកលើដំបូលផ្ទះរបស់ពួកគេ និងការបញ្ចេញសំណល់រាវមិនបានត្រឹមត្រូវពីអាគារខុនដូ។ ភាគីខាងអគាខុនដូបានទូទាត់សំណងជូនដល់ភាគីរងគ្រោះមួយចំនួនផងដែរ ប៉ុន្តែសំណងទាំងនោះមិនទាន់សមរម្យសម្រាប់ការខូចខាតនៅឡើយ ខណៈពេលដែលមនុស្សជាច្រើនផ្សេងទៀតមិនទទួលបានសំណងនោះទេ។



ផែនទីសហគមន៍ព្រែកតាគង់៣ របាយការណ៍ស្តីពីប្រវត្តិសង្ខេបនៃសហគមន៍គោលដៅរបស់អង្គការសមាគមធាងត្នោតឆ្នាំ២០២២

## ២.២. សហគមន៍ព្រែកតាគង់៣

សហគមន៍ព្រែកតាគង់៣ ដែលមានទីតាំងស្ថិតនៅក្នុងសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ រាជធានីភ្នំពេញ មានប្រជាពលរដ្ឋចំនួន២៧គ្រួសារ សរុប១៣៣នាក់ មានមុខរបរផ្សេងៗគ្នា ដោយរួមមានការងាររោងចក្រ សំណង់ និងការងាររដ្ឋ។

ទោះជាយ៉ាងណានេះក្តី អនាគតរបស់ពួកគេស្ថិតក្នុងភាពមិនច្បាស់លាស់ ដោយសារបញ្ហាទាក់ទងនឹងកម្មសិទ្ធិដីធ្លី និងការអភិវឌ្ឍទីក្រុងរណបជុំវិញបឹងទំពុន។

តាមប្រវត្តិសាស្ត្រ សហគមន៍ព្រែកតាគង់៣ស្ថិតនៅចន្លោះផ្លូវជាតិលេខ២ និងមហាវិថីសម្តេចហ៊ុន សែន ហើយហ៊ុមព័ទ្ធជុំវិញដោយបឹង ដែលបណ្តាលឱ្យមានទឹកជំនន់ធ្ងន់ធ្ងរក្នុងរដូវវស្សា។ ប្រជាពលរដ្ឋប្រឈមនឹងបញ្ហាជាច្រើន ដូចជាលទ្ធភាពទទួលបានការអប់រំមិនទាន់គ្រប់គ្រាន់ សេវាថែទាំសុខភាព និងការគ្រប់គ្រងសំណល់ឱ្យបានត្រឹមត្រូវ។ ទោះបីជាមានការលំបាកដូចជា ការជម្លះភាពក្រីក្រ ការទទួលបានកម្មសិទ្ធិដីធ្លី ការកែលម្អជីវភាពរស់នៅ និងការដោះស្រាយបញ្ហានានាផ្សេងៗទៀតយ៉ាងណាក្តី សហគមន៍នៅតែមានភាពតស៊ូ និងសម្របខ្លួនគួរឱ្យកត់សម្គាល់តាមរយៈការសម្របសម្រួលរបស់គម្រោង "រៀបចំដីធ្លីដោយឈរលើមូលដ្ឋានសិទ្ធិមនុស្ស"។

សហគមន៍បានជួបប្រទះនូវផលវិបាកសំខាន់ៗដូចជា ទីតាំងសាងសង់នៅជាប់សហគមន៍។ ជាក់ស្តែងការអភិវឌ្ឍចាប់ផ្តើមពីឆ្នាំ២០១៥ បានប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់ប្រព័ន្ធលូបង្ហូរទឹកស្អុយរបស់សហគមន៍ ដែលនាំឱ្យមានការជន់លិចតំបន់ព្រែកតាគង់៣នោះ។ ការខូចខាតប្រព័ន្ធលូបង្ហូរទឹកនេះបង្ហាញឱ្យឃើញថា នៅក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តវាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនបានធ្វើការត្រួតពិនិត្យឱ្យបានគ្រប់ជ្រុងជ្រោយ និងកង្វះការចូលរួមពីសហគមន៍ព្រែកតាគង់៣ ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍។

## ២.៣. សហគមន៍បឹងត្របែកភូម៤

សហគមន៍បឹងត្របែកភូមិ៤ មានប្រជាជន ប្រមាណ២ ៤០០នាក់ និង៦០០គ្រួសារ ឬខ្នងផ្ទះ ដែលភាគច្រើនជាជនជាតិខ្មែរ ប្រកបមុខរបរដូចជា កម្មករសំណង់ កម្មកររោងចក្រ អ្នកលក់បន្លែ និងមន្ត្រីរាជការស្ថិតនៅក្នុងខណ្ឌចំការមន រាជធានីភ្នំពេញ បាននឹងកំពុងស៊ូទ្រាំនឹងការគំរាមកំហែងរាំងការផ្លាស់ទីលំនៅចាប់តាំងពីឆ្នាំ២០០៩ មកម្ល៉េះ។ សាលារាជធានីភ្នំពេញ បានចោទប្រកាន់ប្រជាពលរដ្ឋពីបទកាន់កាប់ដីសាធារណៈរបស់រដ្ឋដោយខុសច្បាប់ ដោយសារពួកគេមិនមានភាពច្បាស់លាស់ក្នុងការកាន់កាប់កម្មសិទ្ធដីធ្លី។

បញ្ហាប្រឈម របស់សហគមន៍បឹងត្របែកភូមិ៤តាំងពីឆ្នាំ២០០៩ រួមមាន បញ្ហាលំនៅឋានទ្រុឌទ្រោម និងមិនមានឯកសារស្របច្បាប់កាន់កាប់កម្មសិទ្ធិដីធ្លី។ ទោះបីជាពួកគេ ព្យាយាមចុះបញ្ជីដីធ្លីជាប្រព័ន្ធយ៉ាងណាក្តី ក៏អាជ្ញាធរមូលដ្ឋានឆ្លើយតបជាអវិជ្ជមានឬការឆ្លើយតបនៅមានកម្រិត។ ខណៈពេលដែលសហគមន៍មានភាពងាយស្រួលក្នុងការទទួលបានសេវានានា ដូចជាសាលារៀន មណ្ឌលសុខភាព និងមានទីតាំងនៅក្បែរផ្សារក៏ដោយ ក៏សហគមន៍នេះ តែងជួបប្រទះបញ្ហាផ្សេងទៀត ដូចជាភ្លើងបំភ្លឺផ្លូវមិនគ្រប់គ្រាន់ ហេដ្ឋារចនាសម្ព័ន្ធ បញ្ហាអនាម័យ និងមានទឹកជំនន់តាមរដូវ។

ទោះបីជាសហគមន៍រស់នៅជិតទីកន្លែងចាក់សំរាម និងមានប្រភពទឹកស្អុយ ដែលអាចធ្វើឱ្យជីវភាពរស់នៅកាន់តែពិបាកក៏ដោយក៏ពួកគេតែងព្យាយាមដោះស្រាយបញ្ហាទាំងនោះ ដោយការការពារសុខភាព និងសុវត្ថិភាព។ លើសពីនេះទៀត សហគមន៍ក៏មានកង្វល់បន្ថែមទៀត ទាក់ទងនឹងបទល្មើសដូចជា ការប្រើប្រាស់គ្រឿងញៀន អំពើហឹង្សាក្នុងគ្រួសារ និងការលួចគាស់ផ្ទះសម្បែង។

តាមការរាយការណ៍ របស់ប្រជាពលរដ្ឋ នៅមូលដ្ឋានបានឱ្យដឹងថា ស្ថានភាពសហគមន៍បឹងត្របែកភូមិ៤ កាន់តែអាក្រក់ទៅៗ។ ជាក់ស្តែង មានទីតាំងជីកកកាយដីដ៏ធំមួយនៅក្បែរសហគមន៍ដែលមិនមានអ្នកដឹងពីគោលបំណងនៃការជីកកកាយនោះនៅឡើយ។ អ្វីដែលគួរឱ្យព្រួយបារម្ភគឺ ការជីកកកាយនោះបង្កគ្រោះថ្នាក់ និងភាពភ័យខ្លាចដល់ប្រជាពលរដ្ឋដែលរស់នៅក្បែរនោះដោយសារតែការជីកកាយនោះធ្វើឱ្យលំនៅឋានមួយចំនួនមានស្នាមប្រេះដែលនឹងអាចមានការដួលរលំនៅថ្ងៃមុខៗ។

អ្វីដែលគួរឱ្យសោកស្តាយនោះគឺ អាជ្ញាធរមូលដ្ឋានមានភាពព្រងើយកន្តើយក្នុងការផ្តល់ព័ត៌មានជូនសហគមន៍ទាក់ទងនឹងទីតាំងជីកកកាយដ៏គ្រោះថ្នាក់ដែលនៅក្បែរនោះ។ ដូចច្នេះ សហគមន៍បឹងត្របែកភូមិ៤ មានភាពលំបាកក្នុងការទទួលបានព័ត៌មានសំខាន់ៗអំពីផលប៉ះពាល់ចំពោះពួកគេ។



# ៣. ការពិនិត្យខ្លឹមសារអត្ថបទ



## ៣.១. ទិដ្ឋភាពទូទៅនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាដំណើរការមួយដែលវាយតម្លៃកម្រិតសក្តានុពលនៃគម្រោងអភិវឌ្ឍន៍មុនពេលត្រូវបានអនុវត្តន៍ ហើយដំណើរការនេះ វាយតម្លៃផលប៉ះពាល់នានាលើបរិស្ថាន។

គោលបំណងសំខាន់ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីជូនជាដំណឹងដល់អ្នកពាក់ព័ន្ធនានា ដូចជាអ្នកធ្វើសេចក្តីសម្រេចចិត្ត និងសាធារណជនអំពីបញ្ហាប៉ះពាល់បរិស្ថានដែលអាចនឹងកើតមាននៅក្នុងការអនុវត្តគម្រោង និងធានាថាផលប៉ះពាល់ទាំងអស់អាចត្រូវបានកាត់បន្ថយ ឬគ្រប់គ្រងបាន។[៣]

នៅក្នុងប្រទេសកម្ពុជា ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានគ្រប់គ្រងដោយច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦[៤] អនុក្រឹត្យលេខ៧២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩[៥] ប្រកាសលេខ០២១ ស្តីពីចំណាត់ថ្នាក់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំ១៩៩៩[៦] និងរាជក្រមលេខ០៦២៣/០០៧ ស្តីពីក្រុមបរិស្ថាន និងធនធានធម្មជាតិ។[៧] ឧបករណ៍ច្បាប់ទាំងនេះ ផ្តល់នូវមូលដ្ឋានសម្រាប់ការអនុវត្តគម្រោងអភិវឌ្ឍន៍នានា ដែលតម្រូវឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមុនពេលគម្រោងទាំងនោះត្រូវបានយកទៅអនុវត្តន៍។ ម្ចាស់គម្រោងត្រូវធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីបង្ហាញជូននូវលទ្ធផលនៃការសិក្សានោះជូនដល់ក្រសួងបរិស្ថានដើម្បីពិនិត្យ និងអនុម័ត។

ជាងនេះទៅទៀត នៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព គោលការណ៍មិនទុកនរណាម្នាក់ចោល បានសំដៅលើសហគមន៍ក្រីក្រក្នុងទីក្រុងដែលងាយរងគ្រោះ តែងតែទទួលផលប៉ះពាល់ធ្ងន់ធ្ងរនានា ពីផលប៉ះពាល់បរិស្ថាន។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានមានសារៈសំខាន់ណាស់

---

៣ ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក, "គោលការណ៍នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន", ២៤ កុម្ភៈ ២០២៣ ទាញយកពី៖ https://www.usaid.gov/environmental-procedures/environmental-compliance-esdm-program-cycle/principles-eia
៤ ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិឆ្នាំ១៩៩៦
៥ អនុក្រឹត្យលេខ៧២ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឆ្នាំ១៩៩៩
៦ ប្រកាសលេខ០២១ស្តីពីចំណាត់ថ្នាក់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់គម្រោងអភិវឌ្ឍន៍ឆ្នាំ១៩៩៩
៧ ព្រះរាជក្រមលេខ០៦២៣/០០៧ ស្តីពីក្រុមបរិស្ថាន និងធនធានធម្មជាតិ

សម្រាប់ការការពារសហគមន៍ទាំងនេះ ដោយកំណត់ និងកាត់បន្ថយហានិភ័យ ដូចជាការការបំពុលសំឡេង ការបំពុលខ្យល់ ការបំពុលទឹក និងទឹកជន់លិច។

## ៣.២. ក្របខណ្ឌច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជាឧបករណ៍ដ៏សំខាន់មួយ សម្រាប់វាយតម្លៃការអនុវត្តនៃគម្រោងអភិវឌ្ឍន៍។ ឧបករណ៍ច្បាប់ និងបទប្បញ្ញត្តិនានា នៅកម្ពុជាមួយចំនួនរួមទាំងថ្នាក់ជាតិ និងថ្នាក់អន្តរជាតិបានគ្រប់គ្រងលើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលរួមបញ្ចូលទាំងរដ្ឋធម្មនុញ្ញកម្ពុជា ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដូចជាអនុក្រឹត្យលេខ៧២ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រកាសលេខ ០២១ស្តីពីចំណាត់ថ្នាក់វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ ព្រះរាជក្រមលេខ០៦២៣/០០៧ ស្តីពីក្រមបរិស្ថាន និងធនធានធម្មជាតិ និងគោលការណ៍មិនទុកនណាម្នាក់ចោលដែលបានចែងក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។ ក្របខណ្ឌនៃច្បាប់ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់កម្ពុជា គឺជាការភ្ជាប់ទំនាក់ទំនងគ្នារវាងឧបករណ៍ច្បាប់ជាច្រើន ដែលរៀបបានចំឡើងដើម្បីបង្កើន និងលើកកម្ពស់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រកបដោយប្រសិទ្ធភាព និងប្រសិទ្ធផល។

រដ្ឋធម្មនុញ្ញកម្ពុជា ដែលបានអនុម័តកាលពីឆ្នាំ១៩៩៣ ទទួលស្គាល់កាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចការពារធនធានធម្មជាតិផ្ទាល់ខ្លួន។ មាត្រា៥៩ នៃរដ្ឋធម្មនុញ្ញកម្ពុជាចែងថា៖

> *"រដ្ឋត្រូវរក្សាការពារបរិស្ថាន និងតុល្យភាពនៃភោគទ្រព្យធម្មជាតិ ហើយត្រូវចាត់ចែងឱ្យមានផែនការច្បាស់លាស់ ក្នុងការគ្រប់គ្រងមានជាអាទិ៍ ដីធ្លី ទឹក អាកាស ខ្យល់ ភូគព្ភសាស្ត្រ ប្រព័ន្ធអេកូឡូស៊ី រ៉ែ ថាមពល ប្រេងកាត និងឧស្ម័ន ថ្ម និងខ្សាច់ ត្បូងថ្ម ព្រៃឈើ និងអនុផលព្រៃឈើ សត្វព្រៃ មច្ឆាជាតិ និងធនធានជលផល"*។[៨]

បទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញ ផ្តល់មូលដ្ឋានច្បាប់សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា និងជាការចង្អុលបង្ហាញនូវខ្លឹមសារដែលរួមបញ្ចូលកត្តាបរិស្ថាន ទៅក្នុងដំណើរការរៀបចំផែនការអភិវឌ្ឍ។



ច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលបានអនុម័តកាលពីឆ្នាំ១៩៩៦ បានបញ្ជាក់យ៉ាងច្បាស់ពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា។ ជំពូកទី៣បង្ហាញអំពីច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិដែលមានមាត្រាសំខាន់ៗចំនួនពីរ គឺមាត្រា៦ និងមាត្រា៧ ដែលផ្តោតសំខាន់លើជំហាននៃការធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

៨ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

ដែលត្រូវបានពិនិត្យ និងពិចារណាដោយក្រសួងបរិស្ថាន លើគ្រប់គម្រោងរបស់រដ្ឋ ឯកជន និងភាពចាំបាច់នានា។ ច្បាប់នេះ ក៏បានកំណត់នៅក្នុងអនុក្រឹត្យលេខ៧២ ស្តីពីនីតិវិធីអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលនឹងត្រូវបានកំណត់ដោយអនុក្រឹត្យជាបន្តបន្ទាប់ តាមរយៈការស្នើដោយក្រសួងបរិស្ថាន។

អនុក្រឹត្យលេខ៧២ ស្តីពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលចេញកាលពីឆ្នាំ១៩៩៩ ចែងអំពីនីតិវិធីលម្អិតសម្រាប់ការអនុវត្តការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គ្រប់គម្រោងអភិវឌ្ឍន៍របស់រដ្ឋ ឬឯកជននៅកម្ពុជា។ មាត្រា១នៃអនុក្រឹត្យនេះ ចែងអំពីគោលបំណង ដែលបានបញ្ជាក់អំពី ការលើកកម្ពស់ការចូលរួមរបស់សាធារណជនក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយកង្វល់របស់ពួកគេត្រូវបានដឹងឮ និងដោះស្រាយ។ ជាងនេះទៅទៀតអនុក្រឹត្យនេះបង្ហាញអំពីការទទួលខុសត្រូវលើដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានរបស់ម្ចាស់គម្រោង អ្នកពិគ្រោះយោបល់លើការវាយតម្លៃនេះ និងស្ថាប័នរាជរដ្ឋាភិបាល រួមមាន ក្រសួងបរិស្ថាន ក្រសួងពាក់ព័ន្ធនានា។ អនុក្រឹត្យនេះ ក៏មានគោលការណ៍ណែនាំ ស្តីពីដំណាក់កាលជាបន្តបន្ទាប់នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ គោលការណ៍ណែនាំនេះ រួមមាន ការពិនិត្យមើល និងកំណត់វិសាលភាពនៃគម្រោង ការរៀបចំរបាយការណ៍ផែនការគ្រប់គ្រងបរិស្ថាន ការត្រួតពិនិត្យ និងវាយតម្លៃរបាយការណ៍ ការកំណត់ការយល់ព្រម ឬការបដិសេធចំពោះរបាយការណ៍នេះ ការសាងសង់ និងប្រតិបត្តិការជាបន្តបន្ទាប់នៃគម្រោង និងវិធានការត្រួតពិនិត្យអនុវត្ត និងពង្រឹងជាបន្ត។ លើសពីនេះទៀត អនុក្រឹត្យនេះ បានបញ្ជាក់យ៉ាងច្បាស់នូវមាត្រាចំនួន៣នៅក្នុងជំពូកទី៧ ដូចជាមាត្រា២៩ មាត្រា៣០ និងមាត្រា៣១ អំពីទោសបញ្ញត្តិ ដែលម្ចាស់គម្រោងត្រូវស្ថិតក្រោមដែនអនុវត្តន៍នេះ ប្រសិនបើមានការប្រព្រឹត្តិខុសក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

អនុក្រឹត្យនេះផ្តោតសំខាន់លើមាត្រា២០ មាត្រា២១ មាត្រា២២ មាត្រា២៣ និងមាត្រា២៥ ដូចមានចែងក្នុងជំពូកទី៥នៃច្បាប់ស្តីពីការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ដែលពិភាក្សាលើសេចក្តីលម្អិតនៃទោសបញ្ញត្តិទាំងនេះ។ ទោះបីនៅក្នុងអនុក្រឹត្យនេះ មានការលើកកម្ពស់ការចូលរួមជាសាធារណៈក៏ដោយ ក៏នៅមិនទាន់បានចែងលម្អិតអំពីលក្ខខណ្ឌជាក់លាក់នៅឡើយ។ ម្យ៉ាងវិញទៀត អនុក្រឹត្យនេះ ក៏មានភាពខ្វះខាតលើបទប្បញ្ញត្តិនានា ក្នុងការពិចារណាលើជម្រើស ឬការបង្ហាញព័ត៌មាន។[៩]

អនុក្រឹត្យនេះត្រូវបានបញ្ជាក់បន្ថែមទៀតនៅក្នុងប្រកាសពាក់ព័ន្ធនានា ដូចជា ប្រកាសលេខ៣៧៦ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ[១០]



៩ ម៉េតធូ ប៊ឺត (Matthew Baird), ច្បាប់ស្តីពីបរិស្ថានបច្ចុប្បន្ន និងទស្សនៈអនាគតនៅកម្ពុជា, ជំពូកចែងពី ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា, ច្បាប់និងការអនុវត្ត, ខែមីនា ឆ្នាំ២០២០ ទំព័រទី៤៣–៥២
១០ ប្រកាលលេខ៣៧៦ស្តីពីគោលការណ៍ទូទៅ សម្រាប់រៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ

ប្រកាសលេខ៣៧៦ ចេញកាលពីឆ្នាំ២០០៩ ដែលមានចំណងជើងថា៖ *"គោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ"*

បានចែងលម្អិតអំពីដំណើរការចូលរួមជាសាធារណៈ ដូចមានក្នុងឧបសម្ព័ន្ធនៃជំពូកទី៥។ ប្រកាសនេះចែងថា ម្ចាស់គម្រោងត្រូវតែបង្ហាញព័ត៌មាននៃគម្រោងអភិវឌ្ឍន៍របស់ពួកគេទៅអាជ្ញាធរមូលដ្ឋាន និងសហគមន៍។ ម្ចាស់គម្រោង ត្រូវតែពិគ្រោះយោបល់ និងទទួលមតិយោបល់ ឬព័ត៌មានត្រឡប់ពីសំណាក់អង្គការមិនមែនរដ្ឋាភិបាល ក្រសួងពាក់ព័ន្ធ និងសហគមន៍មូលដ្ឋានផងដែរ។

ប្រកាសលេខ០២១ ត្រូវបានចេញផ្សាយដោយក្រសួងបរិស្ថាន កាលពីឆ្នាំ២០២០ ដែលមានចំណងជើងថា "ចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍" ដែលបញ្ជាក់បន្ថែមលើអនុក្រឹត្យលេខ៧២។ ប្រកាសនេះ ចែងអំពីគោលការណ៍ណែនាំ និងធ្វើបច្ចុប្បន្នភាពបន្ថែមទៀតលើដំណើរការនៃការប៉ាន់ប្រមាណតម្លៃ និងការវាយតម្លៃប្រភេទគម្រោងអភិវឌ្ឍន៍ថា តើវាតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ ឬដំបូង។ ប្រកាសលេខ០២១ រួមបញ្ចូលតារាងចំណាត់ថ្នាក់វាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ដែលចែងយ៉ាងជាក់លាក់ថា អាគារគ្រប់ប្រភេទ រួមមានសំណង់អាគារការិយាល័យ សំណង់អាគារពហុវិស័យ សំណង់អាគារពាណិជ្ជកម្ម សំណង់ខុនដូ សំណង់អាគារសហគមន៍មានទ្វាររបង សំណង់អាគារផ្ទះល្វែង សំណង់វីឡា សំណង់ផ្សារទំនើប និងសំណង់អាគារផ្សេងៗទៀត តម្រូវធ្វើកិច្ចសន្យាការពារបរិស្ថាន ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ។ ករណីដីមានទំហំចន្លោះពី៣ ០០០ម៉ែត្រការ៉េ ទៅ១៥ ០០០ម៉ែត្រការ៉េ តម្រូវឱ្យធ្វើកិច្ចសន្យាការពារបរិស្ថាន។ ដីមានទំហំចន្លោះពី១៥ ០០០ម៉ែត្រការ៉េ ទៅ៤៥ ០០០ម៉ែត្រការ៉េ តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង។ ដីមានទំហំធំជាង៤៥ ០០០ម៉ែត្រការ៉េ តម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

នៅកម្រិតអន្តរជាតិ គោលការណ៍មិនទុកចោលនរណាម្នាក់ចោល គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់មួយនៅក្នុងគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។[១១] គោលការណ៍នេះ សំដៅលើតម្រូវការរបស់ជនទាំងឡាយណាដែលមានភាពខ្វះខាត និងងាយរងគ្រោះ។ ចំណុចនេះរាប់បញ្ចូលទាំងប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង ដែលជាញឹកញាប់ងាយរងគ្រោះធ្ងន់ធ្ងរពីផលប៉ះពាល់បរិស្ថាន។ ក្នុងចំណោមប្រជាពលរដ្ឋទាំងអស់ក្នុងរាជធានីភ្នំពេញមានតែប្រជាពលរដ្ឋដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រនោះទេ ដែលកំពុងនឹងប្រឈមនឹងបញ្ហានេះ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានគឺជាឧបករណ៍សំខាន់មួយដើម្បីធានាឱ្យមានការប្រកាន់ខ្ជាប់នូវគោលការណ៍នានា ក្នុងគម្រោងអភិវឌ្ឍន៍។ ខ្លឹមសារនៃគោលការណ៍នេះមានលក្ខណៈគ្រប់ជ្រុងជ្រោយលុះត្រាតែត្រូវបានគិតគូរពិចារណាដល់សហគមន៍ក្រីក្រក្នុងទីក្រុងដែល ងាយរងគ្រោះធ្ងន់ធ្ងរពីផលប៉ះពាល់បរិស្ថាន ដូចជាទីតាំងនៅតំបន់លិចទឹក ស្ថិតនៅជិតតំបន់ឧស្សាហកម្ម និងទីតាំងដីដែលមានការបំពុល។ ការរៀបចំដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចការពារសហគមន៍ក្រីក្រក្នុងទីក្រុងបានពីផល

១១ គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ៖ គោលការណ៍មិនទុកចោលនរណាម្នាក់ចោល, ទាញយកពី៖ https://unsdg.un.org2030-agenda/universal-values/leave-no-one-behind

ប៉ះពាល់បរិស្ថានដែលកើតចេញពីគម្រោងអភិវឌ្ឍន៍។ ជាឧទាហរណ៍ បញ្ហាដែលទាក់ទងនឹងការបំពុលបរិយាកាស ឬការបំពុលទឹកអាចត្រូវបានបង្ហាញក្នុងកំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ អាស្រ័យហេតុនេះ ការកែសម្រួលគម្រោង ដូចជាការដាក់បញ្ចូលបរិក្ខារត្រួតពិនិត្យការបំពុលត្រូវបានធ្វើឡើងដើម្បីកាត់បន្ថយហានិភ័យ។



## ៣.៣. ការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

សន្និសីទពិភពលោក ស្តីពីកំណែទម្រង់ដីកសិកម្ម និងអភិវឌ្ឍន៍ជនបទ ដែលបានធ្វើឡើងកាលពីឆ្នាំ១៩៧៩ បានសន្និដ្ឋានថា ការចូលរួមរបស់ប្រជាពលរដ្ឋនៅក្នុងស្ថាប័ន និងប្រព័ន្ធដែលគ្រប់គ្រងជីវភាពរស់នៅរបស់ពួកគេគឺជាសិទ្ធិមនុស្សជាមូលដ្ឋាន និងមានសារៈសំខាន់សម្រាប់ការផ្លាស់ប្តូរអំណាចឡើងវិញ ដើម្បីគាំទ្រក្រុមងាយរងគ្រោះក្នុងការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។[១២] ការចូលរួមជាសាធារណៈមានសារៈសំខាន់ណាស់ ដោយសារការចូលរួមនេះជាគន្លឹះសម្រាប់ការសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព។ ទោះបីជាការអភិវឌ្ឍកំពុងមានភាពរីកចម្រើនក៏ដោយ ក៏ការអភិវឌ្ឍនោះនឹងមិនមានការលើកកម្ពស់សមធម៌ និងយុត្តិធម៌ ប្រសិនបើគ្មានការគិតគូរពីកង្វល់របស់សាធារណជនដែលងាយរងគ្រោះពីការអភិវឌ្ឍនោះទេ។ ដូច្នេះ ការចូលរួមជាសាធារណៈបានក្លាយជាចំណុចដ៏សំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

ដោយផ្អែកលើ ប្រកាសលេខ៣៧៦ ស្តីពីគោលការណ៍ណែនាំទូទៅក្នុងការធ្វើរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង និងពេញលេញ បានកំណត់ការចូលរួមជាសាធារណៈ ដោយសំដៅលើការចូលរួមពីភាគីពាក់ព័ន្ធនានា ដែលចូលរួមក្នុងគម្រោងអភិវឌ្ឍន៍ ដូចជាក្រសួង អាជ្ញាធរមូលដ្ឋាន នាយកដ្ឋានពាក់ព័ន្ធ ម្ចាស់គម្រោង ក្រុមហ៊ុនពិគ្រោះយោបល់ តំណាងជនរងគ្រោះ និងអង្គការមិនមែនរដ្ឋាភិបាល ដែលកំពុងធ្វើការនៅក្នុងវិស័យគម្រោងទាំងនេះ។

លើសពីនេះទៀត យោងតាមព្រះរាជក្រមលេខ០៦២៣/០០៧ស្តីពីក្រមបរិស្ថាន និងធនធានធម្មជាតិបានបញ្ជាក់ឱ្យដឹងផងដែរ អំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដោយផ្អែកលើគន្ថីទី៥ មាតិកាទី២ ជំពូកទី១ មាត្រា៦៤៩ នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលគោលបំណងនៃមាត្រានេះ ដើម្បីធានាប្រសិទ្ធភាពនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ក្រមនេះ ចែងថា ការចូលរួមជាសាធារណៈត្រូវដាក់បញ្ចូលទៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដើម្បីការពារ ឬកាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមានលើបរិស្ថាន និងសង្គមដែលបណ្តាលមកពីគម្រោងវិនិយោគសាធារណៈ និងឯកជន។[១៣]

---

១២ អង្គការស្បៀង និងកសិកម្ម, សេចក្តីណែនាំ, ទាញយកពី៖ https://www.fao.org/3/T1955E/t1955e02.htm
១៣ ព្រះរាជក្រមលេខ នស/រកម/០៦២៣/០០៧ ស្តីពីក្រមបរិស្ថាននិងធនធានធម្មជាតិ

គោលបំណងនៃការចូលរួម ជាសាធារណៈ នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ត្រូវបានកំណត់យ៉ាងច្បាស់ ដូចមានចែងនៅក្នុង គន្លីទី២ មាតិកាទី២ ជំពូកទី៥ មាត្រា១២៧ នៃ សេចក្តីព្រាងក្រមបរិស្ថាន និងធនធានធម្មជាតិ កំណែទី១១ ដែលត្រូវធានាថា អ្នកដែលទទួល រងហេតុប៉ះពាល់និងអ្នកពាក់ព័ន្ធ បានទទួលដំណឹង គ្រប់ជ្រុងជ្រោយអំពីគម្រោង។

លើសពីនេះទៀតពួកគេក៏មានសិទ្ធិមានឱកាស ចូលរួមក្នុងការពិភាក្សា និងសកម្មភាពនានាទាក់ ទងនឹងគម្រោងនេះផងដែរ។ បន្ថែមពីនេះទៀត ពួកគេ មានសិទ្ធិ មានឱកាសសង្កេតមើលគ្រប់ សកម្មភាពទាំងអស់របស់គម្រោង។ ម្ចាស់គម្រោង ចាំបាច់ដាក់បញ្ចូលការចូលរួមពីអាជ្ញាធរមូលដ្ឋាន សង្គមស៊ីវិល តំណាងសហគមន៍ និងជនរងគ្រោះ ផងដែរ។ ១. កំណត់សារៈសំខាន់នៃបរិស្ថាន សេដ្ឋកិច្ច សង្គមកិច្ច និងទិដ្ឋភាពវប្បធម៌ ២. ប្រមូលផ្តុំកង្វល់ និងមតិយោបល់ទាំងអស់ ហើយបញ្ចូលវាទៅក្នុង ដំណើរការនេះ និង៣. ពិចារណាជម្រើស និង យន្តការដែលកាត់បន្ថយផលវិបាកណា មួយ។ ការចូលរួមជាសាធារណៈ គឺជាចំណុច សំខាន់មួយសម្រាប់ការវាយតម្លៃហេតុប៉ះពាល់ បរិស្ថាន ព្រោះអាចផ្តល់ឱកាសសម្រាប់ភាគី ពាក់ព័ន្ធ ដើម្បីចូលរួមក្នុងដំណើរការធ្វើសេចក្តី សម្រេចចិត្ត។ ជាឧទាហរណ៍ ១. ពង្រឹងគុណភាពនៃ ការសម្រេចចិត្ត៖ ដោយដាក់បញ្ចូលទាំងសហគមន៍ មូលដ្ឋាន អាជ្ញាធរមូលដ្ឋាន ជនងាយរងគ្រោះ និង ភាគីពាក់ព័ន្ធទាំងអស់ ដើម្បីម្ចាស់គម្រោង និង អ្នកធ្វើការសម្រេចចិត្ត អាចទទួលបានព័ត៌មាន គ្រប់ជ្រុងជ្រោយទាក់ទងនឹងហានិភ័យ និងផល វិបាក។ ២) ការសម្រេចចិត្តពីគ្រប់ភាគីពាក់ព័ន្ធ៖ ដោយរួមបញ្ចូលទាំងភាគីពាក់ព័ន្ធទាំងអស់ ដើម្បី ឱ្យអ្នកធ្វើការសម្រេចចិត្តមានការប្រុងប្រយ័ត្នខ្ពស់ និងមានភាពត្រឹមត្រូវចំពោះការសម្រេចចិត្តរបស់ ពួកគេ ព្រោះកង្វល់ និងមតិយោបល់របស់ភាគី ពាក់ព័ន្ធទាំងអស់ត្រូវបានទទួលយក និងដោះស្រាយ តាមសមគួរ។ ៣.ពង្រឹងដំណើរការការអនុវត្ត៖ ដោយមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធ ដំណើរការ អនុវត្តន៍នេះ អាចដំណើរការទៅដោយរលូន ដោយ សារពួកគេដឹងច្បាស់អំពីតួនាទី និងការទទួលខុស ត្រូវរបស់ពួកគេ។ ៤. កាត់បន្ថយពាក្យបណ្តឹង និង ជម្លោះ៖ ដោយយកចិត្តទុកដាក់លើគ្រប់កង្វល់ ទាំងអស់ ដោយអាចកាត់បន្ថយជម្លោះ និងពាក្យ បណ្តឹង ដែលត្រូវចំណាយពេល និងលុយកាក់ ច្រើននោះទេ។ ៥) ការរៀនសូត្រ និងការអប់រំ សង្គម៖ តាមការចូលរួមក្នុងដំណើរការធ្វើសេចក្តី សម្រេចចិត្តទាំងនេះ អាចបង្រៀនមនុស្សអំពីរបៀប គ្រប់គ្រងខ្លួនឯងនៅក្នុងសង្គមប្រជាធិបតេយ្យ។

## ៣.៤. បញ្ហាប្រឈមសំខាន់នៃការចូលរួម ជាសាធារណៈនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា

ដោយបានពិនិត្យមើលឯកសារការងារ ដែល រៀបចំដោយវិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល អំពីក្របខណ្ឌច្បាប់ និងបញ្ហាប្រឈមនៃការវាយ តម្លៃហេតុប៉ះពាល់បរិស្ថាននៅបណ្តាប្រទេសអាស៊ី ជាច្រើន ឃើញថា មានបញ្ហាប្រឈមច្រើនទាក់ទង នឹងការចូលរួមជាសាធារណៈនៅក្នុងដំណើរការ វាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា។[១៤]

១៤ វិទ្យាស្ថានយុទ្ធសាស្ត្របរិស្ថានសកល, អ្នកនិពន្ធ៖ Daisuke SANO, Ikuko MATSUMOTO, Akiko URAGO, Yasuo TAKAHASHI, Naoko GENJIDA, ពង្រឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅអាស៊ី, ឯកសារពិភាក្សា, ឯកសារការងារដែលរៀបចំ សម្រាប់សន្និសីទវាយតម្លៃផលប៉ះពាល់បរិស្ថានអាស៊ីឆ្នាំ២០១៦ នៅទីក្រុងណាហ្គូយ៉ា ប្រទេសជប៉ុន, ឧសភា ២០១៦

ជាដំបូង មានការចង្អុលបង្ហាញទិដ្ឋភាពទូទៅចំនួនពីរ ដោយមិនមានចែងច្បាស់លាស់នៅក្នុងអនុក្រឹត្យអំពីការកំណត់ពេលវេលា និងវិសាលភាពដែលសាធារណជនអាចចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននោះ។ ការកំណត់ពេលវេលា សំដៅទៅដល់ដំណាក់កាលជាក់លាក់នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលជាពេលវេលាសាកសមចូលរួមរបស់សាធារណៈជន។ ចំណុចនេះ អាចរួមបញ្ចូលទាំងឱកាសសម្រាប់ការពិគ្រោះយោបល់ជាសាធារណៈ កិច្ចប្រជុំ ឬរយៈពេលនៃការទទួលយោបល់ជាសាធារណៈ។ ម្យ៉ាងវិញទៀត អនុក្រឹត្យនេះមិនបានគូសបញ្ជាក់ក្របខណ្ឌច្បាស់លាស់សម្រាប់សកម្មភាពទាំងអស់ ដោយបើកឱកាសដល់ការបកស្រាយ និងលទ្ធភាពនាំឱ្យមានភាពមិនស្របគ្នាក្នុងការអនុវត្តជាក់ស្តែង។ រីឯវិសាលភាព សំដៅទៅដល់កម្រិតចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយអនុក្រឹត្យនេះក៏មិនបានចែងក្របខណ្ឌច្បាស់លាស់ទាក់ទងនឹងកម្រិតចូលរួមជាសាធារណៈដែរ។



លើកទីពីរ ទោះបីមានការគិតទុកជាមុនថាសាធារណជននឹងទទួលបានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយក៏ដោយ ក៏អនុក្រឹត្យនេះ មិនបានបញ្ជាក់ថារបាយការណ៍នេះនឹងត្រូវបានចែកជូនសាធារណជននោះទេ។ របាយការណ៍ទាំងអស់ ត្រូវតែមានព័ត៌មានសំខាន់អំពីបញ្ហាបរិស្ថានដែលមានសក្តានុពលរបស់គម្រោងដែលកំពុងស្ថិតក្រោមការវាយតម្លៃ។

ដោយហេតុនេះរបាយការណ៍បានចង្អុលបង្ហាញពីកង្វះនៃតម្លាភាព និងគណនេយ្យភាពចំពោះសាធារណជន ដែលទទួលបានរបាយការណ៍វាយតម្លៃចុងក្រោយ។ ម្យ៉ាងវិញទៀត របាយការណ៍ចុងក្រោយត្រូវផ្តល់ជូនសាធារណជន ហើយសេចក្តីព្រាងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវចែកជូនអង្គការមិនមែនរដ្ឋាភិបាល ដើម្បីមានយោបល់ និងព័ត៌មានត្រឡប់។

ទោះបីមានក្របខណ្ឌមិនច្បាស់លាស់សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងអនុក្រឹត្យនេះ ក៏ដោយ ក៏ក្រសួងបរិស្ថានពិតជាបានផ្តល់សេចក្តីណែនាំផ្ទាល់មាត់អំពីការចូលរួមជាសាធារណៈ នៅក្នុងដំណាក់កាលអនុវត្តគម្រោង ដែលស្ថិតនៅក្នុងដំណាក់កាលពិនិត្យមើល និងវាយតម្លៃគម្រោ និងក្រោយពេលបានវាយតម្លៃដោះស្រាយផលវិបាកមានសក្តានុពលចុងក្រោយ និងស្វែងរកវិធានការកាត់បន្ថយ ទោះបីមានឯកសារសេចក្តីណែនាំសរសេរជាលាយលក្ខណ៍អក្សរ ជាផ្លូវការក៏ដោយ។

### ៣.៥. ការចូលរួមជាសាធារណៈនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៃគម្រោងវារីអគ្គិសនីនៅកម្ពុជា

យោងតាមឯកសារលោក ហាន សៀ (HanXia) ស្តីពីតួនាទី និងបញ្ហានៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់ការគ្រប់គ្រងគម្រោងវារីអគ្គិសនីនៅកម្ពុជាបានបង្ហាញភស្តុតាងថា ការចូលរួមជា

សាធារណៈនៅក្នុងគម្រោងវារីអគ្គីសនីនៅកម្ពុជា នៅមានកម្រិតដោយសារកត្តាជាច្រើនដែលនឹងត្រូវបានបង្ហាញនៅក្នុងរបាយការណ៍នេះ។[១៥] ហេតុផលសំខាន់មួយ គឺកង្វះមធ្យោបាយដែលមានប្រសិទ្ធភាពសម្រាប់សាធារណជនក្នុងការទទួលបានព័ត៌មានអំពីគម្រោង ដោយគ្មានការបើកទូលំទូលាយក្នុងការចូលទៅទាញយកឯកសារពីគេហទំព័រ ដូចជារបាយការណ៍របស់វិទ្យាស្ថានវិស្វកម្មអគ្គិសនី ឬរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានជាដើម។ បន្ថែមពីនេះទៀត មន្ត្រីទទួលខុសត្រូវផ្នែកផ្តល់ព័ត៌មាន ជារឿយៗបង្ហាញភាពស្ទាក់ស្ទើរក្នុងការផ្តល់ព័ត៌មានដោយអះអាងថា ក្រសួងបរិស្ថានមិនទទួលខុសត្រូវ ហើយដំណើរការការិយាធិបតេយ្យ(ការងាររដ្ឋបាល)មានភាពស្មុគស្មាញក្នុងការទទួលបានឯកសារ ដែលទាំងនេះជាការរារាំងដល់ការចូលរួមជាសាធារណៈ។ ម្យ៉ាងវិញទៀត ការយល់ដឹងរបស់សហគមន៍ទាក់ទងទៅនឹងសិទ្ធិចូលរួមរបស់ពួកគេនៅក្នុងដំណើរការពិគ្រោះយោបល់ជាសាធារណៈ និងឱកាសនានាសម្រាប់ការពិគ្រោះយោបល់ គឺនៅមានកម្រិតនៅឡើយ។ វិសមភាពសង្គមដូចជា ការរើសអើងយេនឌ័រ ការបន្ថែមការរឹតត្បិតដល់ការប្រមូលផ្តុំមួយចំនួនរួមមានក្រុមស្ត្រីជាដើម។ ភាពស្មុគស្មាញ និងលទ្ធភាពទទួលព័ត៌មានអំពីគម្រោង ក៏បានរារាំងដល់ការចូលរួមជាសាធារណៈផងដែរ ដោយសារការយល់ដឹងអំពីភាសាបច្ចេកទេសនៅមានកម្រិត និងខ្លឹមសារមានភាពស្មុគស្មាញ។ បទពិសោធអវិជ្ជមានមុនៗដូចជាគម្រោងទំនប់វារីអគ្គីសនីកំចាយ ដែលខ្វះការចូលរួមជាសាធារណៈបានរួមចំណែកធ្វើឱ្យបាត់បង់ទំនុកចិត្តក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយទំនុកចិត្តក្នុងការចូលរួមជាសាធារណៈត្រូវបានធ្លាក់ចុះ។ កត្តាទាំងអស់នេះរួមចំណែកធ្វើឱ្យការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជានៅមានកម្រិតនៅមានឡើយ។

## ៣.៦. សិទ្ធិទទួលបានព័ត៌មាន ជាសិទ្ធិទទួលបានសុខុមាលភាពនៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

យោងតាមឯកសារលោក កៃ ម៉ាធីសិន (Kay Mathiesen) ស្តីពី"ការទទួលបានព័ត៌មានជាសិទ្ធិមនុស្ស" បានលើកឡើងថា សិទ្ធិទទួលបានព័ត៌មានមិនត្រឹមតែត្រូវបានចាត់ទុកថាជាសិទ្ធិមានសេរីភាពប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជាសិទ្ធិទទួលបានសុខុមាលភាពផងដែរ។[១៦] សិទ្ធិទទួលបានសុខុមាលភាព តម្រូវឱ្យមានសកម្មភាពជាក់លាក់ដើម្បីបំពេញសិទ្ធិស្មើគ្នា។ សិទ្ធិទទួលបាន "សុខុមាលភាព" គ្របដណ្តប់លើការផ្តល់ប្រយោជន៍សេវាកម្ម ឬការគាំទ្រជាក់លាក់ដល់អ្នកគ្រប់គ្នាដោយមានការធានានូវសុខុមាលភាពទូទៅ។ ដោយមានសិទ្ធិទទួលបានព័ត៌មាន សហគមន៍ក្រីក្រក្នុងទីក្រុងជាច្រើនអាចទទួលបានព័ត៌មានដោយស្របច្បាប់ទាក់ទងនឹងគម្រោងអភិវឌ្ឍន៍ដែលកំពុងត្រូវបានអនុវត្តនៅជុំវិញសហគមន៍របស់ពួកគេ។ សិទ្ធិនេះ ផ្តល់អំណាចដល់ពួកគេដើម្បីអាចស្នើសុំព័ត៌មានអំពី គោលបំណងនៃគម្រោងផលប៉ះពាល់ធ្ងន់ធ្ងរ និងយុទ្ធសាស្ត្រនានាសម្រាប់ការកាត់បន្ថយផលប៉ះពាល់ទាំងនោះ។ ជារួមសិទ្ធិនេះ លើកកម្ពស់ប្រសិទ្ធភាពនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជា ដោយ

---

១៥ ហាន សៀ (Han Xia), តួនាទី និងបញ្ហានៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សម្រាប់ការគ្រប់គ្រងគម្រោងវារីអគ្គិសនី នៅកម្ពុជា, ៩ មេសា ២០២០, ទាញយកពី៖ https://doi.org/10.4236/blr.2020.112031
១៦ លោក ម៉ាតថេសិន, ខៃ (Mathiesen, Kay), ការទទួលបានព័ត៌មាន ជាសិទ្ធិមនុស្ស, ៧កញ្ញា ២០០៨, ទាញយកពី៖ https://ssrn.com/abstract=1264666 or http://dx.doi.org/10.2139/ssrn.1264666

ផ្តល់សិទ្ធិអំណាចដល់សាធារណជន ជាពិសេសសហគមន៍ក្រីក្រក្នុងទីក្រុងឱ្យបានច្រើនបំផុតតាមដែលអាចធ្វើទៅបាន។ ការផ្តល់សិទ្ធិអំណាចនេះ មានសារៈសំខាន់ចំពោះការធានាសុខុមាលភាពរបស់ពួកគេនៅក្នុងបរិបទនៃទិដ្ឋភាពអភិវឌ្ឍន៍ដែលកំពុងវិវត្តយ៉ាងឆាប់រហ័សនៅកម្ពុជា។



## ៣.៧. ក្របខណ្ឌការពារ គោរព និង ដោះស្រាយ

ក្របខណ្ឌការពារ គោរព និងដោះស្រាយ ដែលបង្កើតឡើងកាលពីឆ្នាំ២០០៨ ដោយលោក ចន រុហ្គី (John Ruggie) អ្នកតំណាងពិសេសទទួលបន្ទុកធុរកិច្ច និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ រួមបញ្ចូលទាំងក្រមគោលការណ៍មួយចំនួនដែលបង្កើតឡើង ដោយអង្គការសហប្រជាជាតិ ដើម្បីបង្កើតកាតព្វកិច្ចទាំងរដ្ឋ និងធុរកិច្ច ដើម្បីរក្សាការពារសិទ្ធិមនុស្សនៅក្នុងវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ច។[១៧] ក្របខ័ណ្ឌនេះ ត្រូវបានបង្កើតឡើងដោយផ្អែកលើសសរស្តម្ភគោលទាំងបី។

ទីមួយ កាតព្វកិច្ចរបស់រដ្ឋក្នុងការការពារ គោរពសិទ្ធិមនុស្ស ដោយទប់ស្កាត់ការរំលោភបំពានដែលអាចកើតមាន ដោយរួមបញ្ចូលទាំងធុរកិច្ចផងដែរ។ ការទទួលខុសត្រូវនេះរួមបញ្ចូលទាំងការបង្កើត និងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិដែលបង្កើតឡើងដើម្បីការពារសិទ្ធិមនុស្ស។

ទីពីរ ការទទួលខុសត្រូវរបស់សាជីវកម្មក្នុង ការគោរពសិទ្ធិមនុស្ស បញ្ជាក់ពីកាតព្វកិច្ចរបស់អាជីវកម្មក្នុងការលើកស្ទួយសិទ្ធិមនុស្សចំពោះប្រតិបត្តិការរបស់ខ្លួន។ ចំណុចនេះរួមបញ្ចូលការជៀសវាងការរំលោភសិទ្ធិមនុស្ស និងកាត់បន្ថយបញ្ហាសិទ្ធិមនុស្សនានាដែលអាចកើតចេញពីសកម្មភាពរបស់ពួកគេ។

ទីបី ក្របខណ្ឌនេះ គូសបញ្ជាក់ពីសារៈសំខាន់ដែលធានាថាអ្នកដែលរងគ្រោះពីការរំលោភសិទ្ធិដោយអាជីវកម្មមានសិទ្ធិទទួលបានការដោះស្រាយសមរម្យ ដែលរួមបញ្ចូលទាំង សំណងទូទាត់តាមរយៈប្រព័ន្ធតុលាការ និងក្រៅប្រព័ន្ធតុលាការ។ ចំណុចនេះ រួមបញ្ចូលទាំងសិទ្ធិសម្តែងសាទុក្ខចំពោះធុរកិច្ចពាក់ព័ន្ធ សិទ្ធិការពារខ្លួនតាមផ្លូវតុលាការ និងសិទ្ធិទទួលបានវិធានការសំណង។ ក្របខណ្ឌការពារ គោរព និងដោះស្រាយត្រូវបានយល់ព្រមពីក្រុមប្រឹក្សាសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ រដ្ឋាភិបាល និងធុរកិច្ចសកល ដែលជាឧបករណ៍ដ៏សំខាន់សម្រាប់ការការពារសិទ្ធិមនុស្សនៅក្នុងបរិបទសេដ្ឋកិច្ច។

១៧ គំនិតផ្តួចផ្តើមហិរញ្ញវត្ថុនៃកម្មវិធីបរិស្ថានអង្គការសហប្រជាជាតិ៖ ឧបករណ៍ណែនាំសិទ្ធិមនុស្ស សម្រាប់វិស័យហិរញ្ញវត្ថុ, ក្របខណ្ឌ និងគោលការណ៍ណែនាំស្តីពីអាជីវកម្ម និងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ, ខែធ្នូ ២០១៤។ ទាញយកពី៖ https://www.unepfi.org/humanrightstoolkit/framework.php

នៅកម្ពុជា ក្របខ័ណ្ឌនេះបាន ដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹងអំពីកាតព្វកិច្ចសិទ្ធិមនុស្សនៃធុរកិច្ច។ បន្ថែមពីនេះទៀត ក្របខណ្ឌនេះ បានសម្របសម្រួលកិច្ចសន្ទនាស្ថាបនារវាងសាជីវកម្ម ស្ថាប័នរដ្ឋាភិបាល និងសង្គមស៊ីវិលដោយពង្រឹងកិច្ចខិតខំប្រឹងប្រែងរួមគ្នាឆ្ពោះទៅរកការលើកកម្ពស់កិច្ចការពារសិទ្ធិមនុស្ស។



# ៤. វិធីសាស្ត្រស្រាវជ្រាវ



ការសិក្សានេះ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យដើម្បីឈ្វេងយល់ពីកម្រិតនៃការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

វិធីសាស្ត្រស្រាវជ្រាវនេះ រួមបញ្ចូលទាំងទិន្នន័យបឋម និងទិន្នន័យបន្ទាប់បន្សំ។ ចំពោះទិន្នន័យបឋម ការសម្ភាសពាក់កណ្ដាលរៀបរយជាមួយបុគ្គលសំខាន់ៗ និងកិច្ចពិភាក្សាជាក្រុមត្រូវបានធ្វើឡើង ដើម្បីទទួលបានការយល់ដឹងស៊ីជម្រៅអំពីទស្សនៈ និងបទពិសោធរបស់អ្នកចូលរួមទាំងអស់។

ចំពោះទិន្នន័យបន្ទាប់បន្សំ ការត្រួតពិនិត្យខ្លឹមសារអត្ថបទ ត្រូវបានធ្វើឡើងដោយផ្អែកលើក្របខណ្ឌច្បាប់កម្ពុជាទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន បញ្ហាប្រឈមនៃការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សិទ្ធិទទួលបានព័ត៌មាន និងក្របខ័ណ្ឌការពារគោរព និងដោះស្រាយ។ ចំណុចនេះ ត្រូវបានធ្វើឡើងក្នុងគោលដៅផ្ដល់ការស្វែងយល់ទូលំទូលាយលើប្រធានបទនេះ។

ផ្នែកខាងក្រោម គូសបញ្ជាក់អំពីការជ្រើសរើសសំណាក វិធីសាស្ត្រប្រមូលទិន្នន័យ និងនីតិវិធីវិភាគទិន្នន័យ ដូចបានប្រើប្រាស់ក្នុងការសិក្សានេះ។

## ៤.១. ការជ្រើសរើសសំណាក

ការសិក្សានេះ រួមបញ្ចូលសំណាកចំនួន៤៥គ្រួសារ ដែលមកពីសហគមន៍ក្រីក្រក្នុងទីក្រុងចំនួន៣ គឺព្រែកតាគង់៣ ព្រែកតាគង់៦០ម៉ែត្រ និងបឹងត្របែកភូមិ៤។ សហគមន៍ទាំងនេះ ត្រូវបានជ្រើសរើសដោយផ្អែកលើតំណាងប្រជាពលរដ្ឋនៅទីនោះ និងទីតាំងគម្រោងអភិវឌ្ឍន៍បច្ចុប្បន្នស្ថិតនៅជិតសហគមន៍របស់ពួកគេ។ អ្នកចូលរួមទាំងអស់ត្រូវបានជ្រើសរើសតាមរយៈការជ្រើសរើសសំណាកតាមគោលដៅ ដែលធានាបាននូវភាពចម្រុះនៃបុគ្គលម្នាក់ៗ ដោយមកពីគ្រួសារផ្សេងៗគ្នានៅក្នុងសហគមន៍នីមួយៗ។

នៅក្នុងចំណោមប្រជាពលរដ្ឋទាំង ៤៥គ្រួសារ មានអ្នកចូលរួមជាបុរសសរុប២នាក់ ចំណែកអ្នកផ្សេងទៀតជាស្ត្រី។ ការរួមបញ្ចូលអ្នកចូលរួមទាំងបុរស និងស្ត្រីនាំឱ្យមានការយល់ដឹងទូលំទូលាយអំពីបទពិសោធ និងទស្សនៈយល់ឃើញរបស់គ្រួសារទាំងអស់នៅក្នុងសហគមន៍ក្រីក្រក្នុងទីក្រុងទាំងនោះ។

## ៤.២. វិធីសាស្ត្រប្រមូលទិន្នន័យ

វិធីសាស្ត្រប្រមូលទិន្នន័យបឋម ដែលបានប្រើប្រាស់នៅក្នុងការសិក្សានេះ គឺការសម្ភាសជាមួយបុគ្គលសំខាន់ៗ និងកិច្ចពិភាក្សាជាក្រុម។ ការសម្ភាសនេះមានគោលដៅដើម្បីឈ្វេងយល់ស៊ីជម្រៅអំពីការយល់ដឹង និងទស្សនៈយល់ឃើញរបស់អ្នកចូលរួមអំពីសិទ្ធិចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ បុគ្គលសំខាន់ៗ ដូចជា ប្រធានសហគមន៍ អ្នកតំណាង និងបុគ្គលដែលមានបទពិសោធ ឬចំណេះដឹងពាក់ព័ន្ធនឹងប្រធានបទ ត្រូវបានជ្រើសរើសសម្រាប់ការសម្ភាស។ ការពិភាក្សាជាក្រុមជាវេទិកាមួយសម្រាប់សមាជិកសហគមន៍ដើម្បីចែករំលែកទស្សនៈ កង្វល់ និងបទពិសោធរបស់ពួកគេ។



## ៤.៣. វិធីសាស្ត្រវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបាន ត្រូវបានវិភាគដោយប្រើការវិភាគសុន្ទរកថា ដែលអនុញ្ញាតឱ្យមានការកំណត់ប្រធានបទសំខាន់ៗ គំរូ និងឧបសគ្គនានា ហើយដំណើរការវិភាគ មានដំណាក់កាលជាច្រើន។ ទីមួយ ចម្លើយនៃការសម្ភាសន៍ និងកិច្ចពិភាក្សាត្រូវបានសរសេរ និងផ្ទៀងផ្ទាត់ដោយអ្នកចូលរួមជាច្រើន ដោយធានាបាននូវភាពត្រឹមត្រូវនៃការឆ្លើយតបរបស់អ្នកចូលរួម។ បន្ទាប់មក អត្ថបទកត់ត្រាទាំងនេះត្រូវបានអានដោយប្រុងប្រយ័ត្នជាច្រើនសារ ដើម្បីយល់ពីទិន្នន័យ កំណត់គំរូ និងឧបសគ្គដែលកើតមាន។

## ៤.៤. លទ្ធផលរកឃើញផ្អែកតាមពិសោធន៍

ការសិក្សានេះ មានគោលដៅស្វែងយល់ពីកម្រិតនៃការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន កំណត់ឧបសគ្គដែលរារាំងដល់ការចូលរួមរបស់ពួកគេ និងផ្តល់អនុសាសន៍។ វិធីសាស្ត្របែបគុណវិស័យ ត្រូវបានប្រើប្រាស់ដោយរួមបញ្ចូលទាំងការសម្ភាសជាមួយបុគ្គលសំខាន់ៗ និងកិច្ចពិភាក្សាជាក្រុម។ គំរូសំណាក់នេះ មាន៤៥គ្រួសារដែលមកពីសហគមន៍ក្រីក្រក្នុងទីក្រុងចំនួន៣ គឺ ព្រែកតាគង់៣ ព្រែកតាគង់៦០ម៉ែត្រ និងបឹងត្របែកភូមិ៤។

សហគមន៍ព្រែកតាគង់៣ មានប្រជាពលរដ្ឋចំនួន២៥គ្រួសារមានចំណេះដឹងតិចតួចអំពីសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ពួកគេទើបតែមានការយល់ដឹងអំពីសិទ្ធិទាំងនេះ បន្ទាប់ពីសហគមន៍របស់ពួកគេត្រូវបានបង្កើតឡើងរយៈពេល៥ឆ្នាំ។

សំណង់ជាប់របងសហគមន៍បានបំផ្លិចបំផ្លាញប្រព័ន្ធលូទឹកស្អុយអស់រយៈពេល៨ឆ្នាំ ដែលនាំមកនូវផលប៉ះពាល់ដល់ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍នេះ។ ការបំផ្លិចបំផ្លាញនេះត្រូវបានសន្មត់ថា បណ្តាលមកពីការវាយតម្លៃដោយធ្វេសប្រហែស និងខ្វះការចូលរួមពីសហគមន៍ព្រែកតាគង់៣។ ជាលទ្ធផលសហគមន៍នេះរងការជន់លិចចាប់តាំងពីប្រព័ន្ធលូត្រូវបានបំផ្លិចបំផ្លាញ។ នៅពេលនោះ ទោះបី

មានការសន្យាពីអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយក៏ដោយ ក៏មិនមានការអន្តរាគមន៍ឡើយ។ ដូច្នេះ សហគមន៍នេះត្រូវធ្វើដំណើរឆ្លងកាត់ទឹកលិចជារៀងរាល់ថ្ងៃ និងត្រូវទទួលបន្ទុកលើហិរញ្ញវត្ថុផ្ទាល់ខ្លួនក្នុងការបូមទឹកចេញផងដែរ។ ថ្មីៗនេះ សហគមន៍ព្រែកតាគង់៣ បានទទួលស្ពានឈើមួយពីអង្គការសមាគមជាងត្នោតហើយពួកគាត់ក៏បានស្នើសុំផ្លូវលំក្រាលកៅស៊ូតូចមួយ ដើម្បីងាយស្រួលធ្វើដំណើរ។

តាមរយៈការពិភាក្សាជាក្រុមជាមួយអ្នកចូលរួម៥នាក់នៅសហគមន៍ព្រែកតាគង់៦០ម៉ែត្រ បានរកឃើញថា អគារខុនដូជាច្រើនត្រូវបានសាងសង់នៅជាប់របងសហគមន៍របស់ពួកគេអស់រយៈពេល៤ឆ្នាំមកហើយចាប់តាំងពីឆ្នាំ២០១៩មក។ ការសាងសង់នេះនាំមកនូវផលប៉ះពាល់រួមមាន ការបំពុលដោយសំឡេង ការកកស្ទះសំរាម ការហុយធូលីដី ការហូរចេញសំណល់រាវពីខុនដូ និងការធ្លាក់ដែកមកលើដំបូលផ្ទះសម្បែងរបស់ពួកគេ (សំណាងល្អ មិនមាននរណាម្នាក់រងរបួសឡើយ ក្រុមហ៊ុនខុនដូរសងសំណងថវិកាជម្ងឺចិត្តខ្លះដែរដល់ជនរងគ្រោះ ប៉ុន្តែសំណងជម្ងឺចិត្តនោះមិនត្រូវបានជូនចំពោះជនរងគ្រោះទាំងអស់នោះទេ)។ ស្រដៀងនឹងសហគមន៍ព្រែកតាគង់៣ សហគមន៍ព្រែកតាគង់៦០ម៉ែត្រ មានចំណេះដឹងតិចតួចអំពីសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដែលពួកគេចាប់ផ្តើមយល់ដឹងនៅពេលដែលសំណង់នោះសាងសង់ជិតរួចទៅរាល់ហើយ។

សំណល់រាវចេញពីខុនដូបានបង្កឱ្យជន់លិចនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រ ដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។ នៅពេលដែលសមាជិកសហគមន៍ព្យាយាមចាក់បំពេញដីដើម្បីការពារទឹកជន់លិចត្រូវបានអាជ្ញាធរមូលដ្ឋានផ្អាកសកម្មភាពដោយចាត់ទុកថាសកម្មភាពនេះមិនមានការអនុញ្ញាត។

ជាងនេះទៅទៀត គឺកង្វះព័ត៌មានពីអាជ្ញាធរមូលដ្ឋានទាក់ទងនឹងការសាងសង់ខុនដូ ទោះបីជាមានសំណូមពរពីសហគមន៍ក៏ដោយ។ សមាជិកសហគមន៍បានបង្ហាញឆន្ទៈរបស់ខ្លួន ក្នុងការទទួលយកព័ត៌មាន ប្រសិនបើអាជ្ញាធរមូលដ្ឋានធ្វើការផ្តួចផ្តើមគំនិតនេះ។ បន្ថែមពីនេះទៀតសហគមន៍នេះបានកត់សម្គាល់ឃើញមានផ្សែងចម្លែកចេញពីខុនដូមួយនេះ ដែលបញ្ចេញក្លិនស្អុយដល់សហគមន៍ និងមិនដឹងថាជាក្លិនអ្វី។



ក្នុងករណីសហគមន៍បឹងត្របែកភូមិ៤ មានអ្នកចូលរួមឆ្លើយតបបទសម្ភាសចំនួន១៥នាក់។ អ្នកឆ្លើយតបភាគច្រើនមិនមានចំណេះដឹងអំពីសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយបង្ហាញចំណាប់អារម្មណ៍និងឆន្ទៈតិចតួចដើម្បីទទួលបានចំណេះដឹងនេះ។ មានតែ៣នាក់ប៉ុណ្ណោះ នៅក្នុងចំណោម១៥នាក់ដែលដឹងពីសិទ្ធិចូលរួមរបស់ពួកគេ ហើយបានចាត់វិធានការដោយស្នើសុំព័ត៌មានទាក់ទងនឹងតំបន់ដីកកកាយដ៏ធំ ដែលមានទីតាំងនៅជិតសហគមន៍បឹងត្របែកភូមិ៤។ ផ្ទះមួយចំនួននៅក្នុងសហគមន៍ក៏ចាប់ផ្តើមមានស្នាមប្រេះដោយសារតែការជីក

កកាយដីនៅជិតផ្ទះសម្បែងរបស់ពួកគេ ដែលបង្កឱ្យមានការព្រួយបារម្ភអំពីការដួលរលំដែលអាចកើតមាន។ ជាក់ស្តែង អាជ្ញាធរមូលដ្ឋានមិនឆ្លើយតបនឹងសំណើរបស់សហគមន៍ចំពោះព័ត៌មានអំពីការជីកកកាយរណ្តៅ ហើយគ្មានឆន្ទៈក្នុងការដោះស្រាយស្ថានភាពនេះទេ។ អាជ្ញាធរដែលមានអំណាចនៅមូលដ្ឋាន ក៏ខកខានក្នុងការផ្តល់ព័ត៌មានដល់សហគមន៍បឹងត្របែកភូមិ៤ដែរ។

## ៤.៥. ការពិចារណាលើក្រមសីលធម៌

ក្រមសីលធម៌ ត្រូវបានអង្កេតនៅក្នុងដំណើរការស្រាវជ្រាវនេះផងដែរ។ អ្នកចូលរួមទាំងអស់ក៏បានយល់ព្រមទទួលយកគោលការណ៍ណែនាំនេះ ដោយធានាការចូលរួមដោយស្ម័គ្រចិត្ត និងរក្សាការសម្ងាត់នៃព័ត៌មានរបស់ពួកគេ។ អ្នកចូលរួមទាំងអស់ត្រូវបានជូនដំណឹងអំពីគោលបំណងនៃការសិក្សា លក្ខណៈនៃការចូលរួមរបស់ពួកគេ និងសិទ្ធិដកខ្លួនចេញនៅដំណាក់កាលណាមួយ។ ជាទូទៅ ព័ត៌មានផ្ទាល់ខ្លួនខ្លះមិនត្រូវបានបង្ហាញនៅអំឡុងពេលវិភាគ និងដំណាក់កាលសរសេររបាយការណ៍ឡើយ ព្រោះដើម្បីរក្សាការសម្ងាត់។



# ៥. លទ្ធផលស្រាវជ្រាវសំខាន់ៗ និងការវិភាគទិន្នន័យ



នៅក្នុងផ្នែកនេះ ទិន្នន័យដើម ឬបឋមដែលប្រមូលបានតាមរយៈការធ្វើបទសម្ភាស និងកិច្ចពិភាក្សាជាក្រុម ត្រូវបានវិភាគដើម្បីដោះស្រាយសំណួរស្រាវជ្រាវ និងកំណត់ឧបសគ្គដែលរារាំងសហគមន៍ក្រីក្រក្នុងទីក្រុងពីការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ វិធីសាស្ត្រប្រមូលទិន្នន័យដូចបានប្រើប្រាស់ក្នុងការសិក្សានេះ គឺមានលក្ខណៈបែបគុណវិស័យ ពាក់ព័ន្ធនឹងការសម្ភាសជាមួយបុគ្គលសំខាន់ៗ និងកិច្ចពិភាក្សាជាក្រុម។ ការសិក្សានេះមានសំណាកចំនួន៤៥គ្រួសារ ដែលមកពីសហគមន៍ក្រីក្រក្នុងទីក្រុងចំនួន៣ គឺព្រែកតាគង់៣ ព្រែកតាគង់ផ្លូវ៦០ម៉ែត្រ និងបឹងត្របែកភូមិ៤។

## ៥.១. ចម្លើយឆ្លើយតបទៅនឹងសំណួរ "អ្វីទៅជាការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងជាសិទ្ធិរបស់ពួកគេ ទាក់ទងនឹងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន?"

ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺជានីតិវិធីមួយដែលប្រើប្រាស់ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចកើតមានមុនពេលការអនុវត្តគម្រោងអភិវឌ្ឍន៍ រួមមានការកំណត់ និងការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចកើតឡើងពីគម្រោងអភិវឌ្ឍន៍។ បុគ្គលមួយចំនួន បង្ហាញពីការយល់ដឹង និងទទួលស្គាល់សារៈសំខាន់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែល ការពារសិទ្ធិ និងសុខុមាលភាពនៃសហគមន៍របស់ពួកគេ ខណៈដែលអ្នកផ្សេងទៀតបញ្ជាក់ពីកង្វះខាតនៃការយល់ដឹងអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយបង្ហាញពីគម្លាតនៃការយល់ដឹងអំពីសិទ្ធិរបស់ពួកគេ និងផលវិបាកដែលអាចកើតមាននៃគម្រោងអភិវឌ្ឍន៍។ អ្នកឆ្លើយតបម្នាក់មកពីសហគមន៍ព្រែកតាគង់៣ មានប្រសាសន៍ថា៖

> "ខ្ញុំមិនដឹងថា តើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាអ្វី ឬសិទ្ធិរបស់ខ្ញុំទាក់ទងនឹងវាជាអ្វីទេ រហូតទាល់តែយើងបង្កើតសហគមន៍ ហើយនៅពេលនោះយើងគ្រាន់តែបានដឹងអំពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានប៉ុណ្ណោះ។ ជាអកុសលនៅត្រឹមពេលនោះ វាយឺតពេលទៅហើយ ដោយសារលូបង្ហូរទឹកស្អុយ ត្រូវបានខូចខាតដោយសំណង់សហគមន៍ជាប់របងនៅក្បែរនោះ ហើយទឹកបានជន់លិចសហគមន៍របស់យើងរួចហើយ។"

## ៥.២. គម្រោងសំណង់ខុនដូ ដែលស្ថិតនៅជិតសហគមន៍ព្រែកតាគង់៦០ម៉ែត្រ

សហគមន៍ព្រែកតាគង់៦០ម៉ែត្រ ស្ថិតនៅជិតគម្រោងអភិវឌ្ឍន៍ធំមួយក្នុងរាជធានីភ្នំពេញ ដែលជាគម្រោង អឺបែនវីលេច ហ្វេសធូ (Urban Village Phase 2)។ គម្រោងសំណង់ខុនដូ អឺបែនវីលេច ហ្វេសធូ (Urban Village Phase 2) រួមមានការសាងសង់អគារកម្ពស់៥១ជាន់ចំនួន២ និងគ្របដណ្តប់លើផ្ទៃដី ៧៦០ ០០០ម៉ែត្រការ៉េ[១៨] ជានាការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញដោយផ្អែកលើបទប្បញ្ញត្តិដូចមានចែងក្នុងប្រកាសលេខ ០២១។


រូបភាពផ្កាយរណបពីគេហទំព័រGoogle Earthអំពីសហគមន៍ព្រែកតាគង់ផ្លូវ៦០ម៉ែត្រ និងគម្រោងសំណង់ខុនដូអឺបែនវីលេចហ្វេសធូ

យោងតាមប្រកាសនេះ គម្រោងសំណង់អគារខ្ពស់ដែលមានផ្ទៃដីលើសពី ៤៥ ០០០ ម៉ែត្រការ៉េស្ថិតក្រោមការត្រួតពិនិត្យមើលការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ។

ដោយសារតែការអភិវឌ្ឍ អ៊ីប៊ែនវីលិក ហ្វេសធូ (Urban Village Phase 2) លើសពីកម្រិតបញ្ញាក់នៃប្រកាសខាងលើ គម្រោងនេះមានកាតព្វកិច្ចរៀបចំការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដ៏ទូលំទូលាយ ដើម្បីវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលអាចកើតមានពីគម្រោងនេះ។ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវបានប្រើប្រាស់ជានីតិវិធីសំខាន់សម្រាប់ការវាយតម្លៃ និងការស្វែងយល់អំពីផលប៉ះពាល់ដែលអាចកើតមានពីគម្រោងសាងសង់ខ្នាតធំនៅក្បែរបរិវេណសហគមន៍។

ដោយពិចារណាលើមាត្រដ្ឋាន និងផលប៉ះពាល់ធ្ងន់ធ្ងររបស់គម្រោងខុនដូ អឺបែនវីលេច ហ្វេសធូ (Urban Village Phase 2)នេះ ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញ គឺមានសារៈសំខាន់ចំពោះការធានាឱ្យមានការអភិវឌ្ឍប្រកបដោយនិរន្តរភាព ការទទួលខុសត្រូវដែលស្របតាមលក្ខខណ្ឌបទដ្ឋានគតិយុត្តិ ការការពារបរិស្ថាន និងសហគមន៍។


ទិដ្ឋភាពនៃសហគមន៍ព្រែកតាគង់ផ្លូវ៦០ម៉ែត្រ និងគម្រោងសំណង់ខុនដូអឺបែនវីលេចហ្វេសធូ

ម្យ៉ាងវិញទៀត ទោះបីតម្រូវឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថានពេញលេញក៏ដោយក៏មិនមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលបង្ហាញជាសាធារណៈសម្រាប់គម្រោងសំណង់ខុនដូអឺបែនវីលេច ហ្វេសធូ (Urban Village Phase 2)ទេ សូម្បីតែក្រោយពេលបញ្ចប់គម្រោងក៏ដោយ។ កង្វះតម្លាភាពនេះ នាំមកនូវការព្រួយបារម្ភចំពោះការអនុវត្តគម្រោងដែលត្រូវស្របតាមបទប្បញ្ញត្តិបរិស្ថាន និងកម្រិតនៃផលប៉ះពាល់ដែលមាន

---

១៨ ភ្នំពេញប៉ុស្តិ៍, អឺបែនវីលេច ហ្វេសធូ (Urban Village Phase 2), កន្លែងរស់នៅដែលប្រកបដោយភាពច្នៃប្រឌិត, ៣ តុលា ២០១៩, ទាញយកពី៖ https://www.phnompenhpost.com/post-focus/urban-village-phase-2-where-innovative-living-comes-alive

សក្ដានុពលត្រូវបានវាយតម្លៃ និងកាត់បន្ថយឱ្យបាន។
អ្នកឆ្លើយតបម្នាក់ ដែលបានចូលរួមនៅក្នុងកិច្ចពិភាក្សាជាក្រុម មានប្រសាសន៍ថា៖

> “កាកសំណល់រាវដែលហូរចេញពីអគារខុនដូ បានធ្វើឱ្យមានការជន់លិចនៅក្នុងសហគមន៍របស់យើង នៅពេលដែលយើងព្យាយាមចាក់ដីដើម្បីជួយការពារការជន់លិចនោះ ពួកយើងត្រូវបានអាជ្ញាធរមូលដ្ឋានបញ្ឈប់ ដោយបានបញ្ជាក់ថា ការធ្វើបែបនេះមិនត្រូវបានអនុញ្ញាតទេ។”

## ៥.៣. គម្រោងអភិវឌ្ឍន៍នៅជិតសហគមន៍ព្រែកតាគង់៣

សហគមន៍ជាប់របងបុរីពិភពរស្មី ដែលមានទីតាំងនៅជិតសហគមន៍ព្រែកតាគង់៣ គឺជាតំបន់ដែលដាក់ឱ្យធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូងយោងតាមបទប្បញ្ញត្តិ ដូចមានចែងក្នុងប្រកាសលេខ០២១។ ម្យ៉ាងវិញទៀត ទោះបីជាមានចំណាត់ថ្នាក់ និងតម្រូវការសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏ដោយ ក៏មិនមានរបាយការណ៍ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាសាធារណៈរបស់បុរីពិភពរស្មីនោះទេ។

ដោយផ្អែក លើការវាស់វែង ដែលធ្វើឡើងដោយប្រើប្រាស់ឧបករណ៍វាស់ចម្ងាយ និងតំបន់របស់គេហទំព័រ Google Earth សហគមន៍ជាប់របងបុរីពិភពរស្មី មានផ្ទៃដី ១៧៧២៦ម៉ែត្រការ៉េ។ យោងតាមប្រកាសលេខ០២១ គម្រោងសំណង់ខ្លះ រួមបញ្ចូលទាំងសំណង់សហគមន៍ជាប់របងត្រូវស្ថិតក្រោមការត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដំបូង ប្រសិនបើផ្ទៃដីមានចន្លោះពី ១៥ ០០០ម៉ែត្រការ៉េ ដល់ ៤៥ ០០០ម៉ែត្រការ៉េ។


ទិដ្ឋភាពនៃសហគមន៍ព្រែកតាគង់៣ និងសំណង់ជាប់របងសហគមន៍



សហគមន៍ព្រែកតាគង់៣ បានជួបប្រទះផលប៉ះពាល់រួចមកហើយ ដែលកើតចេញពីការអភិវឌ្ឍនៃបុរីពិភពរស្មី។ ជាក់ស្តែង ភាពមិនយកចិត្តទុកដាក់នៅក្នុងអំឡុងពេលដំណើរការសាងសង់បានបណ្តាលឱ្យខូចខាតប្រព័ន្ធលូបង្ហូរទឹកនៅសហគមន៍ព្រែកតាគង់៣ ដែលនាំទៅរកការលិចលង់ក្នុងសហគមន៍នោះ។ ទឹកជំនន់នេះបានប៉ះពាល់យ៉ាងខ្លាំងដល់ជីវភាព និងគុណភាពជីវិត ចំពោះប្រជាពលរដ្ឋដែលរស់នៅសហគមន៍ព្រែកតាគង់៣។

ទោះបីមានបទដ្ឋានគតិយុត្តិ សម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថានលើកដំបូងក៏ដោយ ក៏មិនមានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបង្ហាញជាសាធារណៈសម្រាប់សហគមន៍ជាប់របងបុរីពិភពរស្មីនោះដែរ។ កង្វះតម្លាភាពនេះបង្កឱ្យមានការព្រួយបារម្ភជាខ្លាំងអំពីការអនុវត្តតាមបទប្បញ្ញត្តិបរិស្ថានរបស់គម្រោងអភិវឌ្ឍន៍

និងវិសាលភាពនៃផលប៉ះពាល់បរិស្ថានដែលអាចកើតមានត្រូវបានយកមកវាយតម្លៃ និងដោះស្រាយ។ អ្នកឆ្លើយតបម្នាក់ដែលបានចូលរួមក្នុងការធ្វើបទសម្ភាស បានមានប្រសាសន៍ថា៖

> “មុននឹងការសាងសង់នេះ សហគមន៍របស់យើងមិនទាន់លិចទឹកនៅឡើយទេ ជាក់ស្តែង វាជន់លិចទឹកតែនៅពេលដែលកម្មករសំណង់បានបំផ្លាញប្រព័ន្ធលូបង្ហូរទឹករបស់យើង ហេតុនេះបានបង្កឱ្យជន់លិច។ ជាធម្មតា យើងត្រូវដើរកាត់ទឹកលិចរាល់ថ្ងៃ ដូច្នេះវាមានការលំបាកច្រើនព្រោះយើងត្រូវដើរកាត់ពីរទៅបីដងក្នុងមួយថ្ងៃ”។

## ៥.៤. អាងស្តុកទឹកបឹងត្របែក ដែលស្ថិតនៅជិតសហគមន៍បឹងត្របែកភូមិ៤

ជាការពិត ការដ្ឋានដីកកកាយដីដ៏ធំមួយ ដែលស្ថិតនៅជិតសហគមន៍បឹងត្របែកភូមិ៤ បានបង្កឱ្យមានការព្រួយបារម្ភពីផលប៉ះពាល់បរិស្ថានចំពោះសហគមន៍ផងដែរ។ ទោះបីយ៉ាងនេះក្តី ក៏គ្មានប្រជាពលរដ្ឋក្នុងសហគមន៍បឹងត្របែកភូមិ៤ បានដឹងថា ការជីកកកាយដីនោះជាការដ្ឋានអ្វីទេ។

ទោះបីសហគមន៍ បានស្នើសុំព័ត៌មាន ក៏ដោយ ក៏អាជ្ញាធរមូលដ្ឋានមិនឆ្លើយតប និងមិនផ្តល់ព័ត៌មានលម្អិតណាមួយអំពីការដ្ឋានជីកកកាយដីនោះទេ។ ជាងនេះទៅទៀត សកម្មភាពជីកកកាយដីដែលធ្វើឡើងស្ថិតនៅជិតលំនៅឋានរបស់សហគមន៍បានបង្កឱ្យមានស្នាមប្រេះនៅតាមផ្ទះសម្បែងមួយចំនួនរួចទៅហើយ ដោយបង្កឱ្យមានការព្រួយបារម្ភអំពីការដួលរលំ។ អាជ្ញាធរម្នាក់ត្រូវបានដឹងថាមិនមានឆន្ទៈក្នុងការផ្តល់ព័ត៌មាននោះទេ។ អ្នកឆ្លើយតបម្នាក់ បានមានប្រសាសន៍ថា៖

> “ផ្ទះរបស់ខ្ញុំ ចាប់ផ្តើមប្រេះដោយសារការដ្ឋានជីកកកាយដីនោះកាន់តែកៀកទៅៗ។ ភាគច្រើនពួកគេធ្វើការនៅពេលយប់។ ខ្ញុំបានព្យាយាមស្នើសុំឱ្យពួកគេរក្សាចម្ងាយយ៉ាងតិច៥ម៉ែត្រពីផ្ទះរបស់យើង ប៉ុន្តែខ្ញុំមិនទាន់ដឹងថាពួកគេយល់ព្រមឬមិនយល់ព្រមនោះទេ។”



*ទិដ្ឋភាពនៃការដ្ឋានជីកកកាយធំមួយ ដែលស្ថិតនៅក្រោយផ្ទះសម្បែងប្រជាពលរដ្ឋសហគមន៍បឹងត្របែកភូមិ៤*

ទោះជាយ៉ាងណាក៏ដោយ ការដ្ឋានជីកកកាយដីនោះទាក់ទងទៅនឹងអនុក្រឹត្យលេខ២២១ ស្តីពី

*“តំបន់អាងស្តុកទឹកបឹងត្របែកនៅរាជធានីភ្នំពេញជាសម្បត្តិសាធារណៈរបស់រដ្ឋ”*

ដែលបានអនុម័តដោយអតីតនាយករដ្ឋមន្ត្រី ហ៊ុន សែន កាលពីឆ្នាំ២០២០ ដែលដាក់កំណត់ឱ្យបង្កើតអាងស្តុកទឹកបឹងត្របែកដែលជាគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់មួយសម្រាប់រំដោះទឹកស្អុយដែលជាតម្រូវការបន្ទាន់នៅក្នុងរាជធានីភ្នំពេញដែលមានផ្ទៃដីទំហំ១៤ ៥៦២៧ហិកតា ឬ១៤៥៦២៧ម៉ែត្រការ៉េ។[19] ការអនុម័តច្បាប់នេះ

[19] អនុក្រឹត្យលេខ២២១ ស្តីពីតំបន់អាងស្តុកទឹកបឹងត្របែកនៅរាជធានីភ្នំពេញ ជាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ

ត្រូវបានកត់សម្គាល់ថា ប្រភេទគម្រោងមួយចំនួនរួមបញ្ចូលទាំងអាងស្តុកទឹកអាចនឹងត្រូវបានលើកលែងពីការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដោយសារសារៈសំខាន់របស់វា។ អាស្រ័យហេតុនេះ កង្វះខាតនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានចំពោះការដ្ឋាននេះ គឺដោយសារបទប្បញ្ញត្តិទាំងនេះ។



កង្វះការយល់ដឹងរបស់ប្រជាពលរដ្ឋមូលដ្ឋានអំពីហេដ្ឋារចនាសម្ព័ន្ធដ៏សំខាន់នេះ អាចត្រូវបានពន្យល់ដោយកត្តាពីរ។ ទីមួយ កង្វះខាតនៃបណ្តាញទំនាក់ទំនងដែលមានប្រសិទ្ធភាពរវាងរដ្ឋាភិបាល និងអាជ្ញាធរមូលដ្ឋាន។ របាំងការិយាធិបតេយ្យអាចរារាំងលំហូរព័ត៌មានដោយរលូនពីរដ្ឋាភិបាលថ្នាក់លើមកដល់ថ្នាក់មូលដ្ឋាន។ ទីពីរ អាជ្ញាធរមូលដ្ឋាន អាចបដិសេធព័ត៌មានលម្អិតអំពីគម្រោងដើម្បីបញ្ចៀសកុំឱ្យមានការភិតភ័យ ឬអារម្មណ៍អវិជ្ជមានក្នុងសហគមន៍បឹងត្របែកភូមិ៤។ ពួកគេប្រហែលជាជឿថាដោយសារចំណេះដឹងអំពីគម្រោងនៅមានកម្រិតនាំឱ្យប្រជាពលរដ្ឋទាំងនោះមិនឱ្យមានការបារម្ភទេ។ លើសពីនេះទៀត ប្រជាពលរដ្ឋក្នុងសហគមន៍បឹងត្របែកភូមិ៤ មានកម្រិតយល់ដឹងទាបអំពីសារៈសំខាន់ និងឆន្ទៈអនុវត្តសិទ្ធិរបស់ពួកគេក្នុងការចូលរួមទាក់ទងនឹងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅមានកម្រិតទាប។ ការសម្រេចចិត្តរបស់អាជ្ញាធរមានការលាក់ព័ត៌មាន អំពីកន្លែងជីកកកាយដីអាចត្រូវបានជំរុញដោយជឿថា ការទុកប្រជាជនក្នុងភាពងងឹត គឺចាំបាច់ដើម្បីចៀសវាងការបង្កឱ្យមានការព្រួយបារម្ភ ឬ ភាពតានតឹង។

## ៥.៥. ការវិភាគប្រៀបធៀបការយល់ដឹងទស្សនៈ និងឧបសគ្គក្នុងដំណើរការចូលរួមវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ផ្នែកនេះ ប្រៀបធៀបការយល់ដឹង ទស្សនៈ និងឧបសគ្គទាក់ទងនឹងការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅទូទាំងសហគមន៍ក្រីក្រក្នុងទីក្រុងចំនួនបី៖ ព្រែកតាគង់៣ ព្រែកតាគង់៦០ម៉ែត្រ និងបឹងត្របែកភូមិ៤។

### ៥.៥.១. ការយល់ដឹង និងទស្សនៈ

នៅក្នុងសហគមន៍ព្រែកតាគង់៣ ការយល់ដឹងអំពីសិទ្ធិចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺទើបតែកើតឡើងថ្មីៗនេះ ក្រោយពេលបង្កើតសហគមន៍កាលពី៥ឆ្នាំមុន។ បទពិសោធរបស់សហគមន៍ជាមួយផលប៉ះពាល់នៃសំណង់ជាប់របងសហគមន៍បានជំរុញឱ្យមានការយល់ដឹងនេះ។ ជាធម្មតា ការបំផ្លិចបំផ្លាញប្រព័ន្ធលូបង្ហូរទឹកស្អុយនេះ បណ្តាលមកពីការវាយតម្លៃដោយធ្វេសប្រហែស និងកង្វះខាតនៃការចូលរួមបណ្តាលឱ្យមានបញ្ហាទឹកជំនន់នាបច្ចុប្បន្ននេះ។ ដូចគ្នានេះដែរ ការយល់ដឹងរបស់សហគមន៍ព្រែកតាគង់៦០ម៉ែត្រ ត្រូវបានចាប់ផ្តើមកើតឡើង ដោយសារការសាងសង់អគារខុនដូជាច្រើនដែលនាំឱ្យមានបញ្ហា ដូចជាការបំពុលសំឡេង ការកកស្ទះសំរាម និងទឹកជំនន់។ ផ្ទុយទៅវិញ សហគមន៍បឹងត្របែកភូមិ៤ បានបង្ហាញកម្រិតយល់ដឹងទាបបំផុត ដោយមានតែប្រជាជនតិចតួចប៉ុណ្ណោះដែលត្រូវបានគេជូនដំណឹងអំពីសិទ្ធិចូលរួមរបស់ពួកគេ។ ជាការពិតណាស់ ពួកគេភាគច្រើនបានបង្ហាញ

ចំណាប់អារម្មណ៍ ឬឆន្ទៈតិចតួចក្នុងការរកព័ត៌មានបែបនេះ លើកលែងតែមនុស្សមួយចំនួន ដែលចូលរួមយ៉ាងសកម្ម ដោយសារមានការព្រួយបារម្ភអំពីការដួលរលំផ្ទះសម្បែង ដែលអាចកើតឡើងដោយការដ្ឋានជីកកកាយដីនៅក្បែរនោះ។

### ៥.៥.២. ឧបសគ្គចំពោះការចូលរួម

ឧបសគ្គចំពោះការចូលរួម គឺជាភស្តុតាងបង្ហាញឱ្យឃើញនៅក្នុងសហគមន៍ទាំងបី។ នៅតំបន់ព្រែកតាគង់៣ កង្វះខាតនៃការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន បាននាំឱ្យមានបន្ទុកធ្ងន់ផ្នែកហិរញ្ញវត្ថុដល់សហគមន៍ ក្រោយពេលបានបំផ្លិចបំផ្លាញប្រព័ន្ធលូបង្ហូរទឹកស្អុយហើយ។ នៅព្រែកតាគង់៦០ម៉ែត្រ កាកសំណល់រាវពីអគារខុនដូបានបង្កឱ្យជន់លិច ប៉ុន្តែការព្យាយាមរបស់សហគមន៍ដើម្បីទប់ស្កាត់ទឹកជំនន់នោះ ត្រូវបានបញ្ឈប់ដោយអាជ្ញាធរមូលដ្ឋានដោយចាត់ទុកថា សកម្មភាពរបស់ពួកគេគ្មានការអនុញ្ញាត។ លើសពីនេះទៀត កង្វះខាតនៃការផ្តល់ព័ត៌មានពីអាជ្ញាធរមូលដ្ឋានអំពីការសាងសង់អគារខុនដូបានរារាំងដល់ការចូលរួម។

ជាកាពិត បឹងត្របែកភូមិ៤ ជួបប្រទះបញ្ហាប្រឈមដូចជា ការមិនឆ្លើយតបពីអាជ្ញាធរមូលដ្ឋាន និងការមិនទទួលបានព័ត៌មាន។ ចំណុចនេះបង្ហាញពីការកង្វះឆន្ទៈរបស់អាជ្ញាធរ ចំពោះការដោះស្រាយកង្វល់ទាក់ទងនឹងការដ្ឋានជីកកកាយដីនៅក្បែរសហគមន៍។



### ៥.៦. កម្រិតយល់ដឹង និងទស្សនៈរបស់សហគមន៍ក្រីក្រក្នុងទីក្រុងលើការចូលរួមដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ការវិភាគទិន្នន័យ បង្ហាញបន្ថែមទៀតអំពីការយល់ដឹង និងទស្សនៈតិចតួចរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ជាទូទៅ នៅក្នុងសហគមន៍ព្រែកតាគង់៣ គ្រួសារចំនួន២៥ មានចំណេះដឹងតិចតួចអំពីសិទ្ធិរបស់ពួកគេ។ ជាក់ស្តែង ចំណុចនេះគួរឱ្យកត់សម្គាល់ថា ការយល់ដឹងរបស់ពួកគេអំពីសិទ្ធិទាំងនេះ ចាប់ផ្តើមលេចឡើងតែនៅពេលដែលសហគមន៍ត្រូវបានបង្កើតឡើងអស់រយៈពេល៥ឆ្នាំ ចាប់តាំងពីឆ្នាំ២០១៨។ ចំណុចនេះ បង្ហាញថាសហគមន៍ខ្លួនឯងបានដើរតួនាទីយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង។ គេអាចសន្និដ្ឋានបានថា មុនពេលបង្កើតសហគមន៍មានការកំណត់កម្មវិធីដើម្បីផ្សព្វផ្សាយព័ត៌មានអំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសិទ្ធិសហគមន៍ក្រីក្រក្នុងទីក្រុង។

ស្រដៀងគ្នានេះដែរ ក្នុងករណីសហគមន៍ព្រែក

តាគង់៦០ម៉ែត្រដែលសមាជិកសហគមន៍ភាគច្រើនមានចំណេះដឹងតិចតួចអំពីសិទ្ធិចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ពួកគេចាប់ផ្តើមយល់ដឹងបន្តិចបន្តួចនៅពេលគម្រោងសាងសង់អគារខុនដូក្បែរនោះជិតត្រូវបានបញ្ចប់ទៅហើយ។ លទ្ធផលរកឃើញនេះ បានបង្ហាញពីបញ្ហាប្រឈមនានាដែលទាក់ទងនឹងការយល់ដឹងរបស់សហគមន៍ បញ្ហាទាំងនោះកើតឡើងតាមរយៈការឆ្លើយតបទៅនឹងផលប៉ះពាល់ដោយផ្ទាល់របស់ពួកគេដោយសារតែគម្រោងអភិវឌ្ឍន៍ស្ថិតនៅក្បែរនោះ។

ចំណុចនេះ បង្ហាញថា សហគមន៍ក្រីក្រក្នុងទីក្រុង មានទំនោរយល់ដឹងអំពីសិទ្ធិចូលរួមរបស់ពួកគេ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅពេលប្រឈមមុខនឹងផលប៉ះពាល់ជាក់ស្តែង និងចំពោះមុខដែលបណ្តាលមកពីគម្រោងអភិវឌ្ឍន៍ ដែលបានអនុវត្តនៅក្បែរសហគមន៍របស់ពួកគេ។

ជាងនេះទៅទៀត ក្នុងករណីសហគមន៍បឹងត្របែកភូមិ៤ កម្រិតយល់ដឹងអំពីសិទ្ធិចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន គឺមានកម្រិតទាប។ ក្នុងចំណោមអ្នកឆ្លើយតប១៥នាក់ អ្នកឆ្លើយតបបីនាក់ប៉ុណ្ណោះដែលយល់ដឹងអំពីសិទ្ធិរបស់ពួកគេ ហើយបានចាត់វិធានការដោយស្នើសុំព័ត៌មាន អំពីការដ្ឋានដីកកកាយដីធំមួយដែលស្ថិតនៅក្បែរសហគមន៍របស់ពួកគេ។ របកគំហើញនេះ គូសបញ្ជាក់អំពីកង្វះខាតនៃការយល់ដឹងយ៉ាងសំខាន់ក្នុងចំណោមសមាជិកសហគមន៍ និងការមិនមានធន្ទៈក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ដោយបង្ហាញអំពីតម្រូវការចាំបាច់សម្រាប់កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើនការយល់ដឹងរបស់ពួកគេអំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសារៈសំខាន់នៃសិទ្ធិរបស់ពួកគេនៅក្នុងសហគមន៍នោះ។ ការចូលរួមរបស់សហគមន៍ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានក៏ត្រូវបានបញ្ជាក់ផងដែរថា ភាគច្រើនគឺអវត្តមាន ឬមានតិចតួចដោយសារតែពួកគេមិនមានធន្ទៈ ដែលមានតែបុគ្គលសកម្មមួយចំនួនប៉ុណ្ណោះដែលព្យាយាមស្វែងរកព័ត៌មាន។

## ៥.៧. ឧបសគ្គរារាំងសហគមន៍ក្រីក្រក្នុងទីក្រុងក្នុងការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

ឧបសគ្គជាច្រើនដែលបានរារាំងសហគមន៍ក្រីក្រក្នុងទីក្រុងពីការចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានដែលមានប្រសិទ្ធភាពត្រូវបានរកឃើញដូចខាងក្រោម៖

### ៥.៧.១. កង្វះខាតនៃការយល់ដឹង និងចំណេះដឹង

ឧបសគ្គចម្បងដូចបានកំណត់ គឺជាកង្វះខាតនៃការយល់ដឹង និងចំណេះដឹងរបស់សហគមន៍ក្រីក្រក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេ ក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។



ចំណុចនេះ គឺរាំងសមត្ថភាពរបស់ពួកគេក្នុងការចូលរួមយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តដែលប៉ះពាល់ដល់ជីវភាពរស់នៅរបស់ពួកគេ។

សមាជិកសហគមន៍ជាច្រើន នៅក្នុងសហគមន៍ទាំងបីដែលបានធ្វើសម្ភាស គឺបានយល់ដឹងតិចតួចអំពីសិទ្ធិរបស់ពួកគេរហូតដល់មានផលប៉ះពាល់ដោយផ្ទាល់ ទើបពួកគេមានការចាប់អារម្មណ៍។

## ៥.៧.២. កង្វះខាតនៃទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មាន

លទ្ធផលរកឃើញបង្ហាញថា អាជ្ញាធរមូលដ្ឋានខកខានក្នុងការផ្តល់ទំនាក់ទំនង និងការផ្សព្វផ្សាយព័ត៌មានប្រកបដោយប្រសិទ្ធភាពដល់សហគមន៍ក្រីក្រក្នុងទីក្រុង។ ការស្នើសុំព័ត៌មាន ទាក់ទងនឹងគម្រោងសាងសង់នៅក្បែរនោះ ដូចជាព័ត៌មានអំពីអគារខុនដូនៅជិតសហគមន៍ព្រែកតាគង់៦០ម៉ែត្រមិនត្រូវបានអើពើឬមិនបានដោះស្រាយឱ្យបានសមស្របទេ។ កង្វះខាតព័ត៌មានពីអាជ្ញាធរមូលដ្ឋាន រាំងសមាជិកសហគមន៍ក្នុងការទទួលបានដំណឹង និងការចូលរួមប្រកបដោយប្រសិទ្ធភាពក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។

## ៥.៧.៣. កង្វះខាតព័ត៌មាន និងការអញ្ជើញចូលរួមនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន

សហគមន៍ក្រីក្រក្នុងទីក្រុង គូសបញ្ជាក់ពីកង្វះខាតព័ត៌មាន និងការអញ្ជើញពីអាជ្ញាធរមូលដ្ឋានដើម្បីចូលរួមក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ករណីសហគមន៍បឹងត្របែកភូមិ៤បង្ហាញថា សមាជិកសហគមន៍មិនបានដឹងពីអត្ថិភាពនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយក៏មិនបានទទួលការអញ្ជើញឱ្យចូលរួមផងដែរ។ ពេលគ្មានវិធីសាស្ត្របរិយាប័ន្ន និងសកម្មពីអាជ្ញាធរមូលដ្ឋាន គឺរាំងសហគមន៍ក្រីក្រក្នុងទីក្រុងក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ទាក់ទងនឹងផលប៉ះពាល់បរិស្ថានដែលប៉ះពាល់ដោយផ្ទាល់ដល់ពួកគេ។

## ៥.៧.៤. កង្វះខាតឆន្ទៈអនុវត្តសិទ្ធិរបស់ពួកគេ

លទ្ធផលរកឃើញមួយទៀត គឺការស្ទាក់ស្ទើររបស់សមាជិកសហគមន៍មួយចំនួនក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ ទោះបីជាត្រូវបានអញ្ជើញឱ្យដាក់ពាក្យបណ្តឹងដោយតំណាងសហគមន៍ក៏ដោយ។ ចំណុចនេះ ជាភស្តុតាងជាពិសេសដែលបង្ហាញឱ្យឃើញនៅក្នុងសហគមន៍បឹងត្របែកភូមិ៤។ អ្នកចូលរួមជាច្រើន បានបង្ហាញពីចំណាប់អារម្មណ៍ និងការយល់ដឹងតិចតួចដែលបញ្ជាក់អំពីកង្វះខាតលើកទឹកចិត្តចូលរួមក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្តទាក់ទងនឹងផលប៉ះពាល់បរិស្ថាន។ ហេតុផលពិតប្រាកដខ្លះមិនត្រូវបានបង្ហាញឱ្យដឹង។ ទោះជាយ៉ាងណា ហេតុផលមួយចំនួនរួមបញ្ចូលទាំងភាពស្មុគស្មាញនៃដំណើរការ និងការថយចុះទំនុកចិត្តលើអាជ្ញាធរមូលដ្ឋាន។ ការយល់ដឹងអំពីកត្តាទាំងនេះ គឺមានសារៈសំខាន់ចំពោះការបង្កើតយុទ្ធសាស្ត្រដើម្បីលើកទឹកចិត្តឱ្យមានការចូលរួម។



# ៦. សេចក្តីសន្និដ្ឋាន



ការស្រាវជ្រាវនេះ បានឆ្លុះបញ្ចាំងអំពីការយល់ដឹង និងទស្សនៈយល់ឃើញរបស់សហគមន៍ក្រីក្រ ក្នុងទីក្រុងទាក់ទងនឹងសិទ្ធិចូលរួមរបស់ពួកគេក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន នៅកម្ពុជា។ លទ្ធផលរកឃើញបង្ហាញថា ការចូលរួមជាសាធារណៈ ពិតជាមានសារៈសំខាន់ចំពោះការធ្វើឱ្យដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ប្រកបដោយតម្លាភាព គណនេយ្យភាព និងយុត្តិធម៌។

របាយការណ៍នេះ បង្ហាញថា មានបញ្ហាប្រឈម និងគម្លាតនៃការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានបច្ចុប្បន្ន ដោយរួមបញ្ចូលទាំងការយល់ដឹងរបស់សហគមន៍ក្រីក្រក្នុងទីក្រុងមានកម្រិត និងកង្វះខាតគោលការណ៍ណែនាំច្បាស់លាស់។ ទោះយ៉ាងណា ក៏ដោយ មានអនុសាសន៍ដែលអាចអនុវត្តបាន ដើម្បីដោះស្រាយបញ្ហាទាំងនេះ និងពង្រឹងប្រសិទ្ធភាពនៃការចូលរួមជាសាធារណៈ នៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ដោយបានលើកកម្ពស់ការយល់ដឹង ពង្រឹងក្របខ័ណ្ឌច្បាប់ លើកកម្ពស់តម្លាភាព និងការចូលរួមរបស់អង្គការមិនមែនរដ្ឋាភិបាល ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអាចក្លាយជាបរិយាប័ន្ន និងការចូលរួមកាន់តែច្រើន។ វិធានការទាំងនេះ នឹងផ្តល់សិទ្ធិអំណាចដល់សហគមន៍ក្រីក្រក្នុងទីក្រុងដើម្បីរួមចំណែកយ៉ាងសកម្មក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយធានាថាកង្វល់របស់ពួកគេត្រូវបានដឹងឮ។

ជារួម ការស្រាវជ្រាវនេះបង្ហាញថា ការចូលរួមជាសាធារណៈពិតជាមានសារៈសំខាន់ចំពោះការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជា។ អនុសាសន៍ទាំងនេះ មានគោលបំណងភ្ជាប់គម្លាតរវាងអ្វីដែលច្បាប់ចែង និងអ្វីដែលកើតឡើងក្នុងការអនុវត្តជាក់ស្តែង។ ដោយដាក់បញ្ចូលសាធារណជននៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានអនុសាសន៍នេះធ្វើឱ្យការអភិវឌ្ឍប្រកបដោយយុត្តិធម៌ និងបរិយាប័ន្ន ការគោរពសិទ្ធិ និងមតិយោបល់របស់ប្រជាពលរដ្ឋទាំងអស់ ជាពិសេសសហគមន៍ក្រីក្រក្នុងទីក្រុង។



# ៧. អនុសាសន៍



យោងតាមលទ្ធផលនៃការស្រាវជ្រាវនេះ អនុសាសន៍មួយចំនួនត្រូវបានធ្វើឡើងដើម្បីបង្កើនប្រសិទ្ធភាពនៃការចូលរួមជាសាធារណៈនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាននៅកម្ពុជាដោយពឹងផ្អែកលើភាគីពាក់ព័ន្ធនីមួយៗ។

## ក ) អង្គការមិនមែនរដ្ឋាភិបាល ( NGOs )

» អង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍គួរតែមានគំនិតផ្តួចផ្តើមឈានមុខនៅក្នុងការរៀបចំ និងអនុវត្តគំនិតផ្តួចផ្តើមផ្នែកអប់រំ សិក្ខាសាលា ការប្រជុំសហគមន៍ និងយុទ្ធនាការផ្សព្វផ្សាយ ជាពិសេសផ្តោតលើសហគមន៍ក្រីក្រក្នុងទីក្រុង។ គំនិតផ្តួចផ្តើមផ្នែកអប់រំគប្បីក្របដណ្តប់លើមូលដ្ឋានគោលនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ដោយរួមបញ្ចូលគោលបំណង ផលប្រយោជន៍ និងសិទ្ធិចូលរួម។ ជាធម្មតា ពួកគេគួរតែចូលរួមយ៉ាងសកម្មជាមួយសហគមន៍ទាំងនេះ និងផ្សព្វផ្សាយព័ត៌មានអំពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងផលប្រយោជន៍របស់វា។ វិធីសាស្រ្តផ្សេងៗទៀត គប្បីយកមកពិចារណា ដូចជាការប្រមូលផ្តុំសហគមន៍ ការចែកចាយខិតប័ណ្ណ ការរៀបចំវគ្គបណ្តុះបណ្តាល និងការប្រើប្រាស់វេទិកាផ្សព្វផ្សាយព័ត៌មានមូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍ត្រូវមានទទួលខុសត្រូវខ្ពស់បំផុត។ ទីមួយ ពួកគេត្រូវមានជំនាញ និងបទពិសោធន៍ចំពោះការចូលរួមរបស់សហគមន៍ ការតស៊ូមតិ និងបញ្ហាបរិស្ថាន។ ទីពីរ ពួកគេត្រូវមានទំនាក់ទំនងថ្នាក់មូលដ្ឋាន។ ជារឿយៗ អង្គការមិនមែនរដ្ឋាភិបាល ត្រូវមានទំនាក់ទំនងជិតស្និទ្ធជាមួយសហគមន៍ក្រីក្រក្នុងទីក្រុង។ ហេតុដូច្នេះ ពួកគេត្រូវមានការយល់ដឹងកាន់តែច្បាស់អំពីតម្រូវការ និងលក្ខខណ្ឌជាក់លាក់របស់ពួកគេ។

» អង្គការក្រៅរដ្ឋាភិបាល ត្រូវរៀបចំការវាយតម្លៃរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន ហើយត្រូវផ្តល់មតិយោបល់ និងព័ត៌មានត្រឡប់របស់ពួកគេដល់ម្ចាស់គម្រោង។ ជាក់ស្តែង ពួកគេត្រូវចូលរួមយ៉ាងសកម្មជាមួយរបាយការណ៍ទាំងនេះ ពិនិត្យរបាយការណ៍ឱ្យបានហ្មត់ចត់ និងលើកឡើងអំពីកង្វល់ ឬសំណូមពរនានាសម្រាប់ការកែលម្អ។

## ខ ) រដ្ឋមន្ត្រីបរិស្ថាន និងស្ថាប័នពាក់ព័ន្ធរបស់

### រដ្ឋាភិបាល

» ក្រសួងបរិស្ថាន និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ត្រូវផ្តល់ជំនួយគាំទ្រ ធនធាន និងការណែនាំ ដល់អង្គការមិនមែនរដ្ឋាភិបាល និងតំណាងសហគមន៍នានា។ ពួកគេ គប្បីសហការគ្នា ដើម្បីរៀបចំវគ្គបណ្តុះបណ្តាល សម្របសម្រួលការទទួលបានព័ត៌មាន និងធានានូវភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃសម្ភារៈអប់រំ។ ខណៈដែលអង្គការមិនមែនរដ្ឋាភិបាល មានទំនួលខុសត្រូវខ្ពស់បំផុតចំពោះការលើកកម្ពស់ការយល់ដឹង កិច្ចសហការជាមួយស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ ដូចជាក្រសួងបរិស្ថាន គឺមានសារៈសំខាន់ចំពោះការធានានូវការកែតម្រឹមគំនិតផ្តួចផ្តើមអប់រំជាមួយលក្ខខណ្ឌច្បាប់ និងផ្តល់ជំនួយគាំទ្រ និងធនធានចាំបាច់។

» ក្រសួងបរិស្ថាន អ្នកជំនាញផ្នែកច្បាប់ និងស្ថាប័នរដ្ឋាភិបាលពាក់ព័ន្ធ គប្បីទទួលខុសត្រូវខ្ពស់បំផុតចំពោះការដោះស្រាយភាពខ្វះចន្លោះផ្នែកច្បាប់ ទាក់ទងនឹងកម្រិតវិសាលភាព និងពេលវេលានៃការចូលរួមជាសាធារណៈ។ ការពិនិត្យឡើងវិញលើអនុក្រឹត្យដែលមានស្រាប់ និងគោលការណ៍ណែនាំដែលពាក់ព័ន្ធនឹងកម្រិតដែលបានកំណត់យ៉ាងច្បាស់លាស់នៃវិសាលភាព និងពេលវេលានៃការចូលរួមរបស់សាធារណៈជនគួរតែត្រូវបានផ្តួចផ្តើមភ្លាមៗសម្រាប់ការកែលម្អ។ ការពិនិត្យនេះក៏គប្បីបញ្ចប់ក្នុងរយៈពេលជាក់លាក់មួយ សម្រាប់ការទទួលបានការកែសម្រួលក្របខ័ណ្ឌឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ក្នុងនាមជាស្ថាប័នបទដ្ឋានគតិយុត្តិទទួលបន្ទុកត្រួតពិនិត្យការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការចូលរួមជាសាធារណៈ ក្រសួងអប់រំ យុវជន និងកីឡា គប្បីមានទំនួលខុសត្រូវចំពោះការធានានូវក្របខណ្ឌច្បាស់លាស់សម្រាប់ការចូលរួមជាសាធារណៈនៅក្នុងដំណាក់កាលនីមួយៗនៃដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ ពេលវេលា និងកម្រិតនៃវិសាលភាពនៃការចូលរួមជាសាធារណៈគួរតែផ្តល់ការណែនាំច្បាស់លាស់ដោយធានានូវតម្លាភាព និងការអនុវត្តជាក់ស្តែងនៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន។ នៅក្នុងអំឡុងពេលដំណើរការពិនិត្យពិគ្រោះយោបល់ និងសវនាការសាធារណៈ ដើម្បីប្រមូលព័ត៌មានត្រឡប់លើសំណើកែសម្រួលពីគ្រប់ភាគីពាក់ព័ន្ធទាំងអស់ក៏ត្រូវបានទាមទារឱ្យមានផងដែរ។

» ក្រសួងបរិស្ថាន និងស្ថាប័នពាក់ព័ន្ធរបស់រដ្ឋាភិបាល ដែលត្រួតពិនិត្យដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានត្រូវអនុវត្តលក្ខខណ្ឌសម្រាប់ម្ចាស់គម្រោងក្នុងការចែករំលែករបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយ។ ពួកគេត្រូវកំណត់គោលការណ៍ណែនាំច្បាស់លាស់ និងយន្តការត្រួតពិនិត្យត្រឹមត្រូវដើម្បីធានាបាននូវការប្រតិបត្តិ។ ស្ថាប័នរដ្ឋាភិបាលក៏គួរតែសម្របសម្រួលការផ្សព្វផ្សាយសេចក្តីព្រាងរបាយការណ៍ជាក់ជូនអង្គការមិនមែនរដ្ឋាភិបាល និងធានាឱ្យមានការបញ្ចូលគំនិតយោបល់ និងយោបល់របស់ពួកគេ។

### គ) សាធារណជន

» ខណៈដែលសាធារណជនដើរតួនាទីក្នុងដំណើរការធ្វើសេចក្តីសម្រេចចិត្ត ពួកគេទទួលខុសត្រូវតិចតួចបំផុត។ កង្វះខាតនៃក្របខណ្ឌច្បាស់លាស់ និងការទទួលបានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយគឺជាឧបសគ្គសម្រាប់សាធារណជនក្នុងការចូលរួម។ ម្យ៉ាងវិញទៀត ទោះបីជាមានឧបសគ្គទាំងនេះក៏ដោយ វាជាការចាំបាច់សម្រាប់

សាធារណជន ដែលត្រូវចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តសិទ្ធិរបស់ពួកគេ និងចូលរួមជាមួយភាគីពាក់ព័ន្ធផ្សេងទៀត។ នៅពេលដែលសាធារណជន ដើរតួនាទីយ៉ាងសកម្មក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានជាក់ស្តែង វានាំមកនូវទស្សនវិស័យចម្រុះ ចំណេះដឹង និងប្រយោជន៍នៅក្នុងកិច្ចពិភាក្សា។ ចំណុចនេះ នឹងបង្កើនប្រសិទ្ធភាពនៃដំណើរការធ្វើសេចក្តីសម្រេចចិត្ត ដោយរួមបញ្ចូលទាំងមតិយោបល់ និងកង្វល់ដ៏ធំទូលាយដែលនាំទៅរកលទ្ធផលល្អប្រសើរបន្ថែមទៀត។ ដោយបានចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន សាធារណជនក៏អាចដើរតួនាទីយ៉ាងសំខាន់ក្នុងការការពារសហគមន៍របស់ពួកគេដែរ។ ធាតុចូលរបស់ពួកគេ អាចជួយកំណត់ហានិភ័យដែលអាចកើតមាន និងស្នើសុំជម្រើសផ្សេងៗដែលសមស្របទៅនឹងតម្រូវការសហគមន៍។ លើសពីនេះទៀត ការចូលរួមរបស់ពួកគេអាចធ្វើឱ្យអ្នកធ្វើការសម្រេចទទួលខុសត្រូវ និងធានាថា គម្រោងនានាត្រូវបានធ្វើឡើងប្រកបដោយការទទួលខុសត្រូវ និងដោយបានគិតគូរចំពោះផលប៉ះពាល់សង្គម និងបរិស្ថាន។

» នៅពេលដែលច្បាប់ ស្តីពីសិទ្ធិទទួលបានព័ត៌មានត្រូវបានអនុម័ត សហគមន៍ក្រីក្រក្នុងទីក្រុងនឹងអាចស្នើសុំព័ត៌មានកាន់តែមានប្រសិទ្ធភាពអំពីគម្រោងអភិវឌ្ឍន៍ដែលប៉ះពាល់ដល់ពួកគេទាំងនោះ។ ព័ត៌មាននោះអាចជួយពួកគេក្នុងការកំណត់ផលប៉ះពាល់ដែលអាចកើតមាន និងចាត់វិធានការដើម្បីកាត់បន្ថយផលប៉ះពាល់ទាំងនោះ។ ការចូលរួមយ៉ាងសកម្មនេះធានាបាននូវការរក្សាការពារសិទ្ធិសុខុមាលភាពរបស់ពួកគេ ដូចមានចែងនៅក្នុងក្របខណ្ឌនេះ។

### ឃ) ម្ចាស់គម្រោង

» ម្ចាស់គម្រោង ត្រូវទទួលខុសត្រូវខ្ពស់បំផុតចំពោះការចែករំលែករបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយជាមួយសាធារណជនមុនពេលធ្វើការសម្រេចចិត្តសាងសង់ណាមួយ។ ពួកគេគួរតែធានាថារបាយការណ៍ទាំងនេះត្រូវមានលក្ខណៈពេញលេញ ដោយរួមបញ្ចូលទាំងទិន្នន័យ និងលទ្ធផលរកឃើញពាក់ព័ន្ធទាំងអស់។ ពួកគេក៏គួរតែផ្តល់សេចក្តីព្រាងរបាយការណ៍ដល់អង្គការមិនមែនរដ្ឋាភិបាលពាក់ព័ន្ធ ក្នុងរយៈពេលតិច៣០ថ្ងៃមុនការចេញផ្សាយជាសាធារណៈ ដោយអនុញ្ញាតឱ្យមានពេលវេលាសមស្របសម្រាប់ការពិនិត្យ និងព័ត៌មានត្រឡប់។ ម្ចាស់គម្រោងក៏ត្រូវបង្កើតវេទិកាអនឡាញ ដែលពួកគេអាចបង្ហោះ និងបោះពុម្ពផ្សាយរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានចុងក្រោយ។ ចំណុចនេះ គួរតែធានានូវភាពងាយស្រួលសម្រាប់សាធារណជន និងអង្គការមិនមែនរដ្ឋាភិបាលក្នុងការចូលទៅកាន់កម្មវិធី។

### ង) កម្ពុជា

» រដ្ឋាភិបាលកម្ពុជាត្រូវទទួលខុសត្រូវខ្ពស់បំផុតក្នុងការពន្លឿនវឌ្ឍនភាពឆ្ពោះទៅរកក្របខណ្ឌវាយតម្លៃហេតុប៉ះពាល់បរិស្ថានប្រកបដោយប្រសិទ្ធខ្ពស់។ ជំហានសំខាន់មួយ គឺការអនុម័តលើសេចក្តីព្រាងច្បាប់ស្តីពីសិទ្ធិទទួលបានព័ត៌មាន។ ដូចបានបញ្ជាក់នៅក្នុងឯកសាររបស់លោក Kay Mathiesen ស្តីពីសិទ្ធិទទួលបានព័ត៌មាន ចាត់ជាសិទ្ធិមនុស្ស សិទ្ធិទទួលបានព័ត៌មាន លើសពីសិទ្ធិសេរីភាពក៏ជាសិទ្ធិទទួលបានសុខុមាលភាពផងដែរ។

» ដោយបានផ្តល់សច្ចាប័នលើសិទ្ធិទទួលបានព័ត៌មាន រដ្ឋាភិបាលកម្ពុជាអាចផ្តល់សិទ្ធិអំណាច

ដល់ប្រជាពលរដ្ឋជាពិសេសសហគមន៍ក្រីក្រក្នុងទីក្រុងដើម្បីទទួលបានព័ត៌មានដោយស្របច្បាប់អំពីគម្រោងអភិវឌ្ឍន៍ផ្សេងៗនៅក្នុងជុំវិញតំបន់របស់ពួកគេ។ ការផ្តល់សិទ្ធិអំណាចនេះអាចឱ្យជួយសាធារណជនជាពិសេសសហគមន៍ក្រីក្រក្នុងទីក្រុងស្វែងរកព័ត៌មានអំពីបំណងនៃគម្រោង ផលប៉ះពាល់ដែលអាចកើតមាន និងយុទ្ធសាស្ត្រសម្រាប់ការកាត់បន្ថយ។ ហេតុដូច្នេះ រដ្ឋាភិបាលកម្ពុជាគួរតែពន្លឿនដំណើរការផ្តល់សច្ចាប័នលើសិទ្ធិទទួលបានព័ត៌មានឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

» ដោយអនុលោមតាមក្របខណ្ឌការពារ គោរព និងដោះស្រាយ ការគាំទ្រសិទ្ធិដោយរដ្ឋាភិបាលគប្បីឱ្យស្របតាមគោលការណ៍នៃការទទួលខុសត្រូវរបស់សាជីវកម្ម នៅក្នុងការគោរពសិទ្ធិមនុស្ស និងកាតព្វកិច្ចរបស់រដ្ឋក្នុងកិច្ចការពារ ដោយរួមចំណែកដល់ដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថានឱ្យកាន់តែទូលំទូលាយ។



របាយការណ៍ស្រាវជ្រាវ ឆ្នាំ២០២៣

# ការគ្រប់គ្រងសំរាម

## នៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII

## ប្រភព និងដំណោះស្រាយ

# តារាងមាតិកា


០១ សេចក្តីផ្តើម..........១

០២ គោលបំណង..........២

០៣ ចំណោទបញ្ហា..........៣

០៤ ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងសំរាមក្នុងទីក្រុងភ្នំពេញ..........៤

០៥ វិធីសាស្ត្រស្រាវជ្រាវ..........៥

០៦ លទ្ធផលនៃការស្រាវជ្រាវ..........៦

៦.១. ព័ត៌មាននៃសហគមន៍បឹងឈូកមានជ័យថ្មីII..........៦

៦.២. ប្រភពសំរាមចម្បងៗនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មី II.....៨

១. សំរាមដែលប្រជាសហគមន៍បានបោលផ្តេសផ្តាសតាំងពីមុន និងបន្តមានដល់បច្ចុប្បន្ន..........៨

២. សំរាមរឹង និងសំរាមរាវដែលហូរចូលមកក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII ដោយសារការសាងសង់សំណង់ បុរី ប៉េងហួត តាំងពីឆ្នាំ២០១២..........៩

៣. ប្រភពសំរាមដែលផុសចេញពីដីតាមការអេះអាងរបស់ប្រជាសហគមន៍..........១០

៦.៣. ផលប៉ះពាល់និងក្តីបារម្ភពីបញ្ហាសំរាម..........១១

៦.៤. មធ្យោបាយក្នុងការលុបបំបាត់សំរាមចេញពីសហគមន៍..........១១

០៧ សេចក្តីសន្និដ្ឋាន..........១៤

០៨ អនុសាសន៍..........១៥

# ១. សេចក្តីផ្តើម



ការសិក្សានេះធ្វើឡើងក្នុងគោលបំណងសិក្សាពី បញ្ហាប្រឈមរបស់ប្រជាពលរដ្ឋ ដែលកំពុងរស់នៅក្នុងសហគមន៍ក្រីក្រ និងមានលំនៅឋានលើគំនរសំរាមលាយឡំជាមួយនឹងទឹកកខ្វក់ដោយមិនទាន់ដឹងពីប្រភពសំរាមច្បាស់លាស់ ។ សម្រាប់ការសិក្សាស្រាវជ្រាវពីបញ្ហាសំរាមនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII កាលពីឆ្នាំមុនមិនបានសិក្សាស៊ីជម្រៅទៅលើប្រភពសំរាមនោះទេ ដូច្នេះការសិក្សាស្រាវជ្រាវមួយនេះផ្តោតសំខាន់លើប្រភពសំរាម និងបញ្ហាប្រឈមរបស់ប្រជាសហគមន៍បឹងឈូកមានជ័យថ្មីII។ ក្នុងការសិក្សានេះរំពឹងទុកថានឹងទទួលបានលទ្ធផលក្នុងការសិក្សាពីប្រភពដែលបង្កឱ្យមានសំរាមនៅក្នុងសហគមន៍ និងជាប្រយោជន៍ក្នុងការដោះស្រាយជូនសហគមន៍បឹងឈូកមានជ័យថ្មីII និងសហគមន៍ដែលមានស្ថានភាពស្រដៀងៗគ្នានៅក្នុងរាជធានី ភ្នំពេញ។

បញ្ហាសំរាមរឹង និងបញ្ហាសំរាមរាវជាបញ្ហាមួយដែលអ្នករស់នៅទីក្រុងកំពុងជួបប្រទះ ហើយកាន់តែប្រឈមខ្លាំងទៀតនោះគឺសហគមន៍ក្រីក្រ ក្នុងនោះសហគមន៍បឹងឈូកមានជ័យថ្មី II ដែលមានទីតាំងក្នុង សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ក្រោយវិទ្យាល័យច្បារអំពៅ ដែលមានចំនួនប្រជាពលរដ្ឋ៣៣ខ្នងផ្ទះកំពុងតែប្រឈមនឹងបញ្ហាប្រភពសំរាមដែលធ្វើឱ្យសហគមន៍បន្តរងគ្រោះដោយសារសំរាម។ តាមការសិក្សាពីការគ្រប់គ្រង់សំរាមនិងអភិបាលកិច្ចនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មី II បានឱ្យដឹងថាស្ថានភាពសហគមន៍មានសំរាមគ្រប់ទីកន្លែងនៅក្នុងសហគមន៍ និងក្រោមផ្ទះរបស់ពួកគាត់រយៈពេល៣០ឆ្នាំ ដែលជាសំរាមមានប្រភពមិនច្បាស់លាស់ និងមិនអាចប្រមូលចេញអស់ មិនមានប្រព័ន្ធលូសម្រាប់បង្ហូរទឹកចេញ និងសំរាមភាគច្រើនដែលមាននៅក្នុងទឹកក្រោមផ្ទះរបស់ប្រជាសហគមន៍មិនមានប្រភពច្បាស់លាស់។[១] យោងតាមមូលហេតុទាំងអស់នេះហើយទើបធ្វើឱ្យមានការសិក្សាស្រាវជ្រាវពីប្រធានបទខាងលើ ក្នុងការស្វែងរកបញ្ហាពិតប្រាកដដែលជាប្រភពបង្កឱ្យមានសំរាមនៅក្នុងសហគមន៍។ សំរាមជាបញ្ហាមួយដែលពិបាកក្នុងការដោះស្រាយសម្រាប់ប្រជាសហគមន៍បឹងឈូកមានជ័យថ្មីII ដែលមានលំនៅឋាននៅលើគំនរសំរាមដែលមានលាយជាមួយទឹកជាច្រើនឆ្នាំ។

តាមរយៈលទ្ធផលនៃការស្រាវជ្រាវពីឆ្នាំមុន បញ្ហាសំរាមនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII បានបង្ហាញថាសហគមន៍មានប្រភពសំរាមមិនច្បាស់លាស់ ដែលប្រភពសំរាមនេះជាកត្តាដ៏សំខាន់ក្នុងការសិក្សាសម្រាប់ការដោះស្រាយសំរាមផងដែរ។ ជាពិសេសសហគមន៍ក៏ជាទីតាំងមួយដែលមានសណ្ឋានដីទាប ងាយស្រួលក្នុងការហូរទឹកចូល និងហូរនាំមកសំរាមចូលក្នុងសហគមន៍រាល់ពេលមានភ្លៀងធ្លាក់ផងដែរ។

១ អង្គការសមាគមធាងត្នោត ឆ្នាំ២០២២ របាយការណ៍ស្តីពី៖ អភិបាលកិច្ចបរិស្ថានល្អក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង'

# ២. គោលបំណង



### ការស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណង៖

- ស្វែងរកប្រភពសំរាម និងកត្តាដែលបង្កឱ្យមានសំរាមនៅក្នុងសហគមន៍
- ផលប៉ះពាល់នៃសំរាមចំពោះប្រជាសហគមន៍
- ដំណោះស្រាយក្នុងការប្រមូលសំរាមចេញពីសហគមន៍

# ៣. បំណោទបញ្ហា



### សម្រាប់ការសិក្សាស្រាវជ្រាវប្រធានបទខាងលើធ្វើឡើងក្នុងការឆ្លើយតបនឹងសំណួរពធំៗ៖

- តើសំរាមដែលមាននៅក្នុងសហគមន៍មានប្រភពមកពីណាខ្លះ ?
- តើសំរាមមានផលប៉ះពាល់អ្វីខ្លះដល់ប្រជាសហគមន៍ ?
- តើអាជ្ញាធរមូលដ្ឋាននិងប្រជាសហគមន៍មានដំណោះស្រាយយ៉ាងណាខ្លះចំពោះបញ្ហាប្រភពសំរាម ?

# ៤.ទិដ្ឋភាពទូទៅនៃការគ្រប់គ្រងសំរាមក្នុងទីក្រុងភ្នំពេញ



ការគ្រប់គ្រងកាកសំណល់នៅតែបន្តជាបញ្ហាប្រឈមសម្រាប់សហគមន៍ក្រីក្រនៅក្នុងរាជធានីភ្នំពេញ និងនៅបណ្តាទីក្រុងផ្សេងទៀតក្នុងប្រទេសកម្ពុជា និងអត្រាប្រហែល ៣៥.៧ ភាគរយនៃសហគមន៍ក្រីក្រក្នុងរាជធានីភ្នំពេញនៅមិនទាន់ទទួលបានសេវាគ្រប់គ្រងកាកសំណល់បានគ្រប់គ្រាន់នោះទេ។[២] សំរាមសំណល់រឹងនៅទីប្រជុំជនកម្ពុជាចំនួនប្រមាណ ២លានតោន/ឆ្នាំ (ឆ្នាំ២០១៩) ត្រូវបានប្រមូល និងមានអត្រាកំណើនប្រមាណជា ១៥% ក្នុងមួយឆ្នាំ។[៣] ក្នុងនោះ ការកើនឡើងនូវកាកសំណល់នៅតាមផ្លូវទឹកក្នុងមូលដ្ឋានអាចបង្កឱ្យមានការលិចទឹកក្នុងរដូវវស្សា។[៤]

ក្នុងករណី "សិក្សាប្រឡាយខ្មៅសម្រាប់សហគមន៍សាមគ្គីរុងរឿង" ដែលមានប្រជាពលរដ្ឋ ២៩៧ នាក់ដែលមានផ្ទះសម្បែងសាង់សង់នៅលើទឹកដែលមានផ្លាស្ទិកពណ៌សអណ្តែតព្រោងព្រាត ហើយស្មោរសំរាមយ៉ាងក្រាស់ខ្មីក និងមានភ្លៀងលិចផ្ទះ នៅរដូវវស្សាជាមួយចំនួនសំរាមយ៉ាងច្រើនផងដែរ។[៥] តាមលទ្ធផលនៃការស្រាវជ្រាវក្នុងឆ្នាំ២០២២ បានបង្ហាញថាសហគមន៍បឹងឈូកមានជ័យថ្មីII មានសំរាមគ្រប់ទីកន្លែងដែលមានក្លិនស្អុយរលួយនៅក្នុងទឹកខាងក្រោមផ្ទះរបស់ប្រជាសហគមន៍ ដែលគំនរសំរាមទាំងនោះជាគំនរសំរាមចាស់លាយគំនរសំរាមថ្មី។[៦] ទីតាំងរបស់សហគមន៍មិនមានប្រព័ន្ធលូសម្រាប់បង្ហូរទឹក ឬ រំដោះចេញនោះទេដែលធ្វើឱ្យកម្ពស់ទឹកលិចកាន់តែជិតរនាបផ្ទះ ពេលដែលមានភ្លៀងធ្លាក់។

តាមការអង្កេតពីស្ថានភាពរបស់សហគមន៍មានសំរាមជាច្រើននៅក្រោមផ្ទះរបស់ប្រជាពលរដ្ឋដែលមិនដឹងថាសំរាមទាំងអស់នោះមកពីណា និងមិនដឹងថាហូរមកពីណាទេ រាល់ពេលមានភ្លៀងធ្លាក់រួចកាន់តែមានសំរាមច្រើននៅក្រោមផ្ទះរបស់ពួកគាត់។[៧]

---

២ អង្គការសមាគមធាងត្នោត ឆ្នាំ២០១៥ របាយការណ៍តួលេខនិងការពិត ២៦៖ ការប្រមូល និងគ្រប់គ្រងកាក់សំណល់រឹង
៣ គោលនយោបាយស្តីពីការគ្រប់គ្រងសំរាមសំណល់រឹងទីប្រជុំជន២០២០-២០៣០: https://www.moe.gov.kh/wp-content/uploads/2021/02/160221.pdf
៤ សៀវភៅណែនាំ ស្តីអំពីការគ្រប់គ្រងកាកសំណល់សម្រាប់សហគមន៍ក្រីក្រនៅក្នុងទីក្រុង: https://teangtnaut.org/wp-content/uploads/2019/08/STT-Waste-Management-Community-Booklet-Kh-Final_.pdf
៥ អភិបាលកិច្ចទីក្រុង៖ ការគ្រប់គ្រងកាកសំណល់នៅក្នុងរាជធានីភ្នំពេញ: https://teangtnaut.org/wp-content/uploads/2019/01/20190129_STT_Final_Report_Urban_Governance_Wast_Managerment_PP_Khmer-compressed.pdf
៦ អង្គការសមាគមធាងត្នោត ឆ្នាំ២០២២ របាយការណ៍ស្តីពី៖ អភិបាលកិច្ចបរិស្ថានល្អក្នុងសហគមន៍ក្រីក្រក្នុងទីក្រុង'
៧ ដូចខាងលើ

# ៥. វិធីសាស្ត្រស្រាវជ្រាវ



ការសិក្សាស្រាវជ្រាវនេះ ធ្វើឡើងតាមរយៈការសម្ភាសជាមួយប្រជាសហគមន៍ចំនួន៣៣ខ្នងផ្ទះ។ ការសម្ភាសត្រូវបានសុំការអនុញ្ញាតពីអាជ្ញាធរមូលដ្ឋាន (ប្រធានភូមិ) មុនធ្វើការសម្ភាសតាមផ្ទះរបស់ប្រជាសហគមន៍។

ការសិក្សាស្រាវជ្រាវ ដែលបានបង្ហាញនៅក្នុងរបាយការណ៍នេះធ្វើឡើងនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII សង្កាត់និរោធ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។ ការប្រមូលទិន្នន័យត្រូវបានប្រព្រឹត្តឡើងចំនួនបីលើកដែលលើកទីមួយបានប្រព្រឹត្តឡើងនៅថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០២៣ ដែលមានការចុះសាកល្បងរាល់កម្រងសំណួរទាំងអស់។ សម្រាប់ពីរលើកទៀតបានប្រព្រឹត្តឡើងនៅថ្ងៃទី១១ និងថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០២៣។ ការសម្ភាសនីមួយៗប្រើប្រាស់រយៈពេលចន្លោះពី៣០ទៅ ៤៥នាទី និងប្រើប្រាស់វិធីសាស្ត្រគុណវិស័យតាមរយៈការសម្ភាសបុគ្គលដែលមានអ្នកផ្តល់បទសម្ភាសសរុបមានចំនួន ២៦នាក់ ក្នុងនោះមានប្រជាសហគមន៍ចំនួន ២៤នាក់ក្នុងចំណោម៣៣ខ្នងផ្ទះមានស្ត្រី ១៨នាក់ និង បុរស៦នាក់ ដែលបានចូលរួមសម្ភាស អាជ្ញាធរមូលដ្ឋានម្នាក់ និងបុគ្គលិកក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីម្នាក់។ ការប្រមូលទិន្នន័យទាំងអស់នៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII ធ្វើឡើងដោយប្រើប្រាស់កម្រងសំណួរបីផ្នែកធំៗ។ កម្រងសំណួរទី១ គឺសម្រាប់ការសម្ភាសទៅកាន់ប្រជាពលរដ្ឋ កម្រងសំណួរទី២ គឺសម្រាប់ការសម្ភាសទៅកាន់អាជ្ញាធរមូលដ្ឋាន និងកម្រងសំណួរទី៣ គឺសម្រាប់ការសម្ភាសទៅកាន់ក្រុមហ៊ុនប្រមូលសំរាម។ កម្រងសំណួរទាំងបីបានផ្តោតសំខាន់ទៅលើការសាកសួរពីព័ត៌មានទូទៅរបស់ប្រជាសហគមន៍ ការស្វែងរកប្រភព និងកត្តាដែលបង្កឱ្យមានសំរាម ផលប៉ះពាល់នៃសំរាមចំពោះប្រជាសហគមន៍ ដំណោះស្រាយក្នុងការប្រមូលសំរាម។

ទិន្នន័យទាំងអស់ដែលយកមកប្រើប្រាស់បានយកទៅរៀបចំបញ្ចូល ធ្វើការវិភាគនៅក្នុងកម្មវិធី Excel និងវិភាគទិន្នន័យទាំងអស់សម្រាប់ការសរសេររបាយការណ៍។ ដើម្បីធានាការប្រមូលទិន្នន័យប្រព្រឹត្តទៅដោយភាពមិនលម្អៀង និងអនុវត្តប្រកបដោយក្រមសីលធម៌ក្នុងការស្រាវជ្រាវ គឺមានការរក្សាទុកជាសម្ងាត់ពីព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកផ្តល់បទសម្ភាស ការគ្រប់ឯកសារទិន្នន័យទាំងអស់ត្រូវបានរក្សាទុកនៅកន្លែងដែលមានសុវត្ថិភាព និងមិនមានការបែកធ្លាយចេញនោះទេ។

ក្នុងពេលសម្ភាសមានការចូលរួមដោយស្ម័គ្រចិត្ត ការពន្យល់ និងបញ្ជាក់ពីគោលបំណងយ៉ាងច្បាស់លាស់ទៅកាន់ប្រជាសហគមន៍មុនការចាប់ផ្តើមសម្ភាស។

# ៦. លទ្ធផលនៃការស្រាវជ្រាវ



## ៦.១. ព័ត៌មាននៃសហគមន៍បឹងឈូកមានជ័យថ្មីII

សហគមន៍បឹងឈូកមានជ័យថ្មីII មានទីតាំងស្ថិតនៅក្រោយវិទ្យាល័យច្បារអំពៅដែលមានច្រកចូល តាមផ្លូវលំតូចមួយនៅលើបណ្ដាយផ្លូវជាតិលេខ១។ សហគមន៍មានទីតាំងនៅភូមិបឹងឈូក សង្កាត់និរោធ ខណ្ឌច្បារអំពៅ។ សហគមន៍បឹងឈូកមានជ័យថ្មីII មានចំនួនប្រជាជនសរុប២៥៦នាក់ ត្រូវនឹង ៤៨គ្រួសារ និង ៣៣ខ្នងផ្ទះ ហើយមានទំហំទទឹងប្រវែង ៧៥ម៉ែត្រ និងបណ្ដាយប្រវែង ៤៥ម៉ែត្រ ក្នុងនោះមានផ្ទៃក្រឡាសរុប ៣ ៣៧៥ ម៉ែត្រការ៉េ ដែលមានព្រំប្រទល់ជាប់នឹងរបងវិទ្យាល័យច្បារអំពៅ និងម្ខាងទៀតជាប់នឹងមាត់ប្រឡាយទឹករហូតដល់គល់ស្ពាន។ បើយើងពិនិត្យមើលទៅច្រកចូលក្នុងសហគមន៍គឺជាផ្លូវលំតូចមួយដែលអាចបើកបរបានត្រឹមតែម៉ូតូ តុតុ ឬ រ៉ឺម៉កតែប៉ុណ្ណោះ។

ក្នុងនោះតាមការសាកសួរទៅកាន់ប្រជាសហគមន៍ពីប្រវត្តិរបស់ទីតាំងសហគមន៍បានឱ្យដឹងថាពេលដែលពួកគាត់មកសាងសង់លំនៅឋានគឺបានឃើញថាសហគមន៍មានស្ថានភាពលិចទឹកលាយជាមួយសំរាម ដែលពួកគាត់បានគិតថាសហគមន៍ពីមុនមកអាចជាបឹង ប្រឡាយ ឬជាអូរ។ ប៉ុន្តែក្នុងនោះមានប្រជាសហគមន៍ពីរនាក់បានអះអាងផ្ទុយទៅវិញថាទីតាំងសហគមន៍គឺជាដីគោក នឹងជាដីក្រុមសាមគ្គីដែលពេលនោះប្រជាពលរដ្ឋអាចធ្វើស្រែចំការ ដាំដំណាំ



ផ្លូវចូលច្រកសហគមន៍បឹងឈូកមានជ័យថ្មីពីរ

និងខាងវិទ្យាល័យច្បារអំពៅ ក៏បានសុំដីនៅក្នុងសហគមន៍មួយផ្នែកសម្រាប់សិស្សក្នុងការដាំដំណាំ ពោត ចេក ល្ពៅផងដែរ។ គាត់បានរៀបរាប់ថាសហគមន៍មិនមានការលិចទឹកដក់ជាប់រហូតដូចបច្ចុប្បន្ននោះទេ ។

សហគមន៍មានទឹកលិចក្នុងកំឡុងពេល៣ខែ ដែលមានទឹកឡើងខ្លាំងពីទន្លេ ក្នុងនោះមាននៅខែ ៧ ៨ ៩ និងមានការហូរនាំសំរាមមកតាមទឹកបន្ថែមដែរ។ ប៉ុន្តែពេលដែលទឹកទន្លេ

ចាប់ផ្តើមស្រកទឹកទាំងអស់នៅក្នុងសហគមន៍ក៏បានស្រកចេញទៅវិញ និងនាំសំរាមទាំងអស់ទៅជាមួយតាមប្រឡាយដែលគេហៅថាប្រឡាយព្រែកបាំរាំងដែលជាប្រព័ន្ធខ្សែទឹកហូរចេញរបស់សហគមន៍ ។



បន្ទាប់ពីផុតរយៈពេល បីខែនោះទៅប្រជាពលរដ្ឋអាចធ្វើការដាំដុះបានជាធម្មតា។ ចំណែកប្រជាសហគមន៍ម្នាក់បានបញ្ជាក់ថាពីមុនមកសហគមន៍ជារណ្តៅមួយដែលបណ្តាលមកពីមាការជីកដីយកទៅលក់ដែលធ្វើឱ្យផ្ទះរបស់គាត់មានជម្រៅជ្រៅជាងគេ។ លើសពីនេះប្រជាសហគមន៍បានបន្ថែមថាសហគមន៍មានការលិចទឹកជាប់មិនទៅណាដូចសព្វថ្ងៃនេះទើបតែរយៈពេល១០ឆ្នាំចុងក្រោយនេះដែលគិតចាប់តាំងពីឆ្នាំ២០១២មក មានការអភិវឌ្ឍន៍សំណង់ បុរី ប៉េងហួត ដែលធ្វើឱ្យទឹកនៅតំបន់នោះបានហូរមកក្នុងសហគមន៍ព្រមជាមួយសំរាមជាច្រើន ដោយសារតំបន់ដែលបុរី ប៉េងហួតធ្វើការសាងសង់ជាបឹងដ៏ធំមួយ ហើយតំបន់របស់សហគមន៍មានលក្ខណៈទាប នាំឱ្យចរន្តទឹកទាំងអស់ហូរមកតំបន់របស់សហគមន៍ព្រមទាំងមានសំរាមមកបន្ថែមដែលបណ្តាលឱ្យកកស្ទះដោយសំរាមមិនអាចហូរទៅតាមប្រឡាយបាននិងមានការលិចដែលពេលនោះមិនត្រឹមតែមានការលិចនៅក្នុងសហគមន៍ប៉ុណ្ណោះទេ គឺការលិចពាសពេញតំបន់ទាំងអស់ដែលនៅជិតសហគមន៍។

តាមការសង្កេត របស់ប្រជាពលរដ្ឋសម្រាប់បច្ចុប្បន្ននេះមិនមានការហូរចេញ និងហូរចូលនៃទឹក និងសំរាមពីព្រែកឬប្រឡាយណាមួយចូលមកក្នុងសហគមន៍នោះទេ គឺសំរាមទាំងអស់មានចំនួនដដែល។ រាល់ពេលភ្លៀងធ្លាក់ទើបធ្វើឱ្យកម្ពស់ទឹកនៅសហគមន៍ខ្ពស់តាមចំនួនទឹកភ្លៀងដែលនៅដក់ជាប់រហូតដោយមិនមានការហូរចេញនោះទេ។ ការសាកសួរទៅកាន់អាជ្ញាធរមូលដ្ឋាន (មេភូមិ) គាត់បានរៀបរាប់ថាសហគមន៍ចាប់ផ្តើមបង្កើតឡើងនៅឆ្នាំ១៩៩២ដែលមានលំនៅឋាន១៤ខ្នងផ្ទះប៉ុណ្ណោះ។ ទីតាំងសហគមន៍ជាប្រភេទដីក្រុមសាមគ្គីដែលទុកសំរាប់ធ្វើកសិកម្មនិងធ្វើស្រែចំការផងដែរ។ ខណៈពេលនោះ ដែលទីតាំងសហគមន៍មានដីទំនេរច្រើន និងមានលំនៅឋានតិចដែលធ្វើឱ្យនាយកសាលាវិទ្យាល័យច្បារអំពៅបានសុំដីមួយផ្នែក មានទំហំផ្ទៃក្រឡា ៤០០ម៉ែត្រការេសម្រាប់ទុកឱ្យសិស្សានុសិស្សធ្វើពលកម្មដោយសុំឱ្យមានការដាំពោតនៅលើដីរបស់សហគមន៍។ ប៉ុន្តែការដាំពោតនោះបានតែមួយរយៈ បែជាខាងសាលាលួចជីកដីនៅកន្លែងនោះយកទៅធ្វើជាអាជីវកម្មទៅវិញ។ ពេលដែលមានសកម្មភាពបែបនេះកើតមានឡើងនៅក្នុងសហគមន៍ បានធ្វើឱ្យប្រជាសហគមន៍មិនសប្បាយចិត្តនិងទង្វើខាងសាលានោះទេ ដោយមានការប្រឆាំងតវ៉ាចំពោះបញ្ហានេះ។ ការជីកដីលក់នេះប្រហែលជាមានចំនួនចន្លោះ២០ទៅ៣០ឡាន ដែលធ្វើឱ្យសណ្ឋានដីនៅក្នុងសហគមន៍មួយផ្នែកនោះមានលក្ខណៈទាបជាងគេ និងមានជម្រៅប្រហែលជា២ម៉ែត្រ។

រាល់សំរាមដែលប្រើប្រាស់រួចគឺមានការប្រមូលយកទៅចោលនៅឯគល់ស្ពាន ហើយតែងតែមានការប្រមូលដុតចោលនៅទីនោះព្រោះជាដីទំនេរ។

សហគមន៍មិនមានស្ថានភាពធ្ងន់ធ្ងរដូចបច្ចុប្បន្ននោះទេ បើទោះបីជាធ្លាប់មានទឹកជំនន់ជនលិចខ្លាំងកាលពីឆ្នាំ២០០០ក៏មានការលិចត្រឹមតែ៩ថ្ងៃតែប៉ុណ្ណោះ និងបាននាំយកសំរាមដែលនៅក្នុងសហគមន៍ទៅថែមទៀត ព្រោះមានប្រកទឹកសម្រាប់ហូរពីក្នុងសហគមន៍ទៅក្នុងប្រឡាយចូលទៅតាមបឹង។

ប៉ុន្តែស្ថានភាពកាន់តែធ្ងន់ធ្ងរ គឺបញ្ហាសំរាមលាយជាមួយទឹកនេះចាប់ផ្តើមមានតាំងពីពេលបុរីប៉េងហួតបានចាប់ផ្តើមមានការសាងសង់ក្នុងឆ្នាំ២០១២មក គឺបានធ្វើឱ្យទឹកលិចពាសពេញទាំងអស់នៅតំបន់សហគមន៍ ព្រមទាំងផ្លូវដែលធ្វើដំណើរអស់រយៈ៣ឆ្នាំ ព្រោះមានការបូមខ្សាច់ ចាក់ដី ដែលធ្វើឱ្យទឹកទាំងអស់បានធ្លាក់មកលិចនៅក្នុងសហគមន៍ ក្នុងនោះមិនត្រឹមតែទឹកនោះទេគឺនាំមកសំរាម និងទឹកប្រើប្រាស់របស់កម្មករសំណង់ផងដែរ។

សម្រាប់បច្ចុប្បន្នទឹកជាមួយសំរាមមិនមានការហូរចេញហូរចូលបាននោះទេ គឺមានលក្ខណៈនៅនឹងដោយសារមានការចាក់ដីបំពេញរបស់ម្ចាស់ផ្ទះ និងធ្វើជារបងថ្មដែលនៅជិតនឹងមាត់ប្រឡាយដែលជាមុខទឹកហូរចេញរបស់សហគមន៍គឺកាន់តែធ្វើឱ្យមានការបិទមុខទឹកអស់មួយផ្នែកនៅសល់តែមួយផ្នែកតូចដែលជាប្រព័ន្ធខ្សែទឹកសម្រាប់ហូរចេញ។

លើសពីនេះក៏មានសំរាមកកស្ទះបន្ថែមនៅទីតាំងនោះផងដែរ។ ក្នុងនោះនៅក្បែរសហគមន៍មានប្រឡាយមួយដែលមានឈ្មោះថាប្រឡាយព្រែកបារាំងដែលមានប្រវែងពី បុរី ប៉េងហួតទៅដល់វិទ្យាល័យច្បារអំពៅ ដែលទីតាំងប្រឡាយនេះអាចហូរនាំទឹកពីប្រព័ន្ធលូមួយខ្សែដែលមាននៅលើផ្លូវលំរបស់សហគមន៍ទៅកាន់ប្រព័ន្ធលូធំដែលគេហៅថាផ្លូវថ្មីនោះទៅដល់ទន្លេ។ ប៉ុន្តែប្រព័ន្ធលូមួយខ្សែខាងលើផ្លូវលំ របស់សហគមន៍មិនអាចតភ្ជាប់បានគ្រប់លំនៅឋានរបស់ប្រជាសហគមន៍ទាំងអស់ទេ គឺអាចជួយសម្រួលបានតែលំនៅឋានដែលមានទីតាំងនៅខាងមុខផ្លូវ និងពេលដែលមានភ្លៀងធ្លាក់តែប៉ុណ្ណោះ។



បំពង់ទុយោលទឹកតភ្ជាប់ពីផ្ទះមកខាងក្រោម

## ៦.២.ប្រភពសំរាមចម្បងៗនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មី II

យោងតាមការសិក្សាស្រាវជ្រាវបានបង្ហាញថាប្រភពដែលបង្កឱ្យមានសំរាមនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII មានចំនួនបីធំៗគឺ ៖

### ១.សំរាមដែលប្រជាសហគមន៍បានចោលផ្តេសផ្តាសតាំងពីមុន និងបន្តមានដល់បច្ចុប្បន្ន

បើក្រឡេកមកពិនិត្យពីស្ថានភាពរបស់

សហគមន៍បឹងឈូកមានជ័យថ្មីII ពិតជាបន្តមានសំរាមជាច្រើន ជាពិសេសនៅក្រោមផ្ទះរបស់ប្រជាសហគមន៍ ដែលសំរាមទាំងនេះជាប្រភេទសំរាមរឹង និងសំរាមរាវដែលមានដូចជា សំបកដប ថង់ប្លាស្ទិក ស្មៅ និងទឹកដែលមានពណ៌ខ្មៅនៅលាយឡំជាមួយគ្នាដែលមានក្លិនស្អុយជាច្រើនឆ្នាំមក គឺបណ្តាលមកពីការចោលផ្តេសផ្តាសរបស់ប្រជាសហគមន៍តាំងពីដើមទៅខាងក្រោមផ្ទះរៀងៗខ្លួនអស់រយៈពេលជាច្រើនឆ្នាំមកហើយ ព្រោះការប្រមូលសំរាមពីក្រុមហ៊ុនប្រមូលសំរាមទើបតែមានប្រហែលរយៈពេល ១ទៅ២ ឆ្នាំចុងក្រោយប៉ុណ្ណោះ។ បើទោះបីជាប្រជាសហគមន៍បានអះអាងថាបច្ចុប្បន្នពួកគាត់មានការរៀបចំទុកដាក់សំរាម និងមិនបានចោលផ្តេសផ្តេសដូចពីមុនក្តី ប៉ុន្តែតាមការអង្កេតពីស្ថានភាពគំនរសំរាមនៅខាងក្រោមផ្ទះរបស់ប្រជាសហគមន៍យើងនៅតែឃើញមានសំរាមថ្មីៗដែលពួកគាត់នៅតែបន្តចោលទៅក្រោមផ្ទះជារៀងរាល់ថ្ងៃ។

“សមាជិកប្រជាសហគមន៍ម្នាក់អះអាងថា ពីមុនមានទៅណា មានតែក្រោមផ្ទះនឹងចេះដាក់ក្រោមផ្ទះ អត់មានដីចាក់មានតែដាក់សំរាម។”


គំនរសំរាមដែលមានសំរាមចាស់និងថ្មីលាយគ្នា

## ២. សំរាមរឹង និងសំរាមរាវដែលហូរចូលមកក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII ដោយសារការសាងសង់សំណង់ បុរី ប៉េងហួត តាំងពីឆ្នាំ២០១២

ការសាង់សង់សំណង់បុរី ប៉េងហួត ពិតជាប្រភពបង្កឱ្យសំរាមរឹង និងសំរាមរាវជាច្រើនដែលបានហូរចូលមកក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII ដោយសារការបូមខ្សាច់ ការចាក់ដីបំពេញ និងទឹកប្រើប្រាស់របស់កម្មករផងដែរ។ បើទោះបីជាទឹកអាចហូរចេញទៅតាមប្រឡាយក្តីតែការដែលទឹកហូរពីខាងបុរី ប៉េងហួតបាននាំមកសំរាមជាច្រើនដែលបានបណ្តាលឱ្យកកស្ទះមុខទឹកហូរចេញរបស់ប្រឡាយព្រែកបារាំងដែលនៅក្បែរសហគមន៍ធ្វើឱ្យការហូរចេញមានសភាពយឺត និងមានចំនួនតិច។

ជាពិសេសទីតាំងសហគមន៍មានសណ្ឋានដីទាបជាងគេក្នុងតំបន់ដែលធ្វើឱ្យមានទឹកលិចដក់ជាប់មិនអាចហូរចេញបានដូចតំបន់ផ្សេងទៀតដែលមានសណ្ឋានដីខ្ពស់ជាងសហគមន៍។

“សមាជិកប្រជាសហគមន៍ម្នាក់អះអាងថា ដីគោក ពេលបុរីធ្វើលិចទឹក មានបឹងធំមួយប្រឡាយអត់មានទេសំរាមដីគោក។”

“អាជ្ញាធរមូលដ្ឋាន៖ “ពីមុនអត់មានទេមកផ្ទះនៅក្រោយទេ អាចបង្ហូរចេញតែពេលមាន ប៉េង ហួតដក់តាមផ្ទះតាំង២០១២មានទឹកលាយសំរាមចូលភូមិ”។”

បើក្រឡេកមកពិនិត្យមើលស្ថានភាពក្នុងសហគមន៍បានឱ្យដឹងថាមានចំនួន ៧០% នៃចំនួនខ្នងផ្ទះសរុបដែលអាជ្ញាធរមូលដ្ឋានបញ្ជាក់ថាប្រជាសហគមន៍បឹងឈូកមានជ័យថ្មីរស់នៅលើគំនរសំរាមលាយជាមួយទឹកដោយមិនមានប្រព័ន្ធលូសម្រាប់ផ្ទះរបស់ពួកគាត់។

រាល់ទឹកប្រើបាស់ទាំងអស់ បានធ្លាក់ទៅក្រោមផ្ទះ និងបន្តឱ្យមានទឹកលិចរួមផ្សំជាមួយទឹកដក់ចាស់ផងដែរ។ ជាពិសេសនៅរដូវវស្សាចំនួនទឹកភ្លៀងកាន់តែធ្វើឱ្យមានការលិចកាន់តែខ្លាំង។ ក្នុងនោះមុនពេលដែលមិនទាន់មានប្រព័ន្ធលូមួយខ្សែដែលមានទីតាំងនៅលើច្រកផ្លូវចូលសហគមន៍ គឺប្រព័ន្ធទឹកប្រើប្រាស់របស់ប្រជាពលរដ្ឋប្រហែលជា ៥ទៅ៦ខ្នងផ្ទះដែលនៅលើបណ្តោយផ្លូវជាតិលេខ១ និង បុរី ប៉េងហួត បានហូរមកក្នុងសហគមន៍បន្ថែមផងដែរ។

សមាជិកប្រជាសហគមន៍ម្នាក់អះអាងថា៖

"ពីមុនហូរចូល អត់ទាន់មានផ្ទះ ឥឡូវអត់ហូរទេ គេទប់អស់ បើលិចចំនួនទឹកភ្លៀង តែអត់សំរាម។"

### ៣.ប្រភពសំរាមដែលផុសចេញពីដីតាមការអះអាងរបស់ប្រជាសហគមន៍

តាមការសាកសួរពីប្រជាសហគមន៍បានឱ្យដឹងថាសហគមន៍អាចជាបឹងមួយដែលមានទឹកនិងសំរាមជាច្រើនពិតជាមិនត្រឹមត្រូវទេព្រោះផ្ទុយពីការអះអាងពីខាងអាជ្ញាធរមូលដ្ឋានបានលើកឡើងថាសហគមន៍ជាដីក្រុមសាមគ្គីនិងមិនមានសំរាមនិងទឹកនោះទេ។ ប៉ុន្តែសហគមន៍មានសណ្ឋានដីទាបដោយសារតែមានការជីកដីលក់ពីខាងសាលារៀនច្បារអំពៅ ហើយទីតាំងនោះក៏ជាទីតាំងដែលប្រជាសហគមន៍នាំគ្នាមកចោលសំរាមមុនមានលំនៅឋានដូចគ្នាដែលបណ្តាលឱ្យមានសំរាមជាច្រើន។



សមាជិកប្រជាសហគមន៍ម្នាក់អះអាងថា៖

"ពីដំបូងហូរឡើងពីរបស់គេមកទេ តែឥឡូវសំរាមអត់មានចេញទេ បារអត់អស់វាផុសឡើង។"

ក្នុងនោះបុគ្គលិកក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីបានបង្ហាញទិន្នន័យក្នុងការគណនាការប្រើប្រាស់សំរាមជាមធ្យមរបស់ប្រជាពលរដ្ឋបានឱ្យដឹងថា ក្នុង១ថ្ងៃប្រជាពលរដ្ឋប្រើប្រាស់សំរាមជាមធ្យម ១គីឡូ៨ក្រាម ក្នុង១ខ្នងផ្ទះ បើសិនប្រជាពលរដ្ឋមាន ៣៣ ខ្នងផ្ទះ ស្មើនឹង ១,៨ × ៣៣ × ៣៦៥ ថ្ងៃ= ២១៦៨១ គីឡូក្រាមក្នុងមួយឆ្នាំៗ ដែលសំរាមបានកប់ជាប់ទៅខាងក្រោមដី ដែលធ្វើឱ្យការប្រមូលចេញមិនចេះអស់នោះទេបើការចោលសំរាមមានរយៈពេលជាយូរឆ្នាំ។

បែបនេះទើបធ្វើឱ្យប្រជាសហគមន៍យល់ច្រឡំថាសំរាមអាចមានការផុសឡើងពីដី ឬ មិនដឹងពីប្រភពច្បាស់លាស់ ព្រោះបរិមាណសំរាមដែលកប់

ជាប់ទៅខាងក្រោមដី ដែលធ្វើឱ្យការប្រមូលចេញមិនចេះអស់នោះទេបើការចោលសំរាមមានរយៈពេលជាយូរឆ្នាំ។

បែបនេះទើបធ្វើឱ្យប្រជាសហគមន៍យល់ច្រឡំថាសំរាមអាចមានការផុសឡើងពីដី ឬមិនដឹងពីប្រភពច្បាស់លាស់ ព្រោះបរិមាណសំរាមដែលកប់ជាប់នៅក្នុងដីសរុបមានចំនួនច្រើនដោយសារការចោលសំរាមពីមុនរបស់ប្រជាសហគមន៍ បូកបន្ថែមជាមួយសំរាមដែលហូរតាមទឹកពេលដែលមានការសាងសង់សំណង់បុរី ប៉េងហួតផងដែរ។

## ៦.៣.ផលប៉ះពាល់និងក្តីបារម្ភពីបញ្ហាសំរាម

សហគមន៍មួយដែលរស់នៅដូចជាក្រឡដ៏ជ្រៅមួយ និងមានស្ពានថ្មតូចមួយសម្រាប់ការធ្វើការដើរឆ្លងកាត់ដើម្បីចូលទៅក្នុងផ្ទះ បើងាកមើលទៅខាងក្រោមផ្ទះពោរពេញទៅដោយសំរាមអណ្តែតយ៉ាងក្រាស់ជាមួយទឹកកខ្វក់ដែលមានពណ៌ខ្មៅកំពុងតែរុំព័ទ្ធសរសរផ្ទះ ព្រមទាំងក្លិនស្អុយដែលបានសាយភាយតាមខ្យល់។



កាកសំណល់ជាច្រើនដែលបានកក

តាមការសិក្សាស្រាវជ្រាវក្នុងឆ្នាំ២០២២ កន្លងមកប្រៀបធៀបជាមួយការសិក្សាស្រាវជ្រាវប្រធានបទខាងលើបានបង្ហាញថា សំរាមទាំងអស់នេះពិតជានៅតែបង្កនូវផលលំបាក និងក្តីបារម្ភ សម្រាប់ប្រជាសហគមន៍ដូចជា មានក្លិនស្អុយ ជាជំរកសត្វ និងធ្វើឱ្យពិបាកក្នុងការដកដង្ហើម។ លើសពីនេះប្រជាសហគមន៍បានបន្ថែមថាសំរាមទាំងអស់នេះក៏អាចបង្កជាអគ្គីភ័យដែលជាក្តីបារម្ភរបស់ពួកគាត់ពីការដែលមានភ្លើងឆេះដោយសារកន្ទុយបារី ផ្ទះហ្គាស និងប្រព័ន្ធខ្សែភ្លើងជាដើម។ ជាពិសេសការបង្កជាគ្រោះថ្នាក់ដល់កូនៗរបស់ពួកគាត់ដោយសារការលង់ទឹកពេលដែលមានការធ្លាក់ចូលទៅក្រោមផ្ទះរបស់ពួកគាត់។

សមាជិកប្រជាសហគមន៍ម្នាក់អះអាងថា ៖ កូនបងមីតូចនឹងរត់លែង រត់លែងធ្លាក់២ ដងហើយ។



ស្ពានថ្មសម្រាប់ធ្វើដំណើរក្នុងសហគមន៍

## ៦.៤.មធ្យោបាយក្នុងការលុបបំបាត់សំរាមចេញពីសហគមន៍

ប្រជាសហគមន៍បញ្ជាក់ថាការគ្រប់គ្រងសំរាមតាមផ្ទះមានសភាពល្អប្រសើរជាងមុនដោយសារតែពួកគាត់ មានការវេចខ្ចប់ប្រមូលសំរាមប្រើប្រាស់យកទៅទុកនៅគល់ស្ពានដែលមានចំងាយប្រហែល១០០ទៅ២០០ម៉ែត្រជាកន្លែងដែលខាងក្រុមហ៊ុនមកប្រមូលសំរាមនៅក្នុងសហគមន៍។ ពួកគាត់បន្ថែមទៀតថាពួកគាត់ធ្លាប់ចុះទៅប្រមូលសំរាមជាញឹកញាប់

ដោយសារសំរាមមានចំនួនច្រើនពេកបណ្តាលឱ្យមានក្លិនស្អុយ និងប្រជាសហគមន៍មួយចំនួនទៀតមិនហ៊ានចុះប្រមូលនោះទេព្រោះទីតាំងផ្ទះរបស់ពួកគាត់មានជម្រៅទឹកលិចជ្រៅខ្លាំង។ ការចុះប្រមូលពិតជាមានការលំបាកខ្លាំងចំពោះពួកគាត់ដោយសារទឹកដែលនៅក្រោមផ្ទះមានលក្ខណៈជាទឹកកខ្វក់ដែលធ្វើឱ្យរមាស់ពេញខ្លួនប្រាណ អាចមានរបួសដោយសារការមុតអំបែងកែវនិងការជួបគ្រោះថ្នាក់ពីសត្វផ្សេងៗទៀត។



> សមាជិកប្រជាសហគមន៍ម្នាក់អះអាងថាៈ អត់ដឹង មិនហ៊ានស្នើ មិនហ៊ានសុំទេ។

សហគមន៍ធ្លាប់ទទួលបានការដោះស្រាយពីប្រភពសំរាមពីមុនមកពីសំណាក់អាជ្ញាធរមូលដ្ឋានដែលមានការសហការជាមួយអង្គការសមាគមជាងត្នោត ប៉ុន្តែការរុករកប្រភពសំរាមនេះវាពិតរឿងដ៏លំបាកខ្លាំងណាស់ ដោយមិនមានការទទួលបានដំណោះស្រាយលើបញ្ហានោះទេ។ លើសពីនេះអង្គការសមាគមជាងត្នោតធ្លាប់ចុះជួយសំអាត និងប្រមូលសំរាមនៅខាងក្រោមផ្ទះរបស់ប្រជាសហគមន៍ចំនួន២លើកផងដែរ។

អាជ្ញាធរមូលដ្ឋានបានបញ្ជាក់ថាសម្រាប់ការសិក្សាពីបញ្ហាប្រភពសំរាមនៅក្នុងសហគមន៍មិនធ្លាប់មាននោះទេ។ សម្រាប់វិធានការបន្ថែមនោះគឺប្រជាសហគមន៍នាំគ្នាយកសំរាមដែលប្រើប្រាស់រួចយកទៅទុកនៅគល់ស្ពានតាមការណែនាំរបស់អាជ្ញាធរ។ បន្ថែមពីនេះអាជ្ញាធរមូលដ្ឋាន និងប្រជាសហគមន៍ក៏មិនធ្លាប់មានការពិភាក្សា និងការស្នើសុំពីបញ្ហាប្រភពសំរាមដូចគ្នាដែរ ព្រោះពួកគាត់មិនហ៊ានក្នុងការស្នើសុំទៅកាន់អាជ្ញាធរមូលដ្ឋាន និងខាងខណ្ឌសង្កាត់នោះទេ។

តាមកិច្ចសម្ភាសជាមួយក្រុមហ៊ុនប្រមូលសំរាមស៊ីនទ្រីដែលជាក្រុមហ៊ុនចុះមកប្រមូលសំរាមនៅក្នុងសហគមន៍បានឱ្យដឹងថាខាងក្រុមហ៊ុនមានការចុះពិនិត្យទីតាំងកាលពី៥ឆ្នាំមុន គឺទីតាំងសហគមន៍មិនមានផ្លូវដែលអាចចូលប្រមូលក្នុងសហគមន៍នោះទេ គឺតម្រូវឱ្យប្រជាពលរដ្ឋជួយយកទៅចោលនៅផ្លូវធំខាងលើ ប៉ុន្តែសព្វថ្ងៃមានហេដ្ឋារចនាសម្ព័ន្ធគឺឡានប្រមូលសំរាមរបស់ក្រុមហ៊ុនអាចចូលទៅតាមមួយផ្លូវទៀតដែលអាចទៅដល់ត្រឹមគល់ស្ពានសហគមន៍ក្នុងការយកសំរាមចេញក្នុងរយៈពេល ២ទៅ៣ ដងក្នុងមួយសប្តាហ៍។ គាត់បន្តថាខាងក្រុមហ៊ុនមិនមានអ្នកបច្ចេកទេសក្នុងការសិក្សាពីប្រភពសំរាមនៅក្នុងសហគមន៍នោះទេ តែបុគ្គលិកដែលប្រចាំការក្នុងតំបន់របស់សហគមន៍បានសន្មតថាប្រភពសំរាមគឺបណ្តាលមកពីការចោលផ្តេសផ្តាស របស់ប្រជាពលរដ្ឋដែលមិនបានយកទៅទីតាំងប្រមូល ព្រោះទីតាំងសហគមន៍មិនមានការហូរចេញចូលពីទីតាំងផ្សេងនោះទេ។ ក្រុមហ៊ុនបានចុះអប់រំផ្សព្វផ្សាយទៅកាន់សហគមន៍កាលពីថ្ងៃទី១០ ខែមិថុនា ឆ្នាំ២០២៣ ស្តីពីការវេច

ខ្ចប់ការញែកសំរាម និងបានផ្តល់ធុងសំរាមជូនសហគមន៍។

ក្រុមហ៊ុនបន្តថា មានយុនាការក្នុងការចុះប្រមូលសំរាមដោយឥតគិតថ្លៃសម្រាប់ទីតាំងដែលមានសំរាមស្ងួត ប៉ុន្តែសម្រាប់ទីតាំងរបស់សហគមន៍មានស្ថានភាពលំបាកក្នុងការប្រមូលព្រោះមានផ្លូវតូចចង្អៀតមិនអាចយកគ្រឿងចក្រ ហើយទើសរសេរផ្ទះជាមួយជម្រៅទឹកជ្រៅនិងអាចមានសត្វកាចសាហាវ។ ប៉ុន្តែក្នុងនោះក្រុមហ៊ុនក៏មានវិធីសាស្ត្រសម្រួល



ដល់ប្រជាសហគមន៍ក្នុងលក្ខខណ្ឌដែលមានការស្នើរសុំជំនួយមកកាន់ក្រុមហ៊ុន គឺក្នុងនោះមានកម្មករប្រមូលសំរាមក្នុងការជួយប្រមូលសំរាមដែលមានការសហការរួមគ្នាជាមួយប្រជាពលរដ្ឋផ្ទាល់ក្នុងការប្រមូលតាមក្រោយផ្ទះផងដែរ។

ក្នុងនោះសម្រាប់ដំណោះស្រាយជូនប្រជាពលរដ្ឋក្នុងការទប់ស្កាត់បញ្ហាសំរាមគឺប្រជាពលរដ្ឋនាំគ្នាវេចខ្ចប់រាល់សំរាមប្រើប្រាស់ទាំងអស់ និងមិនមានការចោលទៅក្រោមផ្ទះ។ សម្រាប់ដោះស្រាយរយៈពេលវែង គឺមានការធ្វើប្រព័ន្ធលូបន្ថែម១ខ្សែសម្រាប់ការបង្ហូរទឹកដែលប្រើប្រាស់ចេញពីបង្គន់ និងទឹកដែលកុំពុងដក់ ក្នុងការរំដោះទឹកចេញពីសហគមន៍ទាំងស្រុង។ លើកពីនេះការចាក់ដីបំពេញជាជំរើសដ៏ល្អក្នុងការធ្វើឱ្យសហគមន៍លែងមានសំរាម។ ប៉ុន្តែការចំណាយពិតជាខ្ពស់ព្រោះទឹកលាយជាមួយសំរាមដែលមាននៅក្រោមផ្ទះរបស់ប្រជាសហគមន៍មានជម្រៅជ្រៅ។ ក្នុងការចាក់ដីបំពេញប្រហែលជាមានជម្រៅ ៣ម៉ែត្រ ហើយទីតាំងរបស់សហគមន៍ ពិតជាលំបាកសម្រាប់ឡានចូលទៅខាងក្នុងសហគមន៍ផងដែរ។ អាជ្ញាធរមូលដ្ឋានបន្ថែមថាខាងអាជ្ញាធរពិតជាមិនមានកញ្ចប់ថវិការក្នុងការចាក់ដីបំពេញសម្រាប់ សហគមន៍បឹងឈូកមានជ័យថ្មីII នោះទេ។

# ៧.សេចក្តីសន្និដ្ឋាន



ការសិក្សាស្រាវជ្រាវ នេះបាន បង្ហាញឱ្យឃើញថា ប្រភពសំរាមនៅក្នុងសហគមន៍បឹងឈូកមានជ័យថ្មីII ភាគច្រើនជាសំណល់រឹងដែលមានប្រភពមកពីប្រជាសហគមន៍បានចោលផ្តេសផ្តាសតាំងពីមុន និងបន្តមានដល់បច្ចុប្បន្ន និងសំរាមដែលហូរតាមទឹកចូលមកក្នុងសហគមន៍ដោយសារការសាងសង់សំណង់បុរី ប៉េងហួត ក្នុងឆ្នាំ២០១២។ ជាពិសេសសំរាមរាវដែលបណ្តាលមកពីចំនួនទឹកភ្លៀងក្នុងរដូវវស្សា និងទឹកប្រើប្រាស់ប្រចាំថ្ងៃដែលចេញបង្ហូន់តាមផ្ទះនីមួយៗ របស់ប្រជាសហគមន៍។ ក្នុងនោះការអះអាងរបស់ប្រជាសហគមន៍ដែលបញ្ជាក់ថាសំរាមផុសពីដីនោះពិតជាមិនត្រឹមត្រូវទាំងស្រុងនោះទេ។

តាមរយៈដំណោះស្រាយកន្លងមកអាចជួយកាត់បន្ថយសំរាមរឹងនៅក្នុងសហគមន៍បានមួយចំនួនតែប៉ុណ្ណោះ ដោយសារសំរាមចាស់ដែលកប់ជាប់នៅខាងក្រោមដីមានចំនួនច្រើនដែលពិបាកក្នុងការប្រមូលចេញព្រោះមានការរាំងស្ទះដោយសារទឹកបន្ថែមទៀតដែលពុំទាន់មានការរំដោះចេញបាន។



# ៨. អនុសាសន៍



## ១. អាជ្ញាធរមូលដ្ឋាន

- អាជ្ញាធរមូលដ្ឋានគួរមានការប្រជុំពិភាក្សាជាមួយប្រជាពលរដ្ឋសម្រាប់ដំណោះស្រាយសំរាមកកស្ទះ និងបញ្ហាប្រភពសំរាមក្នុងសហគមន៍។
- អាជ្ញាធរមូលដ្ឋានគួរមានការប្រជុំផ្សព្វផ្សាយពីចំណេះដឹងក្នុងការគ្រប់គ្រងសំរាមទៅកាន់ប្រជារាជសហគមន៍។
- អាជ្ញាធរមូលដ្ឋានគួរមានការដាក់ប្រព័ន្ធលូ១ខ្សែទៀតក្នុងការរំដោះទឹកចេញសម្រាប់សហគមន៍ឱ្យបានគ្រប់ផ្ទះ។
- អាជ្ញាធរមូលដ្ឋានគួរសម្របសម្រួលក្នុងការចាក់ដីបំពេញ។

## ២.ប្រជាសហគមន៍

- ប្រជាពលរដ្ឋចូលរួមក្នុងការសម្អាតនិងវេចខ្ចប់សំរាមយកទៅចោលក្នុងធុងសំរាមរបស់ក្រុមហ៊ុនប្រមូលសំរាមដែលបានផ្តល់ជូនឱ្យបានត្រឹមត្រូវ និងមិនចោលនៅក្រោមផ្ទះ។
- ប្រជាពលរដ្ឋពិភាក្សាជាមួយអាជ្ញាធរក្នុងការស្វែងរកជំនួយពីអង្គការដៃគូរនានាក្នុងការចាក់ដីបំពេញ។

## ៣. ក្រុមហ៊ុនប្រមូលសំរាម

- ក្រុមហ៊ុនប្រមូលសំរាមបន្តយុទ្ធនាការអប់រំផ្សព្វផ្សាយពីផលលំបាកនិងការគ្រប់គ្រងសំរាមដល់ប្រជាពលរដ្ឋយ៉ាងតិចក្នុង១ឆ្នាំឱ្យបាន២ដង។
- ក្រុមហ៊ុមប្រមូលសំរាមជួយជាសម្ភារៈដូចជាចង់ខ្មៅ ក្រចាប់ ដង្កៀប និងកម្មករក្នុងការជួយក្នុងការប្រមូលសំរាមក្នុងសហគមន៍។
- ក្រុមហ៊ុនប្រមូលសំរាមទាំងអស់គួរតែមានអ្នកបច្ចេកទេសក្នុងការសិក្សាពីប្រភពសំរាមដែលមាននៅតាមសហគមន៍។
- ក្រុមហ៊ុនប្រមូលសំរាមចូលរួមសហការជាមួយអាជ្ញាធរមូលដ្ឋានក្នុងការទទួលខុសត្រូវប្រមូលសំរាមតាមតំបន់ដែលមានសំរាមទាំងអស់ក្នុងដែនសមត្ថកិច្ច ទោះបីជាទីតាំងមិនមានលំនៅឋានក៏ដោយ។

## ៤.អង្គការដៃគូរ

- អង្គការដៃគូរជួយគាំទ្រកញ្ចប់ថវិកា រួមជាមួយអាជ្ញាធរមូលដ្ឋានព្រមទាំងប្រជាពលរដ្ឋពិភាក្សាគ្នាពីការចាក់ដីបំពេញសម្រាប់សហគមន៍។



បាយការណ៍ស្រាវជ្រាវ ឆ្នាំ២០២៣

# បំរែបំរួលអាកាសធាតុ ក្នុងសហគមន៍ក្រីក្រ

សហគមន៍ស្មើសាមគ្គី និងពង្រសែនជ័យ

# តារាងមាតិកា

០១ សេចក្ដីផ្ដើម.......................................................................................១
០២ វិធីសាស្ត្រស្រាវជ្រាវ...............................................................................៣
០៣ ក្រមសីលធម៌នៃការស្រាវជ្រាវ...................................................................៤
០៤ គោលបំណងនៃការស្រាវជ្រាវ....................................................................៥
០៥ លទ្ធផលនៃការស្រាវជ្រាវ........................................................................៦
៥.១. សហគមន៍ពង្រសែនជ័យ....................................................................៦
ក. ផលប៉ះពាល់នៅពេលឡើងកម្ដៅ...................................................៧
ក.១. បញ្ហាការធ្វើដំណើរ.....................................................................៧
ក.២. បញ្ហាសេដ្ឋកិច្ច.......................................................................៧
ក.៣. បញ្ហាសុខភាព........................................................................៧
ខ. ផលប៉ះពាល់នូវពេលភ្លៀងធ្លាក់ខ្លាំងអំឡុងរដូវវស្សា..............................៨
ខ.១. បញ្ហាហេដ្ឋារចនាសម្ព័ន្ធ...............................................................៨
ខ.២. បញ្ហាការធ្វើដំណើរ.....................................................................៨
ខ.៣. បញ្ហាសុខភាព........................................................................៨
៥.២. សហគមន៍ស្មើសាមគ្គី.........................................................................៩
ក. ផលប៉ះពាល់នៅពេលកើនកម្ដៅ......................................................៩
ក.១. បញ្ហាការប្រកបរបរអាជីវកម្ម.........................................................៩
ក.២. បញ្ហាសុខភាព........................................................................៩
ក.៣. បញ្ហាការចំណាយផ្សេងៗ.........................................................១០
ខ. ផលប៉ះពាល់នៅពេលមានភ្លៀងធ្លាក់ខ្លាំង.......................................១០
ខ.១. បញ្ហាហេដ្ឋារចនាសម្ព័ន្ធ.........................................................១០
ខ.២. បញ្ហាសុខភាព.....................................................................១០

# តារាងមាតិកា


ខ.៣. បញ្ហាការខូចខាតសម្ភារៈ និងលំនៅឋាន..............១១
ខ.៤. បញ្ហាការរស់នៅ..........................................១១
៥.៣. ខ្យល់កន្ត្រាក់....................................................១២

០៦ ការបន្សាំខ្លួនក្នុងការរស់នៅ.................................................១៣
៦.១. ពេលកម្ដៅកើនឡើង........................................................១៣
ក. សហគមន៍ពង្រសែនជ័យ............................................១៣
ខ. សហគមន៍ស្មើសាមគ្គី................................................១៣
៦.២. អំឡុងពេលមានភ្លៀងធ្លាក់..............................................១៤
ក. សហគមន៍ពង្រសែនជ័យ............................................១៤
ខ. សហគមន៍ស្មើសាមគ្គី................................................១៤

០៧ សេចក្ដីសន្និដ្ឋាន..................................................................១៥

០៨ អនុសាសន៍........................................................................១៦

# ១. សេចក្តីផ្តើម



ការប្រែប្រួលអាកាសធាតុគឺជាការកើនឡើងកំដៅផែនដីដែលបណ្តាលមកពីសកម្មភាពរបស់មនុស្ស ដែលបង្កើតឧស្ម័នផ្ទះកញ្ចក់។ ការប្រែប្រួលអាកាសធាតុនេះរួមចំណែកបង្កឱ្យមានបញ្ហាជាច្រើនដូចជា ការរាំងស្ងួត កង្វះទឹក ការឡើងកម្តៅ នីវ៉ូទឹកសមុទ្រឡើងចុះ រលាយទឹកកកនៅតំបន់ប៉ូល ខ្យល់ព្យុះ ទឹកជំនន់ និងគ្រោះមហន្តរាយផ្សេងៗ។ ក្នុងនោះទឹកជំនន់កំពុងនឹងបំផ្លាញផ្ទះ និងជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រផងដែរ។[1]

តាមរយៈផែនការយុទ្ធសាស្ត្របម្រែបម្រួលអាកាសធាតុឆ្នាំ២០១៤ រហូតដល់ឆ្នាំ២០២៣ ក៏បានបង្ហាញថាទឹកជំនន់ជាបញ្ហាចម្បងដែលបណ្តាលឱ្យខូចខាតហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធលូផងដែរ។ ជាងនេះទៅទៀតក្នុងផែនការយុទ្ធសាស្ត្របានបញ្ជាក់ថា មានការកើនឡើងឧស្ម័នផ្ទះកញ្ចក់២៧% ជារៀងរាល់ឆ្នាំក្នុងចន្លោះឆ្នាំ ២០០០ រហូតដល់២០៥០ ដែលនេះជាការរកឃើញរបស់គម្រោងការបំភាយឧស្ម័នផ្ទះកញ្ចក់នៃក្រសួងបរិស្ថាន។[2]

របាយការណ៍វាយតម្លៃលើកទី៤ របស់ក្រុមការងារអន្តររាជរដ្ឋាភិបាល ស្តីពីការប្រែប្រួលអាកាសធាតុចេញផ្សាយឆ្នាំ២០០៧ ក៏បានរកឃើញថាមានបញ្ហាប្រឈមនឹងការប្រែប្រួលអាកាសធាតុដោយសកម្មភាពរបស់មនុស្សមកលើភពផែនដីផងដែរ។[3]

ដូចប្រទេសដ៏ទៃដែរ កម្ពុជាក៏កំពុងប្រឈមនឹងបញ្ហាដែលបង្កឡើងដោយការប្រែប្រួលអាកាសធាតុ។ ជាក់ស្តែង ព្យុះត្រូពិចដែលមានឈ្មោះថា លីនហ្វា (LINFA) និង ណាំងកា (NANGKA) បានវាយប្រហារប្រទេសវៀតណាម កម្ពុជា ឡាវ និងថៃ ធ្វើឱ្យមានមនុស្សស្លាប់លើសពី១១ នាក់ និងបំផ្លាញផ្ទះចំនួន៦៧ ៩៩៥ខ្នង នៅក្នុងខេត្តចំនួន១៩។ ខេត្តដែលរងគ្រោះ ខ្លាំងជាងគេរួមមាន ខេត្តបាត់ដំបងដែលមានចំនួន៣៨ ៩៩០ខ្នង ខេត្តពោធិ៍សាត់មានចំនួន ១៨ ៣៦៥ខ្នង និង ខេត្តបន្ទាយមានជ័យមានចំនួន៧ ០៣៤ខ្នង។[4]

---

[1] អង្គការសហប្រជាជាតិ, អ្វីទៅជាការប្រែប្រួលអាកាសធាតុ?, ទាញយកពី៖ https://www.un.org/en/climatechange/what-is-climate-change

[2] រាជរដ្ឋាភិបាលកម្ពុជា (២០១៣)។ ផែនការយុទ្ធសាស្ត្រប្រែប្រួលអាកាសធាតុកម្ពុជា ២០១៤-២០២៣។ អាចរកតាមរយៈគេហទំព័រ៖ https://www.cambodiaip.gov.kh/DocResources/ab9455cf-9eea-4adc-ae93-95d149c6d78c_007729c5-60a9-47f0-83ac-7f70420b9a34-en.pdf

[3] ក្រុមប្រឹក្សាជាតិ អភិវឌ្ឍន៍ដោយចីរភាព, ប្រែប្រួលអាកាសធាតុ, ទាញយកពី៖ https://ncsd.moe.gov.kh/kh/dcc

[4] ReliefWeb (១៥ តុលា ២០២៣), អាកាសធាតុធ្ងន់ធ្ងរនិងសកម្មភាពរបស់ស៊ីក្លូនត្រូពិច នៅ វៀតណាម កម្ពុជា ឡាវ ថៃ (DG ECHO, GDACS, AHA Centre, DBQG, Cambodia Meteo, NOAA-CPC), ទាញយកពី៖ https://reliefweb.int/report/viet-nam/vietnam-cambodia-laos-thailand-severe-weather-and-tropical-cyclones-activity-dg-echo

ប្រទេសកម្ពុជា ក៏បាននឹងកំពុងទទួលរងគ្រោះមហន្តរាយនានា ពីការប្រែប្រួលអាកាសធាតុ និងគួបផ្សំនឹងការអភិវឌ្ឍទីក្រុងបានបណ្តាលឱ្យមានការកើនឡើងនូវគ្រោះទឹកជំនន់។ ការសិក្សាមួយរបស់សហភាពអឺរ៉ុបបានបញ្ជាក់ថា ប្រទេសកម្ពុជាមានចំណាត់ថ្នាក់ហានិភ័យកម្រិតមធ្យមនៅលើសន្ទស្សន៍ហានិភ័យក្នុងឆ្នាំ២០២០ និងទទួលបានពិន្ទុខ្ពស់លើភាពងាយរងគ្រោះ និងកង្វះសមត្ថភាពក្នុងការដោះស្រាយទៅនឹងគ្រោះមហន្តរាយ។[៥]

ដូចគ្នាទៅនឹងការលើកឡើងខាងលើ សហគមន៍ក្រីក្រមួយចំនួនក្នុងរាជធានីភ្នំពេញបាននឹងកំពុងប្រឈមបញ្ហានានា ដែលរងឥទ្ធិពលពីបម្រែបម្រួលអាកាសធាតុ។ ដូច្នេះ ទាំងនេះជាមូលហេតុសំខាន់ៗដែលជម្រុញឱ្យមានការសិក្សាមួយនេះកើតឡើង។ ដើម្បីបានជាមូលដ្ឋានក្នុងការស្រាវជ្រាវ មានសំណួរចំនួន២ ដែលចោទសួរពីបញ្ហា។ ១. តើបញ្ហាប្រឈមអ្វីខ្លះដែលប្រជាសហគមន៍បានជួបប្រទះនៅពេលមានបញ្ហាបម្រែបម្រួលអាកាសធាតុ(ពេលកម្តៅកើនឡើងខ្លាំង និងពេលមានភ្លៀងធ្លាក់ខ្លាំង)? ២. តើប្រជាសហគមន៍មានវិធីសាស្ត្រអ្វីខ្លះដើម្បីបន្សាំនឹងការរស់នៅពេលមានភ្លៀងខ្លាំង ឬឡើងកម្តៅ?



[៥] សូមមើល https://drmkc.jrc.ec.europa.eu/inform-index

# ២. វិធីសាស្ត្រស្រាវជ្រាវ



ការស្រាវជ្រាវនេះ បានជ្រើសរើសសហគមន៍ក្រីក្រចំនួន២ គឺ សហគមន៍ពង្រសែនជ័យ និងសហគមន៍រស្មីសាមគ្គី។ ការកំណត់យកសហគមន៍ទាំងពីនេះមកធ្វើជាសំណាកសម្រាប់ការសិក្សាស្រាវជ្រាវនេះ ដោយយោងទៅតាមលក្ខណៈវិនិច្ឆ័យមួយចំនួនរួមមាន សហគមន៍ទាំងពីរ កំពុងរស់នៅលើទីតាំងដែលពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងងាយប្រឈមនឹងបញ្ហានានា ពីការប្រែប្រួលអាកាសធាតុ។ សហគមន៍ទាំង២នេះ មានប្រជាពលរដ្ឋរស់នៅសរុបចំនួន ២១០គ្រួសារ ដែលត្រូវនឹង ៦៣៣នាក់។ សហគមន៍ពង្រសែនជ័យជាសហគមន៍ក្រីក្រដែលរស់នៅលើផ្លូវបេតុងតូចមួយមានប្រវែងប្រមាណ ២០០ម៉ែត្រ ឋិតនៅទីតាំងចន្លោះកណ្តាលដែលជាប់របងដោយដីទំនេរ និងសំណង់អគារបុរីមួយកន្លែង មានប្រមាណ ៥៧ខ្នងផ្ទះ ដែលមានចំនួន ៧៤គ្រួសារ ត្រូវនឹង ២២៨នាក់។ សហគមន៍ពង្រសែនជ័យមានប្រជាពលរដ្ឋចំនួន ១៤២ខ្នងផ្ទះ ដែលមានចំនួន ១៥០គ្រួសារ ត្រូវនឹង ៥០១នាក់។ រីឯសហគមន៍រស្មីសាមគ្គីមានទីតាំងស្ថិតនៅ ខណ្ឌមានជ័យ ក្រុងភ្នំពេញដែលភាគច្រើននៃប្រជាសហគមន៍សុទ្ធសឹងតែរស់នៅពីមុខប្រឡាយទឹកស្អុយនេះ និងមានផ្ទះចំនួន ៥៥ខ្នង។ ប្រជាជនរស់នៅសហគមន៍រស្មីសាមគ្គីមានចំនួន ៦០គ្រួសារត្រូវនឹង ១៣២នាក់។ ក្នុងនោះដែរសមាជិកក្នុងសហគមន៍ដែលបានចូលរួមក្នុងការសម្ភាសសរុបទាំងពីរសហគមន៍មានចំនួន ៥២នាក់ ដែលសហគមន៍ពង្រសែនជ័យមានអ្នកផ្តល់បទសម្ភាសន៍ ៣០នាក់ និងរស្មីសាមគ្គី ២២នាក់។ ដោយសារចំនួនអ្នកចូលរួមសម្ភាសមានតិច ការរកឃើញមួយចំនួនក្នុងការស្រាវជ្រាវនេះ ប្រហែលជាមិនតំណាងឱ្យមតិមួយចំនួនរបស់ប្រជាសហគមន៍ផ្សេងទៀតដែលមិនបានចូលរួមក្នុងការស្រាវជ្រាវនេះ។

ការប្រមូលទិន្នន័យខាងលើនេះ ធ្វើឡើងតាមរយៈការសម្ភាសផ្ទាល់មាត់ជាមួយសមាជិកដែលរស់នៅក្នុងសហគមន៍ពង្រសែនជ័យ និងរស្មីសាមគ្គីផ្ទាល់ចាប់ពីថ្ងៃទី១៥ ដល់ ៣០ ខែឧសភា ឆ្នាំ២០២៣ ដោយការសម្ភាសចំណាយពេលពី១០ទៅ២០នាទីក្នុងមួយខ្នងផ្ទះ។ ការសម្ភាសនេះធ្វើឡើងដោយផ្អែកទៅលើកម្រងសំណួរដែលផ្តោតសំខាន់ទៅលើការបន្សាំខ្លួនក្នុងការរស់នៅ និងបញ្ហាផលប៉ះពាល់ដែលសមាជិកនៅក្នុងសហគមន៍ទាំងពីរបានកំពុង និងជួបប្រទះ។



# ៣. ក្រមសីលធម៌ នៃការស្រាវជ្រាវ

ការប្រមូលទិន្នន័យប្រព្រឹត្តទៅដោយមិនមានភាពលម្អៀង និងអនុវត្តប្រកបដោយក្រមសីលធម៌ក្នុងការស្រាវជ្រាវ។ មុន និងធ្វើកិច្ចសម្ភាសអ្នកទទួលការសម្ភាសត្រូវបានពន្យល់នូវចំណុចមួយចំនួនរួមមាន អ្នកទទួលការសម្ភាសចូលរួមដោយស្ម័គ្រចិត្ត មានសិទ្ធិបដិសេធនូវសំណួរដែលខ្លួនមិនចង់ឆ្លើយ ការសម្ភាសប្រាប់ពីគោលបំណងនៃការសម្ភាស និងការស្រាវជ្រាវធានាជូនអ្នកចូលរួមថាព័ត៌មានផ្ទាល់ខ្លួននឹងរក្សាទុកជាការសម្ងាត់ និងទិន្នន័យទាំងអស់ដែលបានមកនឹងប្រើសម្រាប់តែគោលបំណងនៃសិក្សាស្រាវជ្រាវប៉ុណ្ណោះ។



# ៤. គោលបំណង នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងក្នុងគោលបំណង៣គឺ៖

- សិក្សាពីបញ្ហាប្រឈម និងផលប៉ះពាល់របស់ប្រជាសហគមន៍ក្រីក្រ ដោយសារបញ្ហាបម្រែបម្រួលអាកាសធាតុ (ការកើនឡើងកម្ដៅ និងពេលមានភ្លៀងធ្លាក់)
- ឈ្វេងយល់ពីការបន្សាំខ្លួន ឬការផ្លាស់ប្ដូរពីរបៀបរស់នៅរបស់ប្រជាសហគមន៍ក្រីក្រ អំឡុងពេលមានបម្រែបម្រួលអាកាសធាតុ
- ផ្ដល់ជាអនុសាសន៍ទៅកាន់ប្រជាសហគមន៍ក៏ដូចជាអាជ្ញាធរមូលដ្ឋាន និងភាគីពាក់ព័ន្ធដើម្បីស្វែងរកដំណោះស្រាយ។



# ៥. លទ្ធផលនៃការស្រាវជ្រាវ



ការចុះទៅប្រមូលទិន្នន័យតាមរយៈការចុះសម្ភាសដោយផ្ទាល់ជាមួយប្រជាសហគមន៍ទាំង២សហគមន៍បានឱ្យដឹងថា បច្ចុប្បន្ននេះ នៅក្នុងសហគមន៍អាកាសធាតុប្រែប្រួលពុំទៀងទាត់នោះទេ។ ដោយជួនក្តៅជួនត្រជាក់ ជួនមានភ្លៀងជួនគ្មានភ្លៀង ហើយនៅពេលភ្លៀងម្តងនៅក្នុងសហគមន៍នឹងប្រឈមទៅនឹងបញ្ហាស្ទះដោយសារតែប្រព័ន្ធលូនៅក្នុងសហគមន៍ហូរមិនទាន់។ ប្រជាសហគមន៍មួយចំនួនបានប្រាប់ឱ្យដឹងថា បញ្ហាឡើងកម្តៅ និងភ្លៀងធ្លាក់ខ្លាំងនេះ ធ្វើឱ្យគាត់ជួបនូវផលលំបាកជាច្រើន រួមមាន បញ្ហាការរកស៊ី ការលក់ដូរ និងការចំណាយថ្លៃទឹកភ្លើងកើនឡើងច្រើនជាងមុន រួមទាំងការធ្វើដំណើរ ការរស់នៅ និងជាពិសេសចំពោះបញ្ហាសុខភាព។

## ៥.១. សហគមន៍ពង្រសែនជ័យ

សហគមន៍ពង្រសែនជ័យជាតំបន់លំនៅឋានក្រីក្រដែលស្ថិតនៅទីក្រុងភ្នំពេញ។ ពួកគាត់បានរស់នៅលើប្រឡាយតាំងពីឆ្នាំ២០០០ ដែលមានទីតាំងនៅភូមិទួលពង្រ សង្កាត់ចោមចៅទី១ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ។ សហគមន៍ស្ថិតនៅចន្លោះដីឯកជន រោងចក្រ និងបុរី។ ភាគច្រើននៃប្រជាសហគមន៍នៅក្នុងតំបន់នេះច្រើនប្រកបមុខរបរជាមន្រ្តីរាជការ កម្មកររោងចក្រ រត់ម៉ូតូឌុប រត់រ៉ឺមក កម្មករសំណង់ អ្នកលក់ដូរតាមដងផ្លូវ និងតាមរទេះ។ ប្រជាសហគមន៍ស្ទើរតែអស់សុទ្ធតែទទួលបានការតភ្ជាប់អគ្គិសនី និងទឹកស្អាតពីរដ្ឋសម្រាប់ប្រើប្រាស់។ ចំណែកកុមារភាគច្រើនរៀនសូត្រនៅសាលា ឬជាមួយអង្គការមិនមែនរាជរដ្ឋាភិបាល ដែលស្ថិតនៅជិតសហគមន៍។ តាមការសង្កេតបានឃើញថា ផ្លូវដែលចូលទៅកាន់សហគមន៍មានទំហំតូចហើយពុំមានភ្លើងបំភ្លឺផ្លូវនៅពេលយប់នោះទេ។

ហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងសហគមន៍ពុំទាន់មានភាពល្អរឹងមាំនោះទេ ម្យ៉ាងទៀតដោយសារតែផ្លូវក្នុងហគមន៍មានភាពតូចចង្អៀតផងធ្វើឱ្យពួកគាត់លំបាកខ្លាំង។

## ក. ផលប៉ះពាល់នៅពេលឡើងកម្តៅ

តាមរយៈ ការសម្ភាសផ្ទាល់មាត់ជាមួយប្រជាពលរដ្ឋនៅសហគមន៍ពង្រសែនជ័យបានរកឃើញថា នៅពេលមានរលកកម្តៅម្តងៗ បានបង្កជាការរំខាន និងផលប៉ះមួយចំនួនដល់ប្រជាសហគមន៍ដូចជាៈ

### ក.១. បញ្ហាការធ្វើដំណើរ

អ្នកចូលរួមក្នុងការផ្តល់បទសម្ភាសនៅក្នុងសហគមន៍ក្នុងនោះមានសមាជិក ៧% ក្នុងចំណោមអ្នកចូលរួម៣០នាក់បានប្រាប់ថា ដោយសារតែអាកាសធាតុក្តៅពេកធ្វើឱ្យពិបាកចេញទៅណាមកណា។ សម្រាប់មនុស្សធំពួកគាត់ពិបាកក្នុងការធ្វើដំណើរទៅធ្វើការ ឬក៏ទៅផ្សារទិញម្ហូប។ ចំណែកឯប្រជាសហគមន៍ដែលជាអាជីវករ និងអ្នកធ្វើការនៅរោងចក្រ ពួកគាត់មានភាពពិបាកខ្លាំងក្នុងការដឹកឥវ៉ាន់ទៅលក់ និងអង្គុយនៅក្នុងរោងចក្រ។ រីឯកុមារភាគច្រើនប្រឈមនឹងការក្តៅខ្លួនពេលដែលធ្វើដំណើរទៅសាលា។



### ក.២. បញ្ហាសេដ្ឋកិច្ច

ការប្រែប្រួលអាកាសធាតុក៏ប៉ះពាល់ដល់សេដ្ឋកិច្ចសង្គមផងដែរ ដោយសារនៅពេលអាកាសធាតុក្តៅខ្លាំងបែបនេះវាបានធ្វើឱ្យពួកគាត់មានការចំណាយច្រើនជាងមុន។ ពួកគាត់ត្រូវចំណាយទៅលើថ្លៃទឹកភ្លើង ច្រើនជាងមុន។ មានចំនួន៥០% ក្នុងចំណោម៣០នាក់បានឆ្លើយថា ពួកគាត់ភាគច្រើនត្រូវតែបើកកង្ហារជាប់រហូត ហើយការប្រើប្រាស់ទឹកវិញក៏ត្រូវប្រើប្រាស់ច្រើនជាងមុនដែរ រួមទាំងការចំណាយទៅលើថ្លៃថ្នាំពេទ្យផងដែរ។ អាកាសធាតុក្តៅក៏ងាយនឹងធ្វើឱ្យកុមារមានបញ្ហាសុខភាពផងដែរ។ ដូចនេះហើយ ពួកគាត់ត្រូវទៅពេទ្យដែលនៅជិតៗសហគមន៍ដើម្បីព្យាបាល ហើយអ្នកខ្លះទៀតក៏ផ្សំថ្នាំតាមឱសថស្ថាន។

### ក.៣. បញ្ហាសុខភាព

សមាជិក១៣នាក់ ក្នុងចំណោម ៣០នាក់ នៅសហគមន៍ពង្រសែនជ័យដែលបានសម្ភាសបាននិយាយថា ភាគច្រើននៃកុមារ និងមនុស្សធំ គឺសុទ្ធតែជួបប្រទះនូវបញ្ហាសុខភាព

ដោយកុមារច្រើនសុទ្ធតែឧស្សាហ៍ក្តៅខ្លួន ផ្តាសាយ និងមនុស្សចាស់ជួបប្រទះនឹងការវិលមុខ ថប់ដង្ហើម ហើយពេលខ្លះក្តៅខ្លាំងខ្សោះជាតិទឹកអស់ពីខ្លួន។ ក្រៅពីបញ្ហាខាងលើ បញ្ហាសុខភាពមួយចំនួនទៀតមានដូចជាជម្ងឺ សើស្បែក បញ្ហាដំណេកដោយសារផ្ទះរបស់ប្រជាសហគមន៍ភាគច្រើនធ្វើពីស័ង្កសី ដែលមានសភាពហប់

ស្អុះស្អាប់ ឬមិនមានខ្យល់ចេញចូល និងក្តៅខ្លាំងដែលពួកគាត់ត្រូវងើបងូតទឹកញឹកញាប់ច្រើនដង។

## ខ. ផលប៉ះពាល់នូវពេលភ្លៀងធ្លាក់ខ្លាំងអំឡុងរដូវវស្សា

អ្នកផ្តល់បទសម្ភាស៨៧% ក្នុងចំណោម ៣០នាក់នៅក្នុងសហគមន៍ពង្រសែនជ័យ បានឱ្យដឹងថា ផលប៉ះពាល់ដែលពួកគាត់បានជួបប្រទះអំឡុងពេលមានភ្លៀងធ្លាក់មានដូចជា៖

### ខ.១. បញ្ហាហេដ្ឋារចនាសម្ព័ន្ធ

សហគមន៍ កំពុងប្រឈមនឹងបញ្ហាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធដូចជាការស្ទះលូ និងប្រឡាយ។ ៣០% នៃអ្នកទទួលការសម្ភាសបានឱ្យដឹងថា នៅក្នុងសហគមន៍ឱ្យតែពេលមានភ្លៀងធ្លាក់ម្តងៗនឹងធ្វើឱ្យលូនៅក្នុងសហគមស្ទះជាពិសេសនៅអំឡុងខែឧសភា និងមិថុនា។ ប្រជាជននៅក្នុងសហគមន៍ក៏បានបញ្ជាក់ដែរថា ប្រជាពលរដ្ឋដែលរស់នៅទីនោះមានការសហការគ្នា ដើម្បីដាក់ប្រព័ន្ធលូមុខផ្ទះរៀងៗខ្លួន។ ពួកគាត់បានបន្ថែមទៀតថាអ្នកដែលបិទទឹកកុំឱ្យហូរទៅខាងមុខនោះ ជាមិនមែនជាអាជ្ញាធរមូលដ្ឋាននោះទេ។



### ខ.២. បញ្ហាការធ្វើដំណើរ

ប្រជាសហគមន៍វ័យ៣១ឆ្នាំបាននិយាយថា៖

> “លូហ្នឹងមិនមែនណាអ្នកដាក់ទេ គឺសមាជិកនៅក្នុងសហគន៍រៃលុយគ្នាដាក់ទេ។ តាំងពីគេធ្វើស្ពានហ្នឹងទៅ ទឹកវាមិនសូវហូរដូចកាលមុន។ កាលពី ថ្ងៃទី៩ ខែតុលា ល្ងាចឡើងមានភ្លៀងខ្លាំងពេក ខ្ញុំនិងសមាជិកនាំគ្នាទៅបើកកន្លែងបន្លាយ និងឱ្យវាហូរ។ ហើយក៏មានគេមកបិទវិញ គេថាមិនឱ្យបើកទេ។ បំណងគេហ្នឹងចង់ពន្លិចពួកខ្ញុំហ្នុង” ។

### ខ.៣. បញ្ហាសុខភាព

ប្រជាសហគមន៍ភាគច្រើនបានប្រឈមនឹងបញ្ហាសុខភាពមួយចំនួននៅពេលដែលទឹកលិចសហគមន៍។ ប្រជាសហគមន៍មួយចំនួនគាត់បានលើកឡើងថានៅពេលរដូវវស្សា ពួកគាត់ជាច្រើនកើតជម្ងឺផ្តាសាយជាញឹកញាប់ ហើយខ្លះទៀតក៏កើតជាជម្ងឺគ្រុនឈាមដោយសារតែពេលទឹកលិចគឺសម្បូរមូសច្រើនពេក។ ក្នុងឆ្នាំ២០២២ នៅពេលដែលទឹកលិចចូលក្នុងសហគមន៍នោះជម្ងឺដែលប្រជាសហគមន៍ឧស្សាហ៍ជួបជាងគេ គឺជម្ងឺសើស្បែក ជាជម្ងឺទឹកស៊ីជើងដោយសារតែគាត់ត្រូវដើរកាត់ទឹកស្អុយជារៀងរាល់ថ្ងៃ។

## ៥.២. សហគមន៍រស្មីសាមគ្គី

សហគមន៍ រស្មីសាមគ្គីជាសហគមន៍ក្រីក្រមួយស្ថិតនៅទីក្រុងភ្នំពេញ ដែលមាន ទីតាំងស្ថិតនៅភូមិឫស្សី១ សង្កាត់ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ។

នៅក្នុងសហគមន៍សព្វថ្ងៃ មាន៥៥ ខ្នងផ្ទះ ៦០គ្រួសារ ត្រូវនឹង ១៣២នាក់។ ពួកគាត់ភាគច្រើនបានតាំងលំនៅនៅទីនោះតាំងពីឆ្នាំ១៩៩៨ ហើយបន្តរស់នៅទីនោះរហូតមកដល់សព្វថ្ងៃនេះ។

បញ្ហាប្រឈមរបស់ពួកគាត់គឺពួកគាត់កំពុងរស់នៅតាមបណ្តោយប្រឡាយដែលជាហេតុធ្វើឱ្យគាត់ប្រឈមនឹងបញ្ហាបំពុលបរិយាកាស ហើយប្រឈមនឹងទឹកជំនន់ជារៀងរាល់ឆ្នាំនូវរដូវវស្សាផងដែរ។ ចំណែក



### ក. ផលប៉ះពាល់នៅពេលកើនកម្តៅ

ចំពោះសហគមន៍រស្មីសាមគ្គីវិញនៅពេលអាកាសធាតុក្តៅខ្លាំងគាត់ក៏រងនៅផលប៉ះពាល់ស្រដៀងគ្នានឹងសហគមន៍ពង្រសែនជ័យដែរ ដោយពួកគាត់ទាំងនោះបានលើកឡើងថាគាត់បានទទួលរងនូវផលប៉ះពាល់មួយចំនួនដូចជា៖

### ក.១. បញ្ហាការប្រកបរបរអាជីវកម្ម

៦នាក់ក្នុងចំណោម ២២នាក់ ដែលបានអ្នកផ្តល់បទសម្ភាសបានឱ្យដឹងថាការប្រកបមុខរបរដូចជាការលក់ដូរមានភាពពិបាកខ្លាំង ដោយសារតែអាកាសធាតុក្តៅខ្លាំង គឺពុំសូវមានអ្នកចេញមកក្រៅ ដើម្បីទិញនោះទេ គេសម្ងំនៅតែក្នុងផ្ទះ។ ម្យ៉ាងទៀតចំពោះពួកគាត់ជាអ្នកលក់ដូរផ្ទាល់គាត់ពិតជាពិបាកក្នុងការអង្គុយនៅកន្លែងលក់ដោយសារក្តៅខ្លាំងគាត់ពុំសូវបាននៅជាប់លាប់នឹងកន្លែងលក់ដូរនោះទេ។ ពួកគាត់ភាគច្រើនក៏សម្ងំនៅក្នុងម្លប់ឬសម្ងំនៅក្នុងផ្ទះតែម្តង។

ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍រស្មីសាមគ្គីវ័យ ៥៣ឆ្នាំ បាននិយាយថា៖

> “លក់មិនដាច់ទេអូន គេចេញពីធ្វើការគេជិះរ៉ឺយៗ តម្រង់ទៅតែផ្ទះគេទេ។ ហើយណាមួយគេមិនឃើញអ្នកលក់នៅកន្លែងលក់ផងគេតម្រង់ទៅផ្ទះហើយ។”

### ក.២. បញ្ហាសុខភាព

ប្រជាសហគមន៍១៨នាក់ ក្នុងចំណោម ២២នាក់ ដែលទទួលបទសម្ភាសបានឱ្យដឹងថាដោយសារតែអាកាសធាតុក្តៅខ្លាំងពេកធ្វើឱ្យពួកគាត់ប្រឈមនឹងបញ្ហាក្តៅ

ខ្លួន ឈឺក្បាល ហៀរហត់រាល់ថ្ងៃ និងថប់ៗដង្ហើមជាញឹកញាប់។ រីឯក្មេងៗវិញភាគច្រើន គឺក្តៅខ្លួនញឹកញាប់ណាស់។

ប្រជាពលរដ្ឋដែលមានវ័យជាង ៤០ឆ្នាំ បាននិយាយថា៖

"រាល់ថ្ងៃ ដល់តែក្តៅពេកទៅបាយអីមិនឃ្លានទេ ស្រេកតែទឹកទេ បើនិយាយពីរឿងឈឺវិញ ទាំងក្មេងទាំងចាស់ ងាកគ្រុនក្តៅ ងាកផ្តាសាយ ។"

### ក.៣. បញ្ហាការចំណាយផ្សេងៗ

ចំពោះការចំណាយវិញពួកគាត់ភាគច្រើនបានលើកឡើងស្រដៀងនឹងសហគមន៍ពង្រសែនជ័យដែរ។ ប្រជាសហគមន៍មួយចំនួនបានបញ្ជាក់ថា នៅរដូវក្តៅប្រជាសហគមន៍ត្រូវនៅសម្ងំនៅមុខផ្ទះ និងនៅមុខកង្ហាររហូត ធ្វើឱ្យការចំណាយទៅលើថ្លៃទឹកថ្លៃភ្លើងកាន់តែច្រើនជាងមុន។ ក្នុងនោះដែរ ប្រជាសហគមន៍ខ្លះទៀតក៏បានលើកឡើងថា ដោយសារតែអាកាសធាតុក្តៅមនុស្សចាស់ និងក្មេងមានសុខភាពទន់ខ្សោយ និងឈឺច្រើន ដូចនេះហើយពួកគាត់ត្រូវចំណាយទៅលើថ្លៃពេទ្យថ្លៃថ្នាំច្រើនផងដែរ។

## ខ. ផលប៉ះពាល់នៅពេលមានភ្លៀងធ្លាក់ខ្លាំង

សហគមន៍រស្មីសាមគ្គីជាសហគមន៍មួយដែលរស់នៅតាមបណ្តោយប្រឡាយទឹកស្អុយនៅម្តុំសង្កាត់ ស្ទឹងមានជ័យ២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ។ នៅពេលដែលភ្លៀងធ្លាក់ខ្លាំងម្តងៗប្រជាសហគមន៍គាត់បានជួបប្រទះនូវបញ្ហាមួយចំនួនដូចជា៖

### ខ.១. បញ្ហាហេដ្ឋារចនាសម្ព័ន្ធ

ប្រមាណជា ៤១% នៃអ្នកផ្តល់បទសម្ភាសនៅក្នុងសហគមន៍រស្មីសាមគ្គីបានលើកឡើងថា នៅក្នុងសហគមន៍ពុំមានប្រព័ន្ធលូនោះទេ មានតែប្រឡាយដែលនៅពីក្រោយផ្ទះពួកគាត់តែប៉ុណ្ណោះ។ ហេតុដូច្នេះ នៅពេលមានភ្លៀងធ្លាក់ទឹកភ្លៀងនឹងហូរចូលក្នុងប្រឡាយដែលនៅក្រោយផ្ទះគាត់កំពុងរស់នៅនោះ ក្នុងករណីទឹកពេញក្នុងប្រឡាយ ទឹកទាំងនោះហូរចេញពីប្រឡាយចូលផ្ទះពួកគាត់ ទើបហូរកាត់មកផ្លូវវិញក្នុងករណីមានភ្លៀងខ្លាំង។ ដូច្នេះហើយពេលភ្លៀងម្តងៗអាចធ្វើឱ្យសហគមន៍ជន់លិចចន្លោះពី១ ទៅ២ម៉ោង និងជួនកាលអាចដល់កន្លះថ្ងៃ។

"តាមការឱ្យដឹងពីប្រជាសហគមន៍ដែលមានវ័យជាង៤០ឆ្នាំបានប្រាប់ថា "នៅក្នុងហ៊្នឹងអត់មានលូទេ ចឹងហើយបានឱ្យតែភ្លៀងខ្លាំងម្តងៗឬក៏ពេលគេបើកបង្ហូទឹកពីប្រឡាយលើហ្នឹងមកដឹងតែចាល់ហូរកាត់ផ្ទះចេញមកផ្លូវហ្មង" ។"

### ខ.២. បញ្ហាសុខភាព

បញ្ហាសុខភាពចម្បងរបស់សហគមន៍នោះ គឺបញ្ហាផ្លូវដង្ហើម ដែលបង្កដោយក្លិនស្អុយ។ ជិត១៩% នៃអ្នកផ្តល់បទសម្ភាសបានប្រាប់ថា ពួកគាត់ប្រឈមនឹងបញ្ហាផ្លូវដង្ហើមជាពិសេសគឺកុមារ។

ការរស់នៅជិតនឹងប្រឡាយដែលមានក្លិនស្អុយបានធ្វើឱ្យប្រជាជនជួបប្រទះនូវបញ្ហាក្អកស្ទួត ជំងឺបណ្ដាលឱ្យប្រតិកម្មច្រមុះជាដើម។ ដោយសារ សហគមន៍ត្រូវរស់នៅជាមួយនឹងក្លិនស្អុយពីប្រឡាយជារៀងរាល់ថ្ងៃជាពិសេសនៅពេលដែលមានភ្លៀងធ្លាក់ធ្វើឱ្យប្រឡាយមានក្លិនស្អុយភាយកាន់តែខ្លាំងឡើង ហើយក៏អាចបង្កឱ្យកើតមានមូសច្រើនផងដែរ។ ក្លិនស្អុយពីប្រឡាយនេះ បានក្លាយ ជាផលប៉ះពាល់យ៉ាងខ្លាំងទៅលើសុខភាពរបស់អ្នកដែលរស់នៅក្នុងសហគមន៍នេះ។

ប្រជាពលរដ្ឋដែលរស់នៅសហគមន៍សាមគ្គីដែលមានវ័យជាង៣០ឆ្នាំ បាននិយាយថា៖

> “ក្លិនស្អុយណាស់ជាពិសេសពេលមានភ្លៀងធ្លាក់ហើយរាំងទៅវិញក្លិនកាន់តែស្អុយខ្លាំង ដោយសារតែស្អុយខ្លាំងពេកខ្ញុំរាល់ថ្ងៃ និងទៅជា អាលែកហ្ស៊ីច្រមុះហើយ។”



### ខ.៣. បញ្ហាការខូចខាតសម្ភារៈ និងលំនៅឋាន

ការជន់លិចដែលបង្កដោយភ្លៀងខ្លាំងបណ្ដាលឱ្យមានផលប៉ះពាល់ដល់ការរស់នៅ និងសម្ភារៈប្រើប្រាស់របស់ប្រជាសហគមន៍ផងដែរ។ ជាក់ស្ដែងគ្រួសារមួយក្នុងចំណោមគ្រួសារទាំង៦០បានបញ្ជាក់ថា ក្នុងឆ្នាំ២០២២មានការហូរចាល់ទឹកពីប្រឡាយចូលមកក្នុងសហគមន៍ដែលធ្វើឱ្យផ្ទះរបស់គាត់ជន់លិចបណ្ដាលឱ្យខូចខាតម៉ូតូចំនួន១គ្រឿងដោយសារតែត្រាំក្នុងទឹកស្អុយ។ ក្រៅពីនេះ សម្ភារៈមួយចំនួនដូចជា ទូរទស្សន៍ ទូទឹកកក របស់របរ ឬក៏ទូធ្វើពីដែកក៏មានផលប៉ះពាល់ប្រសិនបើពួកគាត់មិនបានប្រមូលសម្ភារៈទាំងនោះទុកដាក់ឱ្យខ្ពស់ៗ។ ហេតុដូចនេះហើយ ប្រជាសហគមន៍ភាគច្រើនលើកឡើងថាវាមានផលលំបាកខ្លាំងក្នុងការរស់នៅពេលមានទឹកលិច។

ប្រជាសហគមន៍មានវ័យជាង៤០ឆ្នាំបាននិយាយថា៖

> “របស់របរខ្ញុំប្រើមិនដែលបានយូរទេអូនហ៊ើយ ងាកៗច្រេះចាប់ខូចចង់អស់ហើយដូចទូរទស្សន៍ទើបទិញ និងចង់ខូចបាត់ហើយ គេថាដោយសារតែមកពីទឹកស្អុយពីប្រឡាយ និងបានធ្វើឱ្យរបស់របរវាច្រេះចាប់ឆាប់ខូច” ។

### ខ.៤. បញ្ហាការរស់នៅ

ចំពោះបញ្ហាប្រឈមមួយទៀតរបស់ប្រជា

សហគមន៍នៅក្នុងសហគមន៍ស្មើសាមគ្គីនោះ  គឺរស់នៅប្រឈមនឹងការភ័យខ្លាច  ដោយសារតែប្រឡាយខាងក្រោយផ្ទះ សម្បូរទៅដោយសត្វល្អិតជាច្រើនរួមមាន មូស កន្លែប  និងកណ្ដុរ ហើយជាពិសេសនោះសត្វពស់ថ្លាន់ផងដែរ។

ប្រជាសហគមន៍វ័យជាង៣១ឆ្នាំបាននិយាយថា៖

នៅប្រឡាយក្រោយហ្នឹងសម្បូរពួកសត្វល្អិតតូចៗណាស់ ជាពិសេស គឺពស់ថ្លាន់ហ្នឹងហ្មង ជួនកាលងើបពីព្រឹកឃើញនៅលើកំប្លោកក្នុងប្រឡាយនិងក៏មានដែរ" ។

### ៥.៣. ខ្យល់កន្ត្រាក់

យោងតាមការសម្ភាសទាំងពីរសហគមន៍ ភាគច្រើននៃប្រជាសហគមន៍ បានបញ្ជាក់ថាពួកគាត់ធ្លាប់បានជួបប្រទះបញ្ហាខ្យល់កន្ត្រាក់ តែពុំមានផលប៉ះពាល់ធ្ងន់ធ្ងរដល់សហគមន៍នោះទេ។ គ្រាន់តែបើុងសម្ភារៈតិចតួច និងកួចសម្រាមមកតែប៉ុណ្ណោះ។



# ៦. ការបន្សាំខ្លួនក្នុងការរស់នៅ



## ៦.១. ពេលកម្តៅកើនឡើង

### ក. សហគមន៍ពង្រសែនជ័យ

យោងតាមទិន្នន័យដែលបានមកតាមរយៈការសម្ភាសគឺប្រជាសហគមន៍ភាគច្រើនគាត់បន្សាំខ្លួនតាមរយៈការងូតទឹក ការអង្គុយនៅនឹងមុខកង្ហារ និងញ៉ាំទឹកឱ្យបានច្រើនតាមតែអាចធ្វើទៅបាន។ អំឡុងពេលឡើងកម្តៅ ប្រជាសហគមន៍ភាគច្រើនគាត់បន្សាំដោយការងូតទឹកឱ្យបានច្រើនផង ហើយនៅនឹងមុខកង្ហារ។ ប្រជាសហគមន៍មួយចំនួនទៀតបន្សាំខ្លួនដោយ ការញ៉ាំទឹកឱ្យបានច្រើន និងងូតទឹកហើយសម្ងំនៅក្នុងបន្ទប់ទឹក និងយកក្រមាសើមមកស្អំលើក្បាល។ គ្រួសារមួយទៀតគាត់បានជះទឹកនៅក្នុងផ្ទះគាត់តែម្តងដើម្បីកាត់បន្ថយការក្តៅ។

ប្រជាពលរដ្ឋដែលនៅក្នុងសហគមន៍ពង្រសែនជ័យមានវ័យ៥០ឆ្នាំបានប្រាប់ថា៖

> ពេលក្តៅខ្លាំងពេកចៅខ្ញុំវារករឿងពេក ខ្ញុំយកទឹកមកជះនៅក្នុងផ្ទះហ្នឹង ពេលជះទៅវាចំហាយត្រជាក់មក វាធ្វើឱ្យគេជាក់មួយសន្ទុះដែរ។

### ខ. សហគមន៍ស្មើសាមគ្គី

អ្នកផ្តល់បទសម្ភាសម្នាក់នៅសហគមន៍ស្មើសាមគ្គីបានប្រាប់ថា ដើម្បីបន្សាំនិងអាកាសធាតុក្តៅបែបនេះគាត់ងូតទឹកឱ្យបានញឹកញាប់ ហើយពុំសូវចេញទៅក្រៅទេ ភាគច្រើនប្រជាសហគមន៍គាត់សម្ងំនៅក្នុងផ្ទះ និងនៅមុខកង្ហារ ហើយជាពិសេសនោះគាត់ញ៉ាំទឹកឱ្យបានច្រើន។ ហើយម្យ៉ាងទៀតគាត់ព្យាយាមដាំជាកូនឈើតូចៗនៅជុំវិញឬជិតផ្ទះ។

ប្រជាសហគមន៍នៅក្នុងសហគមន៍ស្មើសាមគ្គីវ័យ៤០ឆ្នាំបានប្រាប់ថា៖

> ខ្ញុំមានធ្វើអីទេមានតែនៅមុខកង្ហារ ហើយប្រឹងញ៉ាំទឹកឱ្យច្រើន ហើយដាំកូនឈើតូចៗ និងទៅវាបន្ថយក្តៅ និងខ្លះដែរ។

## ៦.២. អំឡុងពេលមានភ្លៀងធ្លាក់

### ក. សហគមន៍ពង្រសែនជ័យ

សមាជិកសហគមន៍ដែលបានផ្ដល់បទសម្ភាសបានលើកឡើងថា អំឡុងពេលមានភ្លៀងខ្លាំងដែលបណ្ដាលឱ្យទឹកក្នុងលូហូរមិនទាន់ ប្រជាសហគមន៍តែនាំគ្នាទៅស្ដារប្រឡាយ ដើម្បីសម្រួលការស្ទះ ឬក៏ទុកឱ្យវាស្រកដោយខ្លួនឯង។ ប្រជាជនខ្លះទៀតក៏នាំគ្នាទៅនៅផ្ទះដែលមានជាន់ខាងលើ ហើយចំណែកអីវ៉ាន់ត្រូវលើកទុកដាក់ឱ្យបាន ខ្ពស់ផុតពីទឹក។

### ខ. សហគមន៍រស្មីសាមគ្គី

ចំពោះរស្មីសាមគ្គីវិធីក្នុងការបន្សាំទៅនឹងបញ្ហានេះ គឺការចាំឱ្យទឹកស្រកទៅវិញ ដោយការចាំនៅមួយកន្លែង និងដាក់សម្ភារៈអីវ៉ាន់ផ្សេងឱ្យផុតពីទឹក។ ក្នុងករណីចាំបាច់ ធ្វើដំណើរទៅក្រៅពួកគាត់មានតែដើរកាត់ទឹកទៅវិញ ទៅមកនោះមានតែទិញថ្នាំលាបតែប៉ុណ្ណឹង។



# ៧. សេចក្តីសន្និដ្ឋាន



តាមរយៈការស្រាវជ្រាវបានបង្ហាញឱ្យឃើញថាប្រជាសហគមន៍បានជួបប្រទះនឹងបញ្ហាប្រែប្រួលអាកាសធាតុដូចជា បញ្ហាការឡើងកម្តៅ និងភ្លៀងធ្លាក់ខ្លាំង។ ប៉ុន្តែយោងតាមអ្នកឆ្លើយតបភាគច្រើននៅក្នុងការសម្ភាសទាំងពីរសហគមន៍បានឱ្យដឹងថាពួកគាត់ប្រឈមនឹងប៉ះពាល់ខ្លាំងជាងគេនោះ គឺនៅពេលដែលមានភ្លៀងធ្លាក់។

ជាក់ស្តែងតាមរយៈការប្រមូលទិន្នន័យនៅក្នុងសហគមន៍ពង្រសែនជ័យ បានឱ្យដឹងថានៅពេលភ្លៀងធ្លាក់ពួកគាត់ប្រឈមជាមួយនឹងទឹកលិចផ្លូវ ហើយទឹកទាំងនោះជាទឹកស្អុយដែលហូរចេញពីលូ និងបង្កឱ្យមានជម្រកមូសច្រើនដែលអាចចម្លងជម្ងឺគ្រុនឈាម ឬគ្រុនចាញ់ដល់ប្រជាសហគមន៍ផងដែរ។ តាមរយៈបញ្ហាទាំងនេះ ក៏អាច បង្ករជាឧសបគ្គក្នុងការធ្វើដំណើរប្រកបរបរ ឬអាជីវកម្ម និងការកើនឡើងថ្លៃទឹកថ្លៃភ្លើងក៏ជាបន្ទុកបន្ថែមសម្រាប់គ្រួសារផងដែរ។

សម្រាប់ សហគមន៍រស្មីសាមគ្គីវិញ បានឱ្យ ដឹងថា ពួកគាត់ភាគបានជួបប្រឈមចម្បងនោះ គឺបញ្ហាហេដ្ឋារចនាសម្ព័ន្ធដោយសារតែសហគមន៍មួយនេះ មិនមានប្រព័ន្ធលូនោះទេ សហគមន៍រស់នៅលើប្រឡាយដែលនៅខាងក្រោយផ្ទះនោះ តែប៉ុណ្ណោះដូចនេះហើយអាចធ្វើឱ្យពួកគាត់ជួបប្រទះនូវការលិចលង់ជាញឹកញាប់ដែលបណ្តាលមកពីទឹកភ្លៀង។ ហើយការលិចលង់នេះ



# ៨. អនុសាសន៍



## ១. ប្រជាពលរដ្ឋ

- ប្រជាពលរដ្ឋគួរស្វែងយល់ឱ្យបានច្រើនពីបម្រែបម្រួលអាកាសធាតុតាមរយៈការមើលឯកសារផ្សេងៗដែលរៀបរាប់ពីការប្រែប្រួលនៃអាកាសធាតុនិងរបៀបនៃការបន្សាំខ្លួនជាដើម ហើយចូលរួមក្នុងការដាំដើមឈើឱ្យបានច្រើនជាងមុន។
- ប្រជាពលរដ្ឋគួររាយការណ៍ពីបញ្ហាដែលខ្លួនបានជួបប្រទះទៅកាន់អាជ្ញាធរមូលដ្ឋាននិងសហការណ៍ជាមួយអាជ្ញាធរមូលដ្ឋានក្នុងការដោះស្រាយបញ្ហាដែលបានជួបប្រទះនៅក្នុងសហគមន៍។

## ២. អាជ្ញាធរមូលដ្ឋាន

- អាជ្ញាធរមូលដ្ឋានគួរចូលរួមក្នុងការដោះស្រាយជូនប្រជាសហគមន៍ទាំងពីរឱ្យបានសកម្មចំពោះបញ្ហាចម្បងមួយចំនួនដូចជា ការរៀបចំនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ នៅក្នុងសហគមន៍ឱ្យបានល្អឡើងវិញ និងការចុះទៅបាញ់ថ្នាំកម្ចាត់សត្វល្អិត ឬកម្ចាត់សត្វមូសជូនប្រជាសហគមន៍ជាដើម។
- អាជ្ញាធរមូលដ្ឋានគួរចុះពិនិត្យមើលសហគមន៍ឱ្យបានញឹកញាប់ ដើម្បីធ្វើបច្ចុប្បន្នភាពបញ្ហាដែលប្រជាពលរដ្ឋបានជួបប្រទះ ដោយការជួបប្រជុំជាមួយសហគមន៍១ខែ ឬ២ខែម្តងដើម្បីឱ្យប្រជាសហគមន៍លើកជាសំណូមពរទៅកាន់អាជ្ញាធរមូលដ្ឋាន។



បានធ្វើឱ្យគាត់ទាំងអស់គ្នាជួបប្រទះនូវបញ្ហាជាច្រើន រួមមានទាំងការធ្វើដំណើរ បញ្ហាសុខភាព ការរស់នៅប្រចាំថ្ងៃ ព្រមទាំងការប្រកបរបររកស៊ីផងដែរ។ តាមទិន្នន័យដែលបានមកនោះអាចឱ្យដឹងថា ប្រជាសហគន៍រស្មីសាមគ្គីអាចមានផលប៉ះពាល់ខ្លាំងជាងប្រជាសហគមន៍ពង្រសែនជ័យ ក្នុងការរស់នៅប្រចាំថ្ងៃដោយសារតែនៅប្រឡាយខាងក្រោយផ្ទះរបស់ប្រជាសហគមន៍រស្មីសាមគ្គីគឺសម្បូរទៅដោយសត្វល្អិត និងសត្វអសិរពិសជាច្រើនដែលធ្វើឱ្យពួកគាត់ពិបាកខ្លាំងក្នុងការរស់នៅ។

រីឯវិធីសាស្ត្រនៃការបន្សាំខ្លួន របស់សហគមន៍ទាំងពីរដែលពួកគាត់អាចធ្វើបាននោះគឺមានតែ ទ្រាំរស់នៅជាមួយនឹងអាកាសធាតុបែបនេះ ដូចជាអំឡុងពេលក្ដៅត្រូវងូតទឹកឱ្យបានច្រើន ហើយនៅពេលមានភ្លៀងលិចលង់សហគមន៍គឺពុំមានវិធីសាស្ត្រអ្វីនោះទេគឺមានតែទ្រាំនៅរហូតដល់ទឹកស្រកអស់ទៅវិញ។

### ៣. អង្គការឬស្ថាប័នពាក់ព័ន្ធ

- អង្គការឬស្ថាប័នពាក់ព័ន្ធគួរលើកកម្ពស់ការយល់ដឹងអំពីការប្រែប្រួលអាកាសធាតុនិងរបៀបនៃការបន្សាំខ្លួនដល់ប្រជាពលរដ្ឋតាមរយៈការចែកចាយឯកសារផ្សេងៗដែលរៀបរាប់ពីការប្រែប្រួលអាកាសធាតុនិងរបៀបនៃការបន្សាំខ្លួនទៅប្រជាពលរដ្ឋ។
- អង្គការឬស្ថាប័នពាក់ព័ន្ធអាចផ្តល់ជាជំនួយជាថវិកាទៅលើប្រជាពលរដ្ឋដែលបានជួបប្រទះបញ្ហាសុខភាពនិងសេដ្ឋកិច្ចដោយសារបញ្ហាលិចលង់និងការឡើងកម្តៅខ្លាំង។

*RESEARCH REPORT: BY HOY SREYHONG*

# POLUTION BY LOUD MUSIC IN POOR COMMUNITY:

# CHALLENGES AND IMPACT



# តារាងមាតិកា


០១ សេចក្តីផ្តើម........................................................................១

០២ គោលបំណងក្នុងការសិក្សាស្រាវជ្រាវ ....................................................២

០៣ វិធីសាស្ត្រស្រាវជ្រាវ..............................................................................៤
៣.១. ការប្រមូលទិន្នន័យ..................................................................... ..៤
៣.២. ក្រមសីលធម៌អ្នកស្រាវជ្រាវ...............................................................៥

០៤ ច្បាប់និងក្របខណ្ឌគតិយុត្តិទាក់ទងនឹងការបំពុលដោយសំលេង.....................៦
៤.១. អនុក្រិតស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង...........................................................................៦
៤.២. អនុក្រិតលេខ ៤៣ អនក្រ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅ រាជធានីភ្នំពេញ និងខេត្តក្រុង.......................................................................៧

០៥ លទ្ធផលនៃការស្រាវជ្រាវ.............................................................................៨
៥.១. ទិដ្ឋភាពទូទៅរបស់សហគមន៍ទាំងពីរ.........................................៨
៥.២. ការយល់ដឹងរបស់ប្រជាពលរដ្ឋពីការបំពុលដោយសំលេង................៩
៥.៣. ប្រភេទ និងប្រភពនៃការបំពុលដោយសំលេងដែលមានក្នុងសហគមន៍.....................................................................១០
៥.៤. ប្រភពនៃការបំពុលសំលេង.......................................................១១
៥.៥. បញ្ហាប្រឈមដែលបង្កដោយការបំពុលដោយសំលេង....................១២
៥.៦. ដំណោះស្រាយសម្រាប់ការបំពុលសំឡេង..................................១២
៥.៧. អន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន...............................................១៣
៥.៨. ប្រសិទ្ធភាពនៃការឆ្លើយតបរបស់អាជ្ញាធរ...................................១៤

# តារាងមាតិកា

០៦ សេចក្តីសន្និដ្ឋាន.................................................................................១៥
០៧ អនុសាសន៍.........................................................................................១៧

# ១. សេចក្តីផ្តើម



សំឡេងរំខានដែលបង្កើតដោយសកម្មភាពមនុស្សហើយមានទំនាក់ទំនងនឹងការរស់នៅសមរម្យនៅក្នុងកម្រិតបរិស្ថាននៃតំបន់ជាក់លាក់មួយត្រូវបានផ្លាស់ប្តូរជាអវិជ្ជមានគឺជាការបំពុលដោយសំឡេង។ ការបំពុលដោយសំឡេង ពិបាកមើលឃើញ វាមានភាពស្មុគស្មាញក្នុងការវាស់វែង និងស្របពេលជាមួយគ្នានោះវាបានធ្វើឱ្យប៉ះពាល់យ៉ាងខ្លាំងដល់ការរស់នៅរបស់មនុស្សជារៀងរាល់ថ្ងៃ។[១] យោងតាមអត្ថបទស្តីពីការបំពុលសំឡេងរបស់ National Geographic Education សំឡេងរំខានដែលធ្វើឱ្យប៉ះពាល់ដល់សុខភាពមនុស្សត្រូវចាត់ទុកថាជាការបំពុលសំឡេង។ តាមការសិក្សាដដែល កម្រិតនៃសំឡេងត្រូវវាស់ជាដេស៊ីប៊ែល (decibels )។[២]

ការបំពុលដោយសំឡេងមានដូចជាការបំពុលចេញពីការធ្វើចរាចរណ៍ (ផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស) សំឡេងចេញមកពីកន្លែងកំសាន្ត(តន្ត្រីៗ) សំឡេងស្រែកឡូឡា សំឡេងចេញពីរោងចក្រ សិប្បកម្ម ឧស្សាហកម្ម និងការដ្ឋានសាងសង់នានា។ សំឡេងដែលកើតឡើងដោយសកម្មភាពមនុស្សទាំងនេះត្រូវបានប៉ាន់ប្រមាណថាមានកម្រិតរំខាននៃសំឡេងចាប់ពី៣០ ដេស៊ីប៊ែល (dB) ទៅ ១៤០ ដេស៊ីប៊ែល (dB)។[៣] ការបំពុលដោយសំឡេងផ្តល់ផលប៉ះពាល់ជាច្រើនដូចជា ប៉ះពាល់ដល់ការស្តាប់ ប៉ះពាល់ដល់សុខភាពរាងកាយ ដូចជាឈឺក្បាលឡើងសម្ពាធឈាម គាំងបេះដូង ធ្វើឱ្យមានបញ្ហាដល់សុខភាពផ្លូវចិត្តដូចជាមាន ជំងឺធ្លាក់ទឹកចិត្ត ជំងឺថប់អារម្មណ៍ មានអារម្មណ៍ល្ហិតល្ហៃអស់កម្លាំង មានភាពតានតឹងក្នុងអារម្មណ៍ មានបញ្ហាការគេងដូចជា គេងមិនបានគ្រប់គ្រាន់ គេងមិនស្កប់ ពិបាកក្នុងការផ្តោតអារម្មណ៍ដូចជា ពិបាកក្នុងការផ្ចង់អារម្មណ៍ក្នុងការធ្វើការងារ និងការសិក្សា។[៤] ការសិក្សាស្រាវជ្រាវនេះបានធ្វើឡើងក្នុងគោលបំណងសិក្សាពីបញ្ហាប្រឈម និងផលប៉ះពាល់ជាក់ស្តែងពីការបំពុលដោយសំឡេងនៅក្នុងសហគមន៍ចំនួន ២ គឺសហគមន៍ព្រែកតាគង់៦០ម៉ែត្រ និងសហគមន៍អណ្តូង១ដែលមានទីតាំងនៅរាជធានីភ្នំពេញ។ ជាលទ្ធផលការសិក្សាស្រាវជ្រាវនេះបានបង្ហាញថា៖

### ក. បញ្ហាប្រឈម

- ប្រជាសហគមន៍ភាគច្រើនខ្វះការយល់ដឹងអំពីអ្វី

[១] សូមមើលអត្ថបទរបស់ អាណាអិល៖ តើការបំពុលសំលេងរំខានគឺជាអ្វីហើយតើវាជះឥទ្ធិពលដល់យើងយ៉ាងដូចម្តេច? ទាញចេញពីគេហទំព័រ៖ https://madreshoy.com/km/que-es-la-contaminacion-acustica-y-como-nos-afecta/
[២] ការបំពុលសំឡេងត្រូវបានចាត់ទុកថាជាសំឡេងរំខានណាមួយ ដែលប៉ះពាល់ដល់សុខភាព សុខុមាលភាព និងសរីរាង្គផ្សេងទៀតរបស់មនុស្ស។
[៣] សូមមើល https://www.geeksforgeeks.org/noise-pollution/
[៤] ដូចខាងលើ

ទៅជាការបំពុលដោយសំឡេង និងបញ្ហាដែលកើតឡើងពីការបំពុលដោយសំឡេង។

- សហគមន៍ទាំង២គឺសុទ្ធតែទទួលរងនៅការបំពុលដោយសំឡេង ដែលសំឡេងទាំងនោះរួមមានសំឡេងមនុស្សស្រែកពេលយប់ដែលមានប្រភពមកពីការលួច និងចែកចាយគ្រឿងញៀននៅពេលយប់របស់ក្មេងទំនើង សំឡេងម៉ាស៊ីនបាញ់មូសចេញពីអាគារខុនដូរ(នៅជាប់សហគមន៍ព្រែកតាគង់៦០ម៉ែត្រ) សំឡេងមនុស្សឡូឡា និងសំឡេងតន្ត្រីតាមផ្ទះដែលកើតចេញមកពីការចាក់ស្តាប់តន្ត្រី និងការជួបជុំគ្នាទទួលទានគ្រឿងស្រវឹង។

### ខ. ផលប៉ះពាល់ជាក់ស្តែង

- សុខភាពរាងកាយ៖ ចំពោះមនុស្សចាស់ឬមនុស្សពេញវ័យវាបង្កឱ្យមានបញ្ហាបេះដូង ការគេង ឈឺក្បាល អស់កម្លាំង ចំពោះកុមារនិងទារក វាបង្កឱ្យមានការភ័យខ្លាច។
- សុខភាពផ្លូវចិត្ត៖ មានអារម្មណ៍ភ័យខ្លាច គ្មានសុវត្ថិភាព ធុញថប់ខ្លាំង តានតឹងក្នុងអារម្មណ៍។
- មានអំពើហិង្សា ពិបាកក្នុងការរស់នៅ បាត់បង់ទំនាក់ទំនងល្អ និងបង្កឱ្យមានភាពអាណាធិបតេយ្យនៅក្នុងសហគមន៍។



# ២. គោលបំណងក្នុងការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានគោលបំណង៖

- ឈ្វេងយល់ពីបច្ចុប្បន្នភាពនៃការបំពុលដោយសំឡេង ប្រភពនិងប្រភេទនៃការបំពុលសំឡេងដែលកើតមានឡើងនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រ និងសហគមន៍អណ្តូង១។
- ឈ្វេងយល់ពីបញ្ហាប្រឈម និងផលវិបាកនៃការបំពុលសំឡេងដែលកើតមានឡើងនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រ និងសហគមន៍អណ្តូង១។

## ២.១. ចំណោទបញ្ហាសំខាន់ៗក្នុងការសិក្សាស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងឆ្លើយតបសំណួរសំខាន់ៗបី៖

ក) តើសហគមន៍ព្រែកតាគង់៦០ម៉ែត្រ និងសហគមន៍អណ្តូង១ មានបញ្ហាបំពុលដោយសំឡេងដែរឬទេ?

ខ) តើការបំពុលសំឡេងបានធ្វើឱ្យសហគមន៍ទាំង២រងនូវផលប៉ះពាល់ និងបញ្ហាប្រឈមអ្វីខ្លះ?

គ) តើអ្វីខ្លះជាដំណោះស្រាយ?



# ៣. វិធីសាស្ត្រសិក្សាស្រាវជ្រាវ



## ៣.១. ការប្រមូលទិន្នន័យ

ការសិក្សាស្រាវជ្រាវនេះធ្វើឡើងតាមរយៈកម្រងសំណួរ ការស្ទង់មតិ និងការសិក្សាពីច្បាប់គតិយុត្តិទាក់ទងនឹងការបំពុលដោយសំឡេងនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រដែលមានទីតាំងនៅសង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យ និងសហគមន៍អណ្តូង១ដែលមានទីតាំងនៅសង្កាត់គោករកា ខណ្ឌព្រែកព្នៅ រាជធានីភ្នំពេញ ។ ការចុះប្រមូលទិន្នន័យត្រូវបានធ្វើឡើង តាមរយៈការស្ទង់មតិ និងការធ្វើបទសម្ភាសន៍ ដែលបទសម្ភាសន៍នីមួយៗមានរយៈពេលចន្លោះពី៤៥ទៅ៦០នាទី។ សរុបចំនួន៥០សំណាក ដែលក្នុងនោះមាន៣៣សំណាកបានទទួលពីសហគមន៍ព្រែកតាគង់៦០ម៉ែត្រ (ស្ត្រី ២២នាក់ បុរស ១១នាក់ ក្នុងចំណោមស្ត្រី២២នាក់មានប្រធានសហគមន៍១នាក់ និងអនុប្រធានសហគមន៍១នាក់) និង១៧សំណាកពីសហគមន៍អណ្តូង១ (ស្ត្រី ៩នាក់ បុរស ៨នាក់ ក្នុងចំណោមបុរស៨នាក់មានអនុប្រធានភូមិម្នាក់)។ ដើម្បីសម្រេចបាននូវគោលបំណងនៃការសិក្សា ការវាយតម្លៃខ្លីៗនឹងត្រូវបានធ្វើឡើងតាមរយៈការរួមបញ្ចូលគ្នា រវាងវិធីសាស្ត្រក្នុងការសម្ភាសន៍ ការប្រើប្រាស់សំណួរស្រាវជ្រាវ (បែបគុណវិស័យ និងបរិមាណ) ដើម្បីទទួលបានព័ត៌មានសំខាន់ៗក្នុងការស្ទង់មតិនិងនៅពេលចុះទៅយកទិន្នន័យដោយផ្ទាល់។

ការប្រមូលទិន្នន័យនៅក្នុងហគមន៍ព្រែកតាគង់៦០ម៉ែត្រ ត្រូវបានធ្វើឡើងចំនួន៣ថ្ងៃ។

ការប្រមូលទិន្នន័យលើកទី១និងទី២ធ្វើឡើងដោយការចុះទៅសហគមន៍ដោយផ្ទាល់ រីឯលើកទី៣ធ្វើឡើងតាមរយៈសម្ភាសន៍តាមទូរស័ព្ទដោយផ្ទាល់។

សកម្មភាពចុះទៅប្រមូលទិន្នន័យ
(សហគមន៍ព្រែកតាគង៦០ម៉ែត្រ)

១. លើកទី១ ធ្វើឡើង នៅថ្ងៃទី១១ ខែឧសភា ឆ្នាំ២០២៣
២. លើកទី២ ធ្វើឡើងនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២៣
៣. លើកទី៣ ធ្វើឡើងនៅថ្ងៃទី៣ ខែកក្កដា ឆ្នាំ២០២៣

ការប្រមូលទិន្នន័យនៅក្នុងសហគមន៍អណ្តូង១

ធ្វើឡើងចំនួន២ថ្ងៃ។ លើកទីមួយចុះទៅស្ទង់មតិនិងប្រមូលទិន្នន័យដោយផ្ទាល់ និងលើកទីពីរធ្វើឡើងតាមរយៈសម្ភាសន៍តាម ទូរស័ព្ទដោយផ្ទាល់។

សកម្មភាពចុះទៅប្រមូលទិន្នន័យ (សហគមន៍អណ្តូង១)

១. លើកទី១ ធ្វើឡើងនៅថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២៣
២. លើកទី២ ធ្វើឡើងនៅថ្ងៃទី៦ ខែកក្កដា ឆ្នាំ២០២៣

មូលហេតុដែលកំណត់យកសហគមន៍ព្រែកតាគង់៦០ម៉ែត្រនិងសហគមន៍អណ្តូង១ធ្វើជាគំរូសម្រាប់ការសិក្សាស្រាវជ្រាវនេះឡើងដោយសារប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ទាំងពីរនេះ បាននិងកំពុងជួបប្រទះនូវការបំពុលសំឡេងនៅក្នុងសហគមន៍យ៉ាងអាណាធិបតេយ្យ និងរងនូវផលប៉ះពាល់ជាច្រើនពីការបំពុលដោយសំឡេងជាប្រចាំ។

## ៣.២ ក្រមសិលធម៌អ្នកស្រាវជ្រាវ

ដើម្បីបង្កាហានិភ័យផ្សេងៗដល់អ្នកចូលរួម អ្នកស្រាវជ្រាវបានប្រកាន់ភ្ជាប់ក្រមសិលធម៌យ៉ាងខ្ជាប់ខ្ជួនដូចជា ការរក្សាការសម្ងាត់ គោរពភាពចម្រុះ និងដើម្បីធានាអនាមិកភាព និងការសម្ងាត់នៃការសិក្សា។ អ្នកដែលបានផ្តល់បទសម្ភាសន៍ទាំងអស់នៅក្នុងការសិក្សាស្រាវជ្រាវនេះត្រូវបានជូនដំណឹងអំពីគោលបំណងនៃការសិក្សា ហើយបានស្នើសុំឱ្យផ្តល់ការយល់ព្រមរបស់ពួកគេដើម្បីចូលរួម។ អ្នកឆ្លើយសំណួរអាចមិនឆ្លើយ រំលងសំណួរ ឬដកខ្លួនចេញពីការសម្ភាសន៍បានគ្រប់ពេល។

មិនមានព័ត៌មានកំណត់អត្តសញ្ញាណណាមួយរបស់អ្នកផ្តល់បទសម្ភាសន៍ត្រូវបានបញ្ចេញនៅក្នុងការសរសេររបាយការណ៍នេះទេ។



# ៤. ច្បាប់និងក្របខណ្ឌគតិយុត្តិ ទាក់ទងនឹងការបំពុលដោយសំឡេង



## ៤.១. អនុក្រឹត្យស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំឡេង

មាត្រា៧

កម្រិតស្តង់ដារបញ្ចេញសំឡេង ពីប្រភពយានយន្ត ទីតាំងផលិតកម្ម និងកំរិតកំណត់ស្តង់ដារសំឡេងអតិបរមាសម្រាប់ទីកន្លែងសាធារណៈ និងតំបន់លំនៅដ្ឋានមានចែងនៅក្នុងតារាងឧបសម្ព័ន ៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ៧។

មាត្រា៩

ហាមឃាត់ដាច់ខាតនូវការបង្ក អោយមានសំឡេង ដែលមិនឆ្លើយតបទៅនឹងកំរិតកំណត់ស្តង់ដារដូចមានចែងនៅក្នុងតារាងឧបសម្ព័ន៥ ឧបសម្ព័ន្ធ៦ និងឧបសម្ព័ន្ធ៧។

មាត្រា៣០

ក្នុងករណី មានពាក្យបណ្តឹង ឬសេចក្តីរាយការណ៍ថាប្រភពបំពុលណាមួយបានបញ្ចេញសារធាតុបំពុលខ្យល់ ឬសំឡេង ឬរំញ័របង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ ក្រសួងបរិស្ថានដោយសហការជាមួយក្រសួងពាក់ព័ន្ធមានសិទ្ធិធ្វើអធិការកិច្ចនៅក្នុងបរិវេណប្រភពបំពុលនោះ និងយកគំរូតាងមកធ្វើការវិភាគ ។

មាត្រា៣១

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលសំឡេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។

មាត្រា៣២

ក្នុងករណីបទល្មើសជាក់ស្តែងដែលបង្កអោយមានការបំពុលសំឡេង មន្ត្រីអធិការកិច្ចក្រសួងបរិស្ថានត្រូវ៖

ក- ធ្វើកំណត់ហេតុ ប្រមូលឃាត់ទុកវត្ថុតាងនៃបទល្មើស និងធ្វើការពិន័យអន្តរការណ៍ប្រសិនបទល្មើសនោះមិនបង្កដោយមានការបំពុលធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន។

ខ- ប្រមូល និងឃាត់ទុកវត្ថុតាងនៃបទល្មើសនោះ ដើម្បីធ្វើកំណត់ហេតុ និងបញ្ជូលសំណុំរឿង

ទៅស្ថាប័នមានសមត្ថកិច្ច ប្រសិនបើបទល្មើសនោះកំណត់ហេតុធ្ងន់ធ្ងរ ឬប៉ះពាល់ដល់សុខភាព ឬទ្រព្យសម្បត្តិសាធារណៈ និងគុណភាពបរិស្ថាន។

មាត្រា ២៥

ក្នុងករណីដែលរកឃើញថាការបញ្ចេញសារធាតុបំពុលខ្យល់ និងសំឡេងពីប្រភពណាមួយពុំបានឆ្លើយតបទៅ និងកម្រិតស្តង់ដារដូចមានចែងក្នុងមាត្រា៥ មាត្រា៧ នៃអនុក្រិត្យនេះ ក្រសួងបរិស្ថានត្រូវ៖

ក- ចេញបញ្ជាជាលាយលក្ខណ៍អក្សរគំរូឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះធ្វើការកែប្រែសកម្មភាពល្មើសជាបន្ទាន់ក្នុងរយៈពេលជាក់លាក់មួយ។

ខ- ចេញបញ្ជាជាលាយលក្ខណ៍អក្សរគំរូឱ្យម្ចាស់កម្មសិទ្ធិ ឬអ្នកទទួលខុសត្រូវប្រភពបំពុលនោះផ្អាកសកម្មភាពរបស់ខ្លួនជាបណ្តោះអាសន្នរហូតដល់បទល្មើសនោះត្រូវបានកែប្រែ ប្រសិនបើសកម្មភាពល្មើសបង្កឱ្យមានគ្រោះថ្នាក់ដល់សុខភាពសាធារណៈ ឬប៉ះពាល់ដល់គុណភាពបរិស្ថាន។

មាត្រា ៣១

ក្នុងករណីមានឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរណាមួយនៃការបំពុលសំឡេង ក្រសួងបរិស្ថានត្រូវចុះធ្វើអធិការកិច្ចជាបន្ទាន់លើបញ្ហាឧបទ្ទវហេតុ ឬគ្រោះថ្នាក់ធ្ងន់ធ្ងរនោះ និងត្រូវជូនព័ត៌មានទៅស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន។[៥]

## ៤.២ អនុក្រឹត្យលេខ៤៣ អនក្រ ស្តីពីសណ្តាប់ធ្នាប់សាធារណៈនៅ រាជធានីភ្នំពេញ និងខេត្តក្រុង

ច្បាប់នេះ មានគោលបំណង ធានាការគ្រប់គ្រងសណ្តាប់ធ្នាប់សាធារណៈឱ្យមានរបៀបរៀបរយ សោភ័ណភាពអនាម័យបរិស្ថាន ភាពស្ងប់ស្ងាត់ សុវត្ថិភាព សង្គមរក្សាប្រពៃណីជាតិ និងសេចក្តីថ្លៃថ្នូររបស់ប្រជាពលរដ្ឋ។ ដែលផ្តោតទៅលើជាតុសំខាន់៥ រួមមាន សោភ័ណភាព អនាម័យ ភាពស្ងប់ស្ងាត់ សុវត្ថិភាព និងសណ្តាប់ធ្នាប់។

មាត្រា១៦

ជនណា បង្កសំឡេងកងរំពង ឬឈ្លោះប្រដែកគ្នាធ្វើអោយប៉ះពាល់ដល់ភាពស្ងប់ស្ងាត់ និងសណ្តាប់ធ្នាប់សង្គមសាធារណៈដោយគ្មានការអនុញ្ញាតត្រូវពិន័យជាប្រាក់៥០០០៛។ ក្នុងករណីពុំរាងចាលត្រូវពិន័យជាប្រាក់ទ្វេរមួយជាពីរ។[៦]



[៥] អនុក្រឹត្យលេខ៤២ ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង។ ទាញចេញពីគេហទំព័រៈ https://www.moe.gov.kh/wp-content/uploads/2017/02/Sub-decree_Air-and-Noise-Pollution.pdf
[៦] http://www.ecosocc.gov.kh/images/regulations/Sub_043_08_94.pdf

# ៥. លទ្ធផលនៃការស្រាវជ្រាវ



## ៥.១ ទិដ្ឋភាពទូទៅរបស់សហគមន៍ទាំងពីរ

*សហគមន៍ព្រែកតាគង់៦០ម៉ែត្រ*

សហគមន៍នេះមានទីតាំងស្ថិតនៅភូមិព្រែកតាគង់សង្កាត់ចាក់អង្រែលើ ខណ្ឌមានជ័យរាជធានីភ្នំពេញជាប់នឹងអាគារខុនដូរ អឺបេិន វីលីក (Urban Villages) សហគមន៍ព្រែកតាគង់៦០ម៉ែត្រមានប្រជាជនសរុប២៨១នាក់ មាន៦៣គ្រួសារ មានចំនួនស្ត្រី១៦៧នាក់។ ប្រជាសហគមន៍ប្រមាណ៨០% បានមករស់នៅទីតាំងនេះដោយសារមូលហេតុនៃការបណ្ដេញចេញនៃគម្រោងអភិវឌ្ឍន៍នានា។ ប្រជាសហគមន៍នៅទីនេះជួបបញ្ហាជាច្រើនដូចជា ស្ថានភាពគ្រួសារមានភាពខ្វះខាត មានទីលំនៅមិនសមរម្យ នៅពេលដែលមានភ្លៀងធ្លាក់ម្ដងៗគឺមានទឹកលិច មិនមានប្រព័ន្ធលូ បញ្ហាគ្រឿងញៀន មានអ្នកចំណូលថ្មីដែលមិនមានអត្តសញ្ញាណច្បាស់លាស់ចូលមករស់នៅក្នុងភូមិ ការលេងល្បែងស៊ីសងក្នុងភូមិ ក្មេងទំនើងដែលបង្កការលំបាកក្នុងការរស់នៅនិងអាចបង្កជាហានិភ័យជាខ្លាំងដល់ប្រជាសហគមន៍។



## សហគមន៍អណ្តូង១

សហគមន៍ នេះមានទីតាំងនៅភូមិអណ្តូង១ សង្កាត់គោករកា ខណ្ឌព្រែកព្នៅ ដែលមានចំនួនជាង២០០គ្រួសារ។ ប្រវត្តិនៃសហគមន៍នេះពីមុនមកធ្លាប់មានអ្នកចំណូលថ្មីមកពីសហគមន៍បុរីកីឡាដែលត្រូវបានបណ្តេញចេញទាំងបង្ខំពីសំណាក់ក្រុមហ៊ុនអភិវឌ្ឍន៍និងអាជ្ញាធររាជធានីភ្នំពេញ ដែលមករស់នៅក្នុងសហគមន៍អណ្តូងចាស់ដែលគេហៅពួកគាត់ថាអ្នកភូមិអណ្តូងថ្មី។ សហគមន៍នេះបានចងក្រងនៅខែមករា ឆ្នាំ២០០៦។ ការរស់នៅរបស់អ្នកចំណូលថ្មីមិនសូវមានជីវភាពល្អប្រសើរឡើយ មានការរស់នៅចម្រុះលាយឡំគ្នា ចំណែកឯស្ថានភាពគ្រួសារក្នុងសហគមន៍មិនមានលក្ខណៈដូចគ្នានោះទេ មានអ្នកខ្លះមានជីវភាពធូរធារអ្នកខ្លះមានជីវភាពមធ្យមនិងអ្នកខ្លះទៀតមានជីវភាពក្រលំបាកនៅតាមស្ថានភាពគ្រួសារនីមួយៗ។



## ៥.២. ការយល់ដឹងរបស់ប្រជាពលរដ្ឋពីការបំពុលដោយសំឡេង

តិចជាងពាក់កណ្តាលនៃប្រជាសហគមន៍ព្រែកតាគង់៦០ម៉ែត្រនិងអណ្តូង១ដែលបានផ្តល់សម្ភាសន៍មានការយល់ដឹងពីថាតើអ្វីទៅជាការបំពុលដោយសំឡេង។ យោងតាមការសម្ភាសប្រជាពលរដ្ឋនៅក្នុងសហគមន៍ ព្រែកតាគង់៦០ម៉ែត្រ ចំនួន៤៦%បានបញ្ជាក់ថាសហគមន៍របស់ពួកគាត់មានការបំពុលដោយសំឡេងក្នុងនោះ មាន ៣៣% បានប្រាប់ថាមានការបំពុលដោសំឡេងខ្លះៗដែរ។

បន្ថែមពីនេះទៅទៀត មានមនុស្ស១៨%ទៀតបាននិយាយថាមិនមានការបំពុលដោយសំឡេងកើតឡើងឡើយ និង៣%ទៀតបានប្រាប់ថាសហគមន៍មិនមានការបំពុលសំឡេងសោះ។

សម្រាប់សហគមន៍អណ្តូង១ តួលេខបានបញ្ជាក់ថាប្រជាសហគមន៍ប្រមាណ២៩%បាននិយាយថាសហគមន៍អណ្តូង១មានការបំពុលដោយសំឡេង រីឯ៦៥%ទៀតបានបញ្ជាក់ថាមានខ្លះៗនិង ៦% ទៀតបានបញ្ជាក់ថាមិនមានការបំពុលដោយសំឡេងនោះទេ។






## ៥.៣. ប្រភេទ និងប្រភពនៃការបំពុលដោយសំឡេងដែលមានក្នុងសហគមន៍

លទ្ធផលដែលបានមកពីការធ្វើបទសម្ភាសជាមួយប្រជាសហគមន៍ទាំងពីរបានបង្ហាញថា សហគមន៍ព្រែកតាគង់៦០ម៉ែត្របាននឹងកំពុងប្រឈមនឹងបញ្ហាការបំពុលសំឡេងច្រើនជាងសហគមន៍អណ្តូង១ ដែលការបំពុលសំឡេង និងប្រភពនៃការបំពុលសំឡេងទាំងនោះកំពុងធ្វើឱ្យមានផលប៉ះពាល់ជាអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់ប្រជាជនដែលរស់នៅក្នុងសហគមន៍ទាំងពីរ ជាពិសេសសហគមន៍ព្រែកតាគង់៦០ម៉ែត្រ។

បើយោងតាមលទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថាប្រជាសហគមន៍ដែលរស់នៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រមានចំនួន៦៧% ច្រើនទទួលរងការបំពុលសំឡេងចេញពីមនុស្សដើរឡូឡាពេលយប់និងសំឡេងនៃការឈ្លោះប្រកែកគ្នានៃក្រុមអ្នកជួញដូរគ្រឿងញៀនជាដើម។

១៨%នៃអ្នកផ្តល់បទសម្ភាសនៅក្នុងសហគមន៍ដដែលបានប្រាប់ថាសហគមន៍មិនសូវមានការបំពុលសំឡេងទេ ដូច្នេះមិនអាចកំណត់ប្រភពនៃការបំពុលសំឡេងបានឡើយ និង១៥%ទៀតទទួលរងការបំពុលសំឡេងចេញពីប្រភពខុនដូរអាគារនៅជាប់សហគមន៍របស់ពួកគាត់ហើយសំឡេងនោះគឺជាសំឡេងបាញ់មូស។

> ស្ត្រីវ័យកណ្តាលម្នាក់បានពោលថា “ប្រភពនៃការបំពុលសំឡេងមកពីមនុស្សដែលរស់នៅក្នុងសហគមន៍ មានមនុស្សមិនល្អមួយក្រុមធំមានការប្រើប្រាស់គ្រឿងញៀន។ ពួកអ្នកប្រើប្រាស់គ្រឿងញៀនទាំងអស់នោះតែងតែដើរ ពេញសហគមន៍នៅពេលយប់ដើម្បីចេញលួចមានអ្នកខ្លះអូសឥវ៉ាន់ដែលលួចបានពីកន្លែងផ្សេងៗមកចែកគ្នាក្នុងសហគមន៍ ពេលខ្លះពួកវាឈ្លោះគ្នា ស្រែកឮៗធ្វើឱ្យមានសំឡេងឆ្អេព្រុសពេញភូមិ។

ចំពោះនៅក្នុងសហគមន៍អណ្តូង១ ប្រភពនៃការបំពុលលំលេងបណ្តាលមកពីការចាក់បាស់ការចាក់តន្ត្រី។

យុវជនវ័យទម្រង់ម្នាក់បានលើកឡើងថា៖

> ប្រភពនៃការបំពុលសំឡេងចេញពីការជួបជុំគ្នាស៊ីផឹករបស់អ្នកជិតខាង ពួកគាត់ភាគច្រើនចំណាយពេលថ្ងៃចុងសប្តាហ៍ជួបជុំគ្នា មានការចាក់តន្ត្រីច្រៀងជដែកគ្នាលឺៗ។ សម្រាប់ការជួបជុំរបស់ពួកគាត់តាំងពីម៉ោង៨ព្រឹកដល់ម៉ោង ១១យប់ យ៉ាងឆាប់បំផុត។











## ៥.៤. ប្រភពនៃការបំពុលសំឡេង

យោងតាម ទិន្នន័យរបស់ប្រជាសហគមន៍ដែលរស់នៅសហគមន៍ព្រែកតាគង់៦០ម៉ែត្របានបញ្ជាក់ថាប្រភពនៃការបំពុលសំឡេងដែលមាននៅក្នុងសហគមន៍រួមមាន ប្រភពសំឡេងចេញពីការជួញដូរនិងចែកចាយគ្រឿងញៀនមានចំនួន ៦១% ចំណែកឯប្រភពសំឡេងចេញពីក្រុមក្មេងទំនើងពីតំបន់អាណាធិបតេយ្យមានចំនួន ៣% រីឯប្រភពសំឡេងចេញមកពីអាគារខុនដូរជាប់សហគមន៍មានចំនួន ៩% និង មានតែ ២៧% តែប៉ុណ្ណោះដែលប្រាប់ថាសហគមន៍មិនមានប្រភពនៃការបំពុលសំឡេងនោះទេ។

បើក្រឡេកទៅមើលសហគមន៍អណ្តូង១វិញបានបង្ហាញថា ប្រភពដែលកើតចេញមកពីការជួបជុំស៊ីផឹកមានចំនួន១០០% ចំណែកឯប្រភពដែលកើតចេញមកពីការសាងសង់នានា និងប្រភពចេញមកពីការឈ្លោះប្រកែកគ្នាគឺគ្មានឡើយ។









## ៥.៥.បញ្ហាប្រឈមដែលបង្កដោយការបំពុលដោយសំឡេង

យោងតាមរយៈបទសម្ភាសន៍ជាមួយប្រជាសហគមន៍ព្រែកតាគង់៦០ម៉ែត្រ ផលប៉ះពាល់នៃការបំពុលដោយសំឡេងមានការជះឥទ្ធិពលដល់សុខភាពផ្លូវកាយនិងសុខភាពផ្លូវចិត្ត ដូចជាបញ្ហាបេះដូង អស់កម្លាំង ធុញថប់ខ្លាំងជាដើម។

ជាក់ស្តែង ប្រជាសហគមន៍ម្នាក់បានមានប្រសាសន៍ថា៖

> ជាធម្មតានៅពេលដែលមានការរំខានដោយសំឡេងបែបនេះ ខ្ញុំមិនបានគេងគ្រប់គ្រាន់នោះទេ ពេលឮសំឡេងមនុស្សស្រែកឮៗដែលបង្កដោយជនអាណាថា នៅពេលយប់វាបានធ្វើឱ្យខ្ញុំមានអារម្មណ៍ភ័យខ្លាច បេះដូងចង់គាំងហើយ និងមានអារម្មណ៍ថាគ្មានសុវត្ថិភាពបំផុត ពេលដែលខ្ញុំភ្ញាក់ហើយគឺពិបាកគេងលក់វិញណាស់។

ប្រជាសហគមន៍ម្នាក់ទៀតបានបញ្ជាក់ថា៖

> ផលប៉ះពាល់ពីការបំពុលសំឡេងនេះ ធ្វើឱ្យខ្ញុំពិបាកគេង គេងមិនបានស្កប់ មានអារម្មណ៍ថាឈឺក្បាល គ្មានកម្លាំង ធុញថប់ខ្លាំង ជាពិសេសខ្ញុំមានកូនតូចចឹងធ្វើឱ្យកូនខ្ញុំភ័យ បេះដូងលោតញាប់ស្រែកយំខ្លាំងៗបាស់ដៃបាស់ជើង។

ស្រដៀងគ្នាទៅនឹងសហគមន៍ព្រែកតាគង់៦០ម៉ែត្រដែរប្រជាជនជិត១០០% នៅក្នុងសហគមន៍អណ្តូង១បានបញ្ជាក់ថាមានផលប៉ះដែលបង្កដោយ ការបំពុលដោយសំឡេងជាពិសេសដល់ដំណេករបស់ពួកគាត់។

ប្រជាសហគមន៍វ៉ៃកណ្តាលម្នាក់បានពោលថា៖

> ផលប៉ះពាល់នៃការបំពុលសំឡេងនេះ បានរំខានដល់ដំណេករបស់ខ្ញុំនិងធ្វើឱ្យខ្ញុំមានអារម្មណ៍ស្រ្តេសខ្លាំង ក្មេងពិបាកក្នុងការគេង។

## ៥.៦. ដំណោះស្រាយសម្រាប់ការបំពុលសំឡេង

ដើម្បីកាត់បន្ថយនិងសម្របខ្លួនទៅនឹងការបំពុលដោយសំឡេងដែលបានកើតឡើងនៅក្នុងសហគមន៍ ប្រជាសហគមន៍បានប្រើប្រាស់យុទ្ធសាស្រ្តដូចជាការព្រមានព្រមទាំងប្រើសម្តីជាហឹង្សាក្នុងការតបតទៅវិញ ប៉ុន្តែក៏មានប្រជាសហគមន៍ខ្លះទៀតមិនហានក្នុងការតបតវិញដែរ។

ជាក់ស្តែងប្រជាសហគមន៍វ៉ៃកណ្តាលម្នាក់បាននិយាយថា៖

> វិធីសាស្រ្តដែលខ្ញុំបានធ្លាប់ធ្វើពីមុនមកគឺការស្រែកជេរពីក្នុងផ្ទះទៅកាន់ពួកក្រុមមិនល្អទាំងនោះ ព្រោះពេលយប់ខ្ញុំមិនហ៊ានចេញក្រៅនោះទេ ដោយសារសម្បូរទៅដោយជនអាណាថានៅខាងក្រៅដែលអាចបង្កគ្រោះថ្នាក់។

ប្រជាសហគមន៍ម្នាក់ទៀតដែលមានអាយុប្រហែល៣០ឆ្នាំ បានលើកឡើងថា៖

> ខ្ញុំគ្មានវិធីសាស្រ្តអ្វីទេ មានតែទ្រាំស្តាប់ទៅ ហើយក៏មិនហ៊ានប្រាប់អាជ្ញាធរដែរព្រោះ ដឹងថាទោះប្រាប់គាត់ គាត់គ្រាន់តែប្រាប់ថានឹងទៅជួយអន្តរាគមន៍ តែមិនដែលចេញជាសកម្មភាពឡើយ។

ទិន្នន័យសិក្សាស្រាវជ្រាវនៅក្នុងសហគមន៍អណ្តូង១បានគូសបញ្ជាក់ច្បាស់ថាប្រជាជនមិនមានសេចក្តីក្លាហានក្នុងការប្រាប់បញ្ហាដែលកើតមាននៅក្នុងសហគមន៍របស់ពួកគាត់នោះទេ ពីព្រោះគិតថាបញ្ហាបំពុលដោយសំឡេងនេះមិនមែនជាបញ្ហាសំខាន់ឬជាបញ្ហាតូចតាចជាដើម។

ប្រជាសហគមន៍វ៉ៃកណ្តាលម្នាក់ទៀត បានពោលថា៖

> មានតែទ្រាំស្តាប់ខ្ញុំមិនហ៊ានប្រាប់ទៅកាន់អាជ្ញាធរមូលដ្ឋានឱ្យបានដឹងនោះទេ តែបើរាយការណ៍ទៅកាន់អាជ្ញាធរអាចមានប្រសិទ្ធភាពខ្លះ។

សហគមន៍អណ្តូង១




## ៥.៧.អន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន

តាមរយៈ ទិន្នន័យបានបង្ហាញថាប្រជាជន ៩៤%នៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រធ្លាប់សុំការជួយអន្តរាគមន៍ពីសំណាក់អាជ្ញាធរ តែផ្តោតសំខាន់ទៅលើបញ្ហាគ្រឿងញៀន ពីព្រោះពួកគាត់គិតថាបញ្ហាគ្រឿងញៀននេះជាបញ្ហាចម្បង និងមានលក្ខណៈធ្ងន់ធ្ងរ។ ទិន្នន័យដែលទទួលបានពីសហគមន៍អណ្តូង១បានបញ្ជាក់ថាប្រជាសហគមន៍ប្រមាណតែ២៤%ប៉ុណ្ណោះដែលធ្លាប់ប្រាប់អំពីកង្វល់របស់ពួកគាត់ទាក់ទងនឹងការបំពុលដោយសំឡេងនេះ។

សហគមន៍ព្រែកតាគង់៦០ម៉ែត្រ






## ៥.៨.ប្រសិទ្ធភាពនៃការឆ្លើយតបរបស់អាជ្ញាធរ

សរុបជារួមមក ការអន្តរាគមន៍ពីអាជ្ញាធរមូលដ្ឋាន សម្រាប់សហគមន៍ទាំងពីរមិនសូវមានប្រសិទ្ធភាព។ ទិន្នន័យនៃលទ្ធផលស្រាវជ្រាវរបស់សហគមន៍ព្រែកតាគង់៦០ម៉ែត្របានបង្ហាញ ប្រជាសហគមន៍ចំនួន៩៤%បានប្រាប់ថាការជួយរបស់អាជ្ញាធរមិនសូវមានប្រសិទ្ធភាព។ ចំពោះទិន្នន័យនៅក្នុងសហគមន៍អណ្ដូង១ ប្រជាសហគមន៍៩៤%បានមានប្រសាសន៍ថាការជួយអន្តរាគមន៍របស់អាជ្ញាធរមានប្រសិទ្ធភាពខ្លះ។

សហគមន៍ព្រែកតាគង់៦០ម៉ែត្រ




សហគមន៍អណ្ដូង១






# ៦. សេចក្តីសន្និដ្ឋាន



សហគមន៍ទាំងពីរសុទ្ធតែទទួលរងនូវការបំពុលដោយសំឡេងដូចគ្នា ប៉ុន្តែសហគមន៍ព្រែកតាគង់៦០ម៉ែត្រទទួលរងការបំពុលដោយសំឡេងធ្ងន់ធ្ងរជាងសហគមន៍អណ្តូង១។ ប្រភេទនៃការបំពុលដោយសំឡេងនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រមានដូចជា សំឡេងមនុស្សដើរស្រែកពេលយប់ ការជួញដូរគ្រឿងញៀន ការសេបគ្រឿងញៀន និងសំឡេងម៉ាស៊ីនបាញ់មូស ។ រីឯប្រភពនៃការបំពុលសំឡេងដែលធ្ងន់ធ្ងរនៅក្នុងសហគមន៍អណ្តូង១រួមមានសំឡេងចាក់បាស់ និងការជួបជុំគ្នាទទួលទានគ្រឿងស្រវឹងនៅតាមផ្ទះ។ បន្ថែមពីនេះទៀតប្រជាសហគមន៍ភាគច្រើនខ្វះការយល់ដឹងអំពីអ្វីទៅជាការបំពុលដោយសំឡេង និងបញ្ហានានាដែលកើតឡើងពីការបំពុលដោយសំឡេង។ ទន្ទឹមនឹងនេះដែរ ការបំពុលដោយសំឡេងបានផ្តល់ផលប៉ះពាល់ដូចជា សុខភាពរាងកាយ និងសុខភាពផ្លូវចិត្ត។ ចំពោះមនុស្សចាស់ឬមនុស្សពេញវ័យបង្កឱ្យមានបញ្ហាបេះដូង ការគេង ឈឺក្បាល អស់កម្លាំង និងចំពោះកុមារនិងទារក បានបង្កឱ្យពួកគេភិតភ័យនៅពេលដែលមានការបំពងសំឡេងៗៗ។ សុខភាពផ្លូវចិត្តរួមមាន អារម្មណ៍ភ័យខ្លាចគ្មានសុវត្ថិភាព ធុញថប់ខ្លាំង តានតឹងក្នុងអារម្មណ៍ និងបង្កជាអំពើហិង្សាពិបាកក្នុងការរស់នៅបាត់បង់ទំនាក់ទំនងល្អ និងបង្កឱ្យមានភាពអាណាធិបតេយ្យនៅក្នុងសហគមន៍។

ចំណែកឯវិធីសាស្ត្រដែលប្រជាសហគមន៍ទាំងពីរអាចធ្វើបានដើម្បីទប់ស្កាត់ការបំពុលសំឡេងមានដូចជា ការទ្រាំស្តាប់ ការស្តីបន្ទោសអ្នកដែលបំពងសំឡេង ការស្រែកជេរបញ្ឆោរ ការរាយការណ៍ទៅអាជ្ញាធរ ប៉ុន្តែការធ្វើបៀបនេះមិនមានប្រសិទ្ធភាពនោះទេ។

ក្នុងការជួយគាំទ្រពីសំណាក់អាជ្ញាធររវាងសហគមន៍ទាំង២ អំពីបញ្ហាបំពុលដោយសំឡេងនេះមិនសូវមានលក្ខណៈសកម្មនោះទេ។ ចំពោះប្រជាសហគមន៍អណ្តូង១ អាជ្ញាធរមូលដ្ឋានបានអន្តរាគមន៍បានមួយចំនួនក្នុងករណីដែលមានការបំពុលសំឡេងខ្លាំងដោយការចាក់តន្ត្រី និងការជួបជុំគ្នាទទួលទានគ្រឿងស្រវឹងប៉ុន្តែការអន្តរាគមន៍របស់អាជ្ញាធរទៅលើបញ្ហាបំពុលដោយសំឡេងមិនសូវមានប្រសិទ្ធិភាពឡើយ។ ស្រដៀងគ្នាដែរការអន្តរាគមន៍របស់អាជ្ញាធរនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រក៏មិនការកែប្រែអ្វីច្រើនដែរពីព្រោះ ភាពអនាមិកនៅតែកើតឡើង ទោះបីជាអាជ្ញាធរមូលដ្ឋានបានចុះល្បាតនៅក្នុងសហគមន៍ចំនួន២ ទៅ៣ដង។

អ្វីដែលកាន់តែសោកស្តាយបំផុតនោះប្រជាសហគមន៍ បានជួបប្រទះការបំពុលដោយសំឡេងយ៉ាងធ្ងន់ធ្ងរជាទីបំផុត។ ប្រជាពលរដ្ឋបានសុំការជួយចុះអន្តរាគមន៍ចំពោះបញ្ហាគ្រឿងញៀន ដែលជាប្រភពនៃការបំពុលសំឡេងម្តងហើយម្តងទៀត ប៉ុន្តែមិនមានការឆ្លើយតបមកកាន់ប្រជាពលរដ្ឋក្នុងសហគមន៍ឡើយ។ ចំពោះករណីគ្រឿងញៀនដែលបានកើតឡើងនៅក្នុងសហគមន៍៦០ម៉ែត្រ អាផ្វាធរហាក់បង្ហាញនូវទង្វើបែបមិនខ្វល់ខ្វាយមិនមានការបារម្ភ ព្រមទាំងមិនបានបំពេញតួនាទីជាអាផ្វាធរដ៏ល្អម្នាក់ឡើយ។ ចំណុចនេះបានគូសបញ្ជាក់យ៉ាងច្បាស់ថាប្រជាពលរដ្ឋ ដែលរស់នៅតំបន់សំណង់អាណាធិបតេយ្យមិនត្រូវបានយកចិត្តទុកដាក់អំពីសិទ្ធិ និងសុវត្ថិភាពរបស់ពួកគាត់ឡើយបើធៀបនឹងសហគមន៍រៀបរយក្នុងទីក្រុង។



# ៧. អនុសាសន៍



## ប្រជាសហគមន៍

- ប្រជាពលរដ្ឋគួរប្រកាន់ខ្ជាប់នូវសេចក្តីថ្លៃថ្នូរ ងត្រូវមានវិន័យក្នុងការរស់នៅ។ ដូច្នេះ នៅក្នុងសហគមន៍នឹងមិនមានការបំពុលដោយសំឡេងនានាដែលអាចបង្កការរំខានដល់ការរស់នៅ ដោយមិនត្រូវប្រើប្រាស់ឧបករណ៍រំពងសំឡេងលើសកម្រិតដែលបានចែងក្នុងអនុក្រឹត្យស្តីពី ការត្រួតពិនិត្យការបំពុលខ្យល់និងការរំខានដោយសំឡេង លេខ ៤២ អនក្រ.បកដែលបានចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០ ។
- ប្រជាសហគមន៍គួររាយការណ៍ទៅកាន់អាជ្ញាធរដើម្បីដោះស្រាយបញ្ហាដែលសហគមន៍បានជួបប្រទះ។

## អាជ្ញាធរមូលដ្ឋាន

- រាជរដ្ឋាភិបាលថ្នាក់ក្រោមជាតិគួរពិនិត្យលើការអនុវត្តច្បាប់ចំពោះបញ្ហាគ្រឿងញៀននិងអនុវត្តច្បាប់ឱ្យបានតឹងរឹង និងត្រូវធ្វើការចុះល្បាតជាញឹកញាប់នៅក្នុងសហគមន៍ឱ្យបានរាងរាល់ពេលយប់។
- អាជ្ញាធរគួរតែដាក់ផែនការឱ្យបានជាក់លាក់ក្នុងការចុះល្បាតក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រដែលអាចមានអាជ្ញាធរម្នាក់ និងមានកម្លាំងសមត្ថកិច្ចយ៉ាងតិច៤នាក់ ចុះល្បាតជារាងរាល់យប់នៅចន្លោះម៉ោង៩ទៅដល់ម៉ោង១យប់។ អាជ្ញាធរក៏ត្រូវបន្តសកម្មភាពចុះល្បាតនេះជាប្រចាំតាមកាលវិភាគ និងធ្វើការវាស់វែងលទ្ធផលមុនពេលចុះល្បាតនិងក្រោយពេលចុះល្បាតជាប្រចាំខែ។
- អាជ្ញាធរមូលដ្ឋាន ប៉ូលីស និងក្រុមប្រឹក្សាឃុំសង្កាត់ជួយពិនិត្យ និងតាមដានស្ថានភាពនៅក្នុងសហគមន៍ព្រែកតាគង់៦០ម៉ែត្រ ជាពិសេសបញ្ហាគ្រឿងញៀន ចោរកម្ម និងជួយបំពេញរាល់តម្រូវការរបស់ប្រជាពលរដ្ឋដែលរស់នៅក្នុងសហគមន៍ ។

## អង្គការដៃគូ

- អង្គការមិនមែនរាជរដ្ឋាភិបាលទាំងឡាយជួយពិនិត្យនិងយកចិត្តទុកដាក់ចំពោះបញ្ហាបំពុលសំឡេង តាមរយៈសកម្មភាពចុះទៅបង្រៀនប្រជាសហគមន៍នៅតាមមូលដ្ឋាន បង្កើតវេទិកាបណ្តុះបណ្តាលស្តីពីការបំពុលសំឡេងដែលអាចរួមបញ្ចូល បញ្ហាប្រឈម ផលប៉ះពាល់នៃការបំពុលដោយសំឡេង វិធីបង្ការកុំឱ្យមានការបំពុលសំឡេងដែលប្រជាពលរដ្ឋអាចធ្វើបាន ព្រមទាំងជួយប្រជាពលរដ្ឋឱ្យយល់ដឹងអំពីសិទ្ធិ និងរបៀបនៃការប្រើសប្រាស់សិទ្ធិ

របស់ពួកគេឱ្យស្របទៅនឹងច្បាប់ ។

## ក្រសួងបរិស្ថាន

- ក្រសួងបរិស្ថានគួរបង្កើតច្បាប់ស្តីអំពីការបំពុលដោយសំឡេងឱ្យមានលក្ខណៈជាក់លាក់ច្បាស់លាស់ មានលក្ខណៈទូទៅកម្ម និងងាយស្រួលយល់ដល់អ្នកអាន ដែលគួរជៀសវាងការប្រើប្រាស់ពាក្យបច្ចេកទេសច្រើន។
- ក្រសួងបរិស្ថានគួរបែងចែកច្បាប់ដែលស្តីអំពីការបំពុលខ្យល់និងសំឡេងឱ្យបានជាក់លាក់ និងលម្អិតទៅលើចំណុចដូចជា និយមន័យពន្យល់ជាអត្ថន័យច្បាស់លាស់នៅក្នុងមាត្រានីមួយៗ ការដាក់ទោសទណ្ឌចំពោះអ្នកដែលប្រព្រឹត្តនូវសកម្មភាពខុសច្បាប់ឱ្យបានជាក់លាក់ជាងមុន។



(+855) 023 555 1964

sttcambodia

UV:https//urbanvoicecambodia.net

www.teantnaut.org